ភ្នំពេញ
អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង
សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Tel: 023 213 563, Fax: 023 213 562
Vanda Institute

សៀមរាប
អគារលឿង ផ្លូវ ៧មករា (ជនន្លង់) ភូមិវត្តបូព៌
សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
Tel: 017 370 268, Fax: 069 533 339
Vanda Institute Siem Reap Branch

បាត់ដំបង
ដីឡូត៍លេខ 271 ផ្លូវលេខ614 ភូមិវ៉ាចេក2
សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
Tel: 053 732 563, Fax: 096 855 36 96
Vanda Institute of Battambang

www.vanda.edu.kh

SCIENCE MAGAZINE

លេខទី៤

ទស្សនាវដ្ដីវិទ្យាសាស្ត្រ
SCIENCE MAGAZINE

មជ្ឈមណ្ឌលស្រាវជ្រាវ

លេខទី៤ ២០២៥

ចាត់ដំបង ភ្នំពេញ សៀមរាប

ថ្នាក់ដឹកនាំ
និងសមាសភាពនៃមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេងសំអឿន
ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា
អនុ.អចិន្ត្រៃយ៍មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត អាស សំណាង
ប្រធានក្រុមនិក្ខេបបទ និងសារណា

បេក្ខបណ្ឌិត ជា ហ្ស៊ីចង្វៀង
ប្រធានក្រុមការងារទស្សនាវដ្ដី

លោក ហ៊ឿ ម៉ុក
ប្រធានក្រុមស្រាវជ្រាវផ្សេងៗ

លោក កុយ សុធី
សមាជិក

លោក យ៉ឿន យ៉ង
សមាជិក

លោក ម៉ូ ជុនហេង
សមាជិក

លោក ហុង ឫទ្ធជន
សមាជិក

កញ្ញា តុង គឹមណាង
សមាជិក

២០២៥ វិទ្យាស្ថាន វ៉ាន់ដា
ចំនួន២00ច្បាប់

រក្សាសិទ្ធិគ្រប់យ៉ាងគ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះ
នឹងត្រូវបានចោះពុម្ពឡើងវិញដោយគ្មានការអនុញ្ញាត
ជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថាន វ៉ាន់ដា ឡើយ។

2025 VANDA Institute
No.200 copies

All rights reserved. by any means, without permission
in writing from VANDA Institute.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថាន វ៉ាន់ដា
ក្រុមប្រឹក្សាភិបាល
លេខ:.៣៧..០៤.២៥ក្រកិ

ថ្ងៃអង្គារ ១១កើត ខែមេត្រា ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ត្រូវនឹងថ្ងៃទី..៤..ខែ..កញ្ញា..ឆ្នាំ២០២៤

សមាសភាពក្នុងការងារទស្សនាវដ្ដីវិទ្យាសាស្ត្រ (Science Magazine) សម្រាប់បុគ្គលិកអប់រំ នៅវិទ្យាស្ថាន វ៉ាន់ដា

អនុម័តចុងក្រោយ

បណ្ឌិត **ហេង វ៉ាន់ដា**

និពន្ធនាយក

បណ្ឌិត **ហ៊ូ គុជគន្ធលីនណា**

លេខាធិការ

គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ស្រាវជ្រាវ និងឌីជីថល

បច្ចេកទេសកុំព្យូទ័រ

បេក្ខបណ្ឌិត **ស្រេង ផល្លា**

បេក្ខបណ្ឌិត **ជា ហ្គ្លិចឡេង**

ទីប្រឹក្សា និងអក្ខរាវិរុទ្ធ

បណ្ឌិត **សេង សំអឿន**

បណ្ឌិត **ហេង ឥសាល**

បេក្ខបណ្ឌិត **ឈៀង សុន្ធារី**

គណៈកម្មការត្រួតពិនិត្យ ចោះពុម្ព និងចែកផ្សាយ

មជ្ឈមណ្ឌលស្រាវជ្រាវ

ជ.ក្រុមប្រឹក្សាអប់រំ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

អាសយដ្ឋាន: អាគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Address: N°216-218, Mao Tse Toung Blvd., Sangkat Tumnub Tock, Khan Boeng Keng Kong, Phnom Penh.
ទូរស័ព្ទ: ០២៣ ២១៣ ៥៦៣ ទូរស័ព្ទដៃ: ០១២ ៧៧៨ ៦៤៤ ទូរសារ: ០២៣ ២១៣ ២៦២ អ៊ីមែល: vanda@camnet.com.kh ហ្វេសប៊ុក: www.vanda.edu.kh
Tel: 023 213 563, H/P: 012 778 644, Fax: 023 213 562, E-mail: vanda@camnet.com.kh. Website: www.vanda.edu.kh

សមាសភាពអ្នកនិពន្ធអត្ថបទ
OUR CONTRIBUTING WRITERS

លោក គី សុភាក់
ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍
ហិរញ្ញវត្ថុអន្តរជាតិ

លោកស្រី សុខ ដានី
ការប្រៀបធៀបប្រព័ន្ធពន្ធដារនៅ
ប្រទេសកម្ពុជា និងប្រទេសថៃ

បេក្ខបណ្ឌិត យ៉ាក រ៉ុទ្ធី
ការរីកចម្រើននៃធនាគារឌីជីថល
នៅកម្ពុជា

បេក្ខបណ្ឌិត សុខ ដារ៉ា
ការគ្រប់គ្រងអចលកម្មឱ្យមាន
ប្រសិទ្ធភាព

លោកស្រី វិចិត្ត ទិដ្ឋការ
ការបង់ពន្ធរបស់អាជីវកម្ម
អនឡាញ

លោក ហុង ប៊ុនថន
ផលប្រយោជន៍នៃការគ្រប់គ្រង
ហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត

លោក ហុង កែវដារ៉ា
ការទទួលខុសត្រូវលើរបាយការណ៍
ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់

បេក្ខបណ្ឌិត កែវ ស៊ីថា
ប្រសិទ្ធភាពការងារជាក្រុម

បេក្ខបណ្ឌិត កែវ ពៅរ៉ាទ្ធី
វិស័យមីក្រូហិរញ្ញវត្ថុចូលរួម
អភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា

កញ្ញា ប៊ូ ធារី
ការរៀបចំយុទ្ធសាស្ត្រដើម្បីយក
ឈ្នះគូប្រកួតប្រជែង

អារម្ភកថា

មជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវបានបង្កើតឡើងស្របតាមយន្តការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃវិទ្យាស្ថាន វ៉ាន់ដា (វ.វ.ដ) ក្នុងឆ្នាំ២០២២ ដើម្បីចូលរួមធ្វើការកែលម្អ ពង្រឹងគុណភាពនៃការស្រាវជ្រាវអប់រំ និងចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនៅវិទ្យាស្ថាន វ៉ាន់ដា។ មជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវបានចាត់តាំងឱ្យប្រតិបត្តិនូវតួនាទីសំខាន់ៗ ដូចជា ការស្រាវជ្រាវជាមួយបុគ្គលិកអប់រំ និងនិស្សិត និងជាអ្នកសម្របសម្រួលការងារពាក់ព័ន្ធផ្សេងៗក្នុងវិទ្យាស្ថាន វ៉ាន់ដា។ យើងបានដឹងហើយថាការស្រាវជ្រាវ គឺជាប្រធានបទមួយដ៏ពេញនិយមក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សា។ ការស្រាវជ្រាវដែលមានលទ្ធផលល្អ តម្រូវឱ្យអ្នកស្រាវជ្រាវធ្វើការសិក្សាប្រមូលនូវព័ត៌មាន និងទិន្នន័យមកពីប្រភពផ្សេងៗគ្នា យកមកចងក្រងជាលទ្ធផលឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើង ហើយវិធីសាស្ត្រប្រមូលព័ត៌មាន និងទិន្នន័យ របស់អ្នកស្រាវជ្រាវគឺធ្វើតាមរយៈ បែបបរិមាណវិស័យ (Quantitative Methodology) គុណវិស័យ (Qualitative Methodology) និងបែបចម្រុះ (Mixed Methodology) ដែលប្រើប្រាស់ទិន្នន័យដំបូង (Primary data) និងទិន្នន័យបន្ទាប់ (Secondary data)។

មជ្ឈមណ្ឌលស្រាវជ្រាវនៃវិទ្យាស្ថាន វ៉ាន់ដា បានអនុវត្តការងារស្រាវជ្រាវជាច្រើនដូចជា ការការពារសារណាបញ្ចប់ការសិក្សារបស់និស្សិតបរិញ្ញាបត្រចំនួន ៣៦៣ប្រធានបទ ការប្រកួតប្រជែងស្នាដៃស្រាវជ្រាវរបស់និស្សិតចំនួន ៦លើក ស្មើនឹង ៨០ប្រធានបទ ការសរសេរអត្ថបទខ្លីរបស់បុគ្គលិកអប់រំចំនួន ៣០អត្ថបទ រួចមកហើយ។ សម្រាប់ខែមីនា ឆ្នាំ២០២៥នេះ មជ្ឈមណ្ឌលស្រាវជ្រាវនៃវិទ្យាស្ថាន វ៉ាន់ដា បានសម្រេចបោះពុម្ពផ្សាយទស្សនាវដ្ដីវិទ្យាសាស្ត្រលេខ០៤ ដើម្បីបម្រើផលប្រយោជន៍ជូនអ្នកសិក្សា។ ទស្សនាវដ្ដីលេខ០៤នេះ មានអត្ថបទជាច្រើន សរសេរបែបលក្ខណៈវិទ្យាសាស្ត្រ ដែលពាក់ព័ន្ធនឹងគណនេយ្យហិរញ្ញវត្ថុ ធនាគារ ពន្ធ ការគ្រប់គ្រងយុទ្ធសាស្ត្រ និងការវិភាគអំពីបញ្ហាទូទៅផងដែរ។ ទស្សនាវដ្ដីវិទ្យាសាស្ត្រនេះ មានការចូលរួមសរសេរពីសំណាក់ គណៈគ្រប់គ្រង និងបុគ្គលិកអប់រំចំនួន១០រូប ដែលមានគុណវុធិស្របតាមជំនាញ ដើម្បីដាក់តាំងបង្ហាញជាសាធារណៈនូវស្នាដៃដែលបានស្រាវជ្រាវយកមកចងក្រងជាទស្សនាវដ្ដីវិទ្យាសាស្ត្ររបស់វិទ្យាស្ថាន វ៉ាន់ដា។ ជាមួយគ្នានេះផងដែរ មជ្ឈមណ្ឌលស្រាវជ្រាវប្រចាំវិទ្យាស្ថាន វ៉ាន់ដា សង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រនេះនឹងក្លាយទៅជាឯកសារមួយដ៏សំខាន់ និងមានស្តង់ដាសម្រាប់រាល់កិច្ចការស្រាវជ្រាវដែលមាននៅក្នុងវិទ្យាស្ថាន ក៏ដូចប្រើប្រាស់តាមតម្រូវការ។

មជ្ឈមណ្ឌលស្រាវជ្រាវយើងខ្ញុំ រង់ចាំទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាពីប្រិយមិត្តអ្នកអាន និងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន ដែលបានផ្ដល់មតិយោបល់កែលម្អនូវកង្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើងទាំងលើខ្លឹមសារ និងបច្ចេកទេស ដើម្បីឱ្យទស្សនាវដ្ដីនេះមានខ្លឹមសារ និងសារៈសំខាន់ចូលរួមចំណែកអភិវឌ្ឍន៍វិទ្យាស្ថាន និងសង្គមជាតិ។

ថ្ងៃពុធ ៤ កើត ខែចេត្រ ឆ្នាំម៉ាមី ព.ស ២៥៣៨
ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២៥

ជ. ក្រុមប្រឹក្សាអប់រំ

ប្រធាន

បណ្ឌិត ហ៊ីង ឥន្ទលីនណា

មាតិកា

១. ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដោយលោក គី សុភាក់..... ១-៧
២. ការប្រៀបធៀបប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា និងប្រទេសថៃ ដោយលោកស្រី សុខ ផានី.....៨-១៧
៣. ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា ដោយបេក្ខបណ្ឌិត យ៉ាក រ៉ុទ្ធី ១៨-២៥
៤. ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព ដោយបេក្ខបណ្ឌិត សុខ ដារ៉ា ២៦-៣២
៥. ការបង់ពន្ធរបស់អាជីវកម្មអនឡាញ ដោយលោកស្រី រិចិត្ត ទិដ្ឋការ..... ៣៣-៤៨
៦. ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត ដោយលោក ហុង ប៊ុនថន . ៤៩-៥៦
៧. ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់ ដោយលោក ហុង កែវដារ៉ា ..៥៧-៦៧
៨. ប្រសិទ្ធភាពការងារជាក្រុម ដោយបេក្ខបណ្ឌិត កែវ ស៊ីថា ៦៨-៧៦
៩. វិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា ដោយបេក្ខបណ្ឌិត កែវ ពៅរ៉ិទ្ធី ៧៧-៨៥
១០. ការរៀបចំយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង ដោយកញ្ញា ប៊ូ ធារី..... ៨៦-៩៥

ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

The Development of International Financial Reporting Standards

គី សុភាក់
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម
សមាជិកអនុគណៈកម្មការជំនាញគណនេយ្យហិរញ្ញវត្ថុ

មូលន័យសង្ខេប

គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IFRS) ដែលបង្កើតឡើងដោយក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) មានគោលបំណងបង្កើតសំណុំស្តង់ដានៃច្បាប់គណនេយ្យ ដែលបង្កើនតម្លាភាព ភាពប្រៀបធៀប និងភាពស៊ីសង្វាក់នៃរបាយការណ៍ហិរញ្ញវត្ថុជាអន្តរជាតិ។

ដើម្បីដោះស្រាយគោលបំណងនេះ ការស្រាវជ្រាវត្រូវបានរៀបចំឡើងតាមរយៈសំណួរដែលបានចោទសួរ តាមរយៈការសិក្សាស្រាវជ្រាវនេះផ្តល់នូវការយល់ដឹងដ៏ទូលំទូលាយអំពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ ការស្រាវជ្រាវត្រូវបានប្រើវិធីសាស្ត្រគុណវិស័យ ដោយផ្តោតជាចម្បងលើការវិភាគទិន្នន័យបន្ទាប់បន្សំ។ ការប្រមូលទិន្នន័យបន្ទាប់បន្សំបានមកពី អត្ថបទខ្លីៗ និងប្រភពគេហទំព័រដែលពាក់ព័ន្ធនឹងប្រធានបទនៃការស្រាវជ្រាវ។ ការវិភាគទិន្នន័យបន្ទាប់បន្សំ គឺធ្វើតាម ការវិភាគរកប្រធានបទ (Thematic Analysis) តាមរយៈការវិភាគរកប្រធានបទនេះនឹងត្រូវបានធ្វើឡើងដើម្បីសំយោគឯកសារដែលបានមកពី អត្ថបទខ្លីៗ និងគេហទំព័រផ្សេងៗ ដោយបញ្ជាក់ពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដោយក្រុមប្រឹក្សាកំណត់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IASB) មានសារៈសំខាន់ណាស់ក្នុងការបង្កើនតម្លាភាព ភាពប្រៀបធៀប និងភាពស៊ីសង្វាក់នៃរបាយការណ៍ហិរញ្ញវត្ថុជាអន្តរជាតិ។

១. សេចក្តីផ្តើម

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS=International Financial Reporting Standards) គឺជាសំណុំនៃស្តង់ដាគណនេយ្យដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB=International Accounting Standards Board-1973)។ IFRS ត្រូវបានបង្កើតឡើងដើម្បី ផ្តល់ជាស្តង់ដារួមសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ ជានានូវភាពស៊ីសង្វាក់គ្នា តម្លាភាព និងការប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅទូទាំងប្រទេស។

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS)បង្កើតជាគោលការណ៍សម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមមាន របាយការណ៍តុល្យការ របាយការណ៍លទ្ធផល របាយការណ៍លំហូរសាច់ប្រាក់ និងរបាយការណ៍នៃការបម្រែបម្រួលភាគហ៊ុនរបស់ម្ចាស់អាជីវកម្ម។ ស្តង់ដាទាំងនេះគ្របដណ្តប់ទៅលើនិយមន័យ ការទទួលស្គាល់ ការវាស់វែង និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ។ គោលដៅរបស់ IFRS គឺដើម្បីបង្កើនគុណភាព ភាពពាក់ព័ន្ធ និងភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយហេតុនេះ វាជួយសម្រួលដល់ការសម្រេចចិត្តកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ រួមមាន៖ វិនិយោគិន ម្ចាស់បំណុល និយ័តករ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ តាមរយៈការលើកកម្ពស់តម្លាភាព និងការប្រៀបធៀប IFRS រួមចំណែក ដល់ស្ថិរភាព និងប្រសិទ្ធភាពនៃទីផ្សារហិរញ្ញវត្ថុពិភពលោក លើកទឹកចិត្តការវិនិយោគ និងជំរុញកំណើនសេដ្ឋកិច្ច។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IFRS) មានសារៈសំខាន់ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលផ្តល់អត្ថប្រយោជន៍ចំពោះក្រុមហ៊ុន វិនិយោគិន និងទីផ្សារលើពិភពលោក។

ដោយមើលឃើញពីសារៈសំខាន់នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ទើបមានសំណួរពីរលើកឡើងថា៖

១. តើក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) អភិវឌ្ឍន៍ IFRS យ៉ាងដូចម្តេច?

២. តើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) មានការវិវត្តយ៉ាងដូចម្តេច?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើវិធីសាស្ត្រគុណវិស័យ (Qualitative methods) ដោយផ្តោតជាចម្បងលើការវិភាគទិន្នន័យបន្ទាប់បន្សំបានមកពី ប្រភពគេហទំព័រចំនួន៥ IFRS, IASB due process, wikipedia.org, journal of accountancy និង fasb.org ដែលពាក់ព័ន្ធនឹងប្រធានបទ ដើម្បីយកមកវិភាគក្នុងគោលបំណងបញ្ជាក់ពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

សម្រាប់សំណួរទី១ ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន២ IFRS និង IASB due process ដើម្បីយកមកដោះស្រាយទៅលើការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងការវិភាគទិន្នន័យបន្ទាប់បន្សំ ធ្វើតាមការវិភាគរកប្រធានបទ (Thematic Analysis) តាមរយៈការវិភាគរកប្រធានបទ ដើម្បីសំយោគឯកសារដែលបានមកពីគេហទំព័រទាំងពីរក្នុងគោលបំណងបញ្ជាក់ពីការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

សម្រាប់សំណួរទី២ ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន៣ wikipedia.org, journal of accountancy, fasb.org ដើម្បីយកមកដោះស្រាយទៅលើការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ

អន្តរជាតិ និងការវិភាគទិន្នន័យបន្ទាប់បន្សំ ធ្វើតាមការវិភាគរកប្រធានបទ (Thematic Analysis) តាមរយៈការវិភាគរកប្រធានបទ ដើម្បីសំយោគឯកសារដែលបានមកពីគេហទំព័រទាំងបីក្នុងគោលបំណងបញ្ជាក់ពី ការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

អភិវឌ្ឍន៍ (Development) មានន័យថាលទ្ធភាពអាចរស់នៅយូរអង្វែងប្រកបដោយសុខភាព ទទួលការអប់រំនិងលទ្ធភាពទទួលបានធនធានចាំបាច់សម្រាប់ការរស់នៅសមរម្យ[1]។

របាយការណ៍ហិរញ្ញវត្ថុ (Financial statement) គឺជារបាយការណ៍ដែលបង្ហាញ ឬរៀបរាប់ពីប្រវត្តិសាច់រឿងដែលកើតឡើងកន្លងមកនៃការធ្វើអាជីវកម្មរបស់អង្គភាព។ របាយការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធផលហិរញ្ញវត្ថុ ស្ថានភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់[2]។

វិវត្តន៍ (Evolution) ត្រូវបានប្រើជាទូទៅ ក្នុងន័យថា សេចក្ដីចម្រើនលូតលាស់ ដំណើរប្រែប្រួល[3]។

ស្តង់ដា (Standard) គឺជាវិធីដែលអាចធ្វើឡើងវិញបាន មានការចុះសម្រុងគ្នា យល់ព្រម និងជាឯកសារនៃការធ្វើអ្វីមួយ។ ស្តង់ដាមានលក្ខណៈបច្ចេកទេស ឬលក្ខណៈវិនិច្ឆ័យជាក់លាក់ផ្សេងទៀតដែលត្រូវបានរចនាឡើងដើម្បីប្រើប្រាស់ជាច្បាប់ គោលការណ៍ណែនាំ ឬនិយមន័យ។ ស្តង់ដាជួយធ្វើឱ្យជីវិតកាន់តែសាមញ្ញ បង្កើនភាពជឿជាក់ ប្រសិទ្ធភាពនៃទំនិញ និងសេវាកម្មជាច្រើនដែលយើងប្រើប្រាស់[4]។

របាយការណ៍ហិរញ្ញវត្ថុ (Financial statement) គឺជាឧបករណ៍សំខាន់ៗដែលអាជីវកម្មប្រើប្រាស់ដើម្បីតាមដាន ផ្ដល់ការយល់ដឹងអំពីដំណើរការហិរញ្ញវត្ថុ និងសុខភាពទូទៅរបស់ក្រុមហ៊ុន[5]។

២. ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ត្រូវបានអភិវឌ្ឍដោយក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) ដែលជាអង្គភាពមួយឯករាជ្យក្នុងការបោះផ្សាយស្តង់ដាសម្រាប់ពិភពលោក។ ការអភិវឌ្ឍស្តង់ដានេះ មានសភាពទូលំទូលាយ ដើម្បីធានាឱ្យមានតម្លាភាព ការចូលរួមពីភាគីដែលពាក់ព័ន្ធ និងការធ្វើឱ្យសមស្របទៅនឹងការអនុវត្តជាអន្តរជាតិ។ ខាងក្រោមនេះ គឺជាដំណាក់កាលនៃការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៖

១. ការពិគ្រោះយោបល់លើកម្មវិធីអនុវត្តន៍ (Agenda Consultation)

ក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) បានធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ដើម្បីប្រមូលយោបល់ពីសមាជិកនៅជុំវិញពិភពលោក ហើយកំណត់ចំណុចដែលអាចបង្កើតស្តង់ដាថ្មី ឬវិសោធនកម្មស្តង់ដាដែលមានស្រាប់។

---

[1] តើពាក្យ«អភិវឌ្ឍន៍»មានន័យដូចម្តេច? ថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ២០២០ https://shorturl.at/kVLMu

[2] វិទ្យាស្ថាន វ៉ាន់ដា. (២០២៣). *ហិរញ្ញវត្ថុសម្រាប់អាជីវកម្ម.* បោះពុម្ពលើកទី៥ ទំព័រ១០

[3] បម្រើបម្រាស់ពាក្យ«វិវត្តន៍ និងវិឌ្ឍន៍»ក្នុងភាសាខ្មែរ! ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧ https://tinyurl.com/4k2ma3pk

[4] WHAT ARE STANDARDS? https://tinyurl.com/4xk5x54h

[5] Financial Statements on June 08, 2023 https://tinyurl.com/ynbkxk9h

២. កម្មវិធីស្រាវជ្រាវ (Research Program)

ដំណើរការស្រាវជ្រាវនេះ ចាប់ផ្តើមដោយស្វែងរកបញ្ហាដែលអាចបណ្តាលឱ្យមានការបង្កើតស្តង់ដាថ្មី ឬវិសោធនកម្មស្តង់ដាដែលមានស្រាប់។ ក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) នឹងធ្វើការស្រាវជ្រាវជាមួយនឹងការប្រមូលយោបល់ពីក្រុមប្រឹក្សា និងការពិគ្រោះជាមួយអ្នកពាក់ព័ន្ធ ដើម្បីវាយតម្លៃពីតម្រូវការ និងអត្តសញ្ញាណសម្រាប់ការបង្កើតស្តង់ដាថ្មី ឬវិសោធនកម្មស្តង់ដាដែលមានស្រាប់។

៣. ការពិគ្រោះយោបល់សាធារណៈ (Public Consultation)

បន្ទាប់ពីកំណត់បញ្ហារួច IASB នឹងបោះពុម្ពផ្សាយឯកសារពិភាក្សា (Discussion paper) ដែលមានការអញ្ជើញសាធារណជនដើម្បីផ្តល់យោបល់។ ឯកសារនេះ ផ្តល់ព័ត៌មានអំពីបញ្ហា ដំណោះស្រាយ និងហេតុផលដែលត្រូវពិចារណាពីការបង្កើតស្តង់ដាថ្មី ឬកែប្រែស្តង់ដាដែលមានស្រាប់។ អ្នកពាក់ព័ន្ធត្រូវបានអញ្ជើញដើម្បីផ្តល់យោបល់ត្រឡប់។

៤. ការអភិវឌ្ឍសេចក្តីព្រាងស្តង់ដា (Development of Exposure Draft)

ដោយផ្អែកលើយោបល់ត្រឡប់ពីឯកសារពិភាក្សា (Discussion paper) ក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) នឹងអភិវឌ្ឍន៍សេចក្តីព្រាងនៃការប៉ះពាល់ (Exposure Draft)។ សេចក្តីព្រាងនេះ គឺជាការស្នើឡើងនូវស្តង់ដាដែលរួមបញ្ចូលនូវការណែនាំជាក់លាក់ និងសំណើលម្អិត។ សេចក្តីព្រាងនៃការប៉ះពាល់ (Exposure Draft) ត្រូវបានបោះពុម្ពផ្សាយ ដើម្បីទទួលយោបល់បន្ថែមពីអ្នកពាក់ព័ន្ធ។

៥. ការធ្វើការស្រាវជ្រាវ និងសាកល្បង (Fieldwork and Testing)

ក្នុងអំឡុងពេល និងបន្ទាប់ពីដំណាក់កាលសេចក្តីព្រាងនៃផលប៉ះពាល់ (Exposure draft) ក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) អាចធ្វើការសាកល្បង និងប្រមូលទិន្នន័យបន្ថែម ដើម្បីយល់ពីផលប៉ះពាល់នៃស្តង់ដាដែលបានស្នើ។ ការធ្វើការស្រាវជ្រាវ និងសាកល្បងជួយក្នុងការវាយតម្លៃពីសមត្ថភាព និងផលប៉ះពាល់ដែលអាចមានលើការរាយការណ៍ហិរញ្ញវត្ថុ។

៦. ការពិចារណាឡើងវិញ (Redeliberation)

ក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) ពិនិត្យឡើងវិញលើយោបល់ត្រឡប់ដែលបានទទួលពីសេចក្តីព្រាងនៃការប៉ះពាល់ (Exposure Draft) និងលទ្ធផលផ្សេងនៃការស្រាវជ្រាវ។ ក្រុមប្រឹក្សាពិចារណាទៅលើមតិយោបល់ និងអាចធ្វើការកែប្រែសេចក្តីព្រាង ដើម្បីដោះស្រាយបញ្ហា ឬកែលម្អដើម្បីមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាព។

៧. ការបោះពុម្ពស្តង់ដា (Final Standard Issuance)

បន្ទាប់ពី IASB ជឿជាក់ថា ស្តង់ដាត្រូវបានរួចរាល់សម្រាប់ការអនុវត្ត ស្តង់ដាថ្មីនោះនឹងបោះពុម្ពផ្សាយជាសាធារណៈ។ ស្តង់ដាថ្មីត្រូវបានដំណើរការដោយស្ថាប័ននានា និងបញ្ចូលទៅក្នុងរចនាសម្ព័ន្ធនៃការរាយការណ៍ហិរញ្ញវត្ថុ។

៨. ការត្រួតពិនិត្យបន្ទាប់ពីអនុវត្ត (Post-Implementation Review) បន្ទាប់ពីស្តង់ដាថ្មីត្រូវបានអនុវត្តក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ បានធ្វើការត្រួតពិនិត្យបន្ទាប់ពីអនុវត្ត ដើម្បីវាយតម្លៃពីប្រសិទ្ធភាព និងកំណត់បញ្ហាដែលកើតឡើងក្នុងអំឡុងពេលអនុវត្ត។
យោបល់ត្រឡប់នេះអាចនាំទៅការកែប្រែបន្ថែម ឬការអភិវឌ្ឍស្តង់ដាថ្មីបន្ថែម ប្រសិនបើចាំបាច់។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) បានវិវត្តចាប់តាំងពីការចាប់ផ្តើម ដើម្បីសម្របខ្លួនទៅនឹងទិដ្ឋភាពផ្លាស់ប្តូរនៃហិរញ្ញវត្ថុជាសកល។ ខាងក្រោមនេះ ជាទិដ្ឋភាពទូទៅនៃការវិវត្តសំខាន់ៗនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៖

១. ប្រវត្តិ និងការបង្កើតដំបូង

1973-2000: ស្តង់ដាគណនេយ្យអន្តរជាតិ (IAS)

- ❖ ឆ្នាំ1973: គណៈកម្មាធិការកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASC) ត្រូវបានបង្កើតឡើងដោយស្ថាប័នគណនេយ្យមកពីជប់ប្រទេស ដើម្បីបង្កើតស្តង់ដាគណនេយ្យអន្តរជាតិ (IAS)។
- ❖ ឆ្នាំ1989: IASC បានចេញ "ក្របខ័ណ្ឌសម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" ដែលផ្តល់មូលដ្ឋានគ្រឹះនៃគំនិតសម្រាប់បង្កើតស្តង់ដាថ្មី និងវិសោធនកម្មស្តង់ដាដែលមានស្រាប់។

២. ការផ្លាស់ប្តូរទៅ (IFRS)

2001-2005: ការបង្កើត IFRS

- ❖ ឆ្នាំ2001: ក្រុមប្រឹក្សាស្តង់ដាកំណត់គណនេយ្យអន្តរជាតិ (IASB) បានជំនួសពី IASC ។ IASB បានចាប់ផ្តើមបង្កើតស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដោយជំនួស IAS ជាមួយ IFRS ។
- ❖ ឆ្នាំ2002: សហភាពអឺរ៉ុបបានសម្រេចចិត្តអនុម័ត IFRS សម្រាប់របាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី ចាប់ពីឆ្នាំ 2005 តទៅ ដែលជំរុញយ៉ាងខ្លាំងដល់ការអនុម័ត IFRS នៅទូទាំងពិភពលោក។

៣. ចំណុចសំខាន់ និងការកែប្រែ

2006-2011: ការបញ្ចូលគ្នា និងការអនុម័តជាសកល

- ❖ ឆ្នាំ2006: អនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង IASB និងក្រុមប្រឹក្សាស្តង់ដាគណនេយ្យហិរញ្ញវត្ថុ (FASB) មានគោលបំណងបង្រួបបង្រួម IFRS និង U.S. GAAP ។
- ❖ ឆ្នាំ2011: ប្រទេសជិត 120 បានទាមទារ ឬអនុញ្ញាតឱ្យប្រើប្រាស់ IFRS សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជី។

2012-2020: ការពង្រឹង និងស្តង់ដាថ្មី

- ❖ ឆ្នាំ2013: IFRS 13 "ការវាស់វែងតម្លៃទីផ្សារប៉ាន់ស្មាន" ត្រូវបានចេញ ដើម្បីផ្តល់ជាការណែនាំមួយសម្រាប់ការវាស់វែងតម្លៃទីផ្សារប៉ាន់ស្មាន។

- ❖ ឆ្នាំ2014: IFRS 15 "ចំណូលពីកិច្ចសន្យាជាមួយអតិថិជន" ត្រូវបានចេញ ដើម្បីធ្វើជាស្តង់ដាការអនុវត្ត ការទទួលស្គាល់ប្រាក់ចំណូល។
- ❖ ឆ្នាំ2016: IFRS 16 "ជួល" ត្រូវបានចេញដែលតម្រូវឱ្យអ្នកជួលទទួលស្គាល់ទ្រព្យសម្បត្តិ និងបំណុលសម្រាប់ការជួលភាគច្រើន។
- ❖ ឆ្នាំ2018: IFRS 9 "ឧបករណ៍ហិរញ្ញវត្ថុ" និង IFRS 17 "កិច្ចសន្យាធានារ៉ាប់រង" ត្រូវបានអនុវត្តន៍ដោយបង្កើនគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យាធានារ៉ាប់រង។

2021-បច្ចុប្បន្ន: និរន្តរភាព និងរបាយការណ៍ឌីជីថល

- ❖ ឆ្នាំ2021: មូលនិធិ IFRS បានប្រកាសពីការបង្កើតក្រុមប្រឹក្សាស្តង់ដានិរន្តរភាពអន្តរជាតិ (ISSB) ដើម្បីបង្កើតស្តង់ដាពិភពលោកសម្រាប់ការបង្ហាញហិរញ្ញវត្ថុដែលទាក់ទងនឹងនិរន្តរភាព។
- ❖ កំពុងដំណើរការ: មូលនិធិ IFRS បន្តស្វែងរកការរួមបញ្ចូលនៃការរាយការណ៍ឌីជីថល និងការកែលម្អស្តង់ដា ដើម្បីឆ្លើយតបនឹងការវិវត្តនៃការអនុវត្តអាជីវកម្ម និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា។

៣. សន្និដ្ឋាន

ការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដោយក្រុមប្រឹក្សាកំណត់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IASB) គឺការអភិវឌ្ឍមួយ ដែលមានដំណាក់កាលច្បាស់លាស់ និងអនុលោមតាមគោលការណ៍ជាក់លាក់ ដើម្បីធានាថា ស្តង់ដាមានគុណភាពខ្ពស់ និងទទួលស្គាល់នៅទូទាំងពិភពលោក។ ដំណាក់កាលនីមួយៗផ្តល់នូវទំនុកចិត្ត ភាពច្បាស់លាស់ ដល់អ្នកប្រើប្រាស់ ព្រោះការអភិវឌ្ឍ និងវិសោធនកម្មនៃស្តង់ដាមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធជាច្រើន ដើម្បីបង្កើតស្តង់ដាដែលធ្វើឱ្យមានការប្រៀបធៀប ភាពជឿជាក់ និងភាពពាក់ព័ន្ធនៃព័ត៌មានហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ទូទាំងពិភពលោក។

ឯកសារយោង

១. តើពាក្យ«អភិវឌ្ឍន៍»មានន័យដូចម្តេច? ថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ២០២០ https://shorturl.at/kVLMu

២. វិទ្យាស្ថាន វ៉ាន់ដា.(២០២៣).*ហិរញ្ញវត្ថុសម្រាប់អាជីវកម្ម.* បោះពុម្ពលើកទី៥ ទំព័រ១០ សរុបទំព័រ៥៣

៣. បម្រើបម្រាស់ពាក្យ«វិវត្តន៍ និងវិឌ្ឍន៍»ក្នុងភាសាខ្មែរ! ថ្ងៃ២៩ ខែមករា ឆ្នាំ២០១៧ https://tinyurl.com/4k2ma3pk

៤. WHAT ARE STANDARDS? *https://tinyurl.com/4xk5x54h*

៥. Financial Statements on June 08, 2023 https://tinyurl.com/ynbkxk9h

៦. IFRS Foundation on 26 June 2017 https://tinyurl.com/mn659hv9

៧. IASB due process. https://rb.gy/7sa6oa

៨. What have IASB and FASB convergence efforts achieved? On February 1, 2013 https://tinyurl.com/4y7vrxjc

៩. COMPARABILITY IN INTERNATIONAL ACCOUNTING STANDARDS A BRIEF HISTORY. https://rb.gy/3a1cj8

១០. International Accounting Standards Committee on 10 February 2021 https://tinyurl.com/4ttzjy4e

ការប្រៀបធៀបប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា និងប្រទេសថៃ

The Comparation of taxation in Cambodia and Thailand

សុខ ផានី
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម
អនុប្រធានផ្នែក គណនេយ្យអនុវត្តន៍ និងពន្ធ

មូលន័យសង្ខេប

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីសិក្សាស្វែងយល់ពីប្រព័ន្ធពន្ធដារនៃប្រទេសកម្ពុជា និងប្រទេសថៃ មានភាពខុសគ្នា ឬដូចគ្នាទៅលើអ្វីខ្លះ ដែលផ្តោតលើការប្រៀបធៀបគោលនយោបាយពន្ធដារ របៀបគ្រប់គ្រង និងប្រព័ន្ធពន្ធដាររបស់ប្រទេសទាំងពីរ។ ជាការពិតណាស់ ប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរ បានចូលរួមចំណែកអភិវឌ្ឍន៍ប្រទេស សេដ្ឋកិច្ច និងសង្គមជាតិយ៉ាងច្រើន ដូចជា សាងសង់មន្ទីរពេទ្យ សាលារៀន បើកប្រាក់ខែជូនមន្ត្រីរាជការ កងទ័ព កម្លាំងប្រដាប់អាវុធ និងសេវាសាធារណៈ...។

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យសម្រាប់រៀបរាប់ពីប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរ។ ការប្រមូលទិន្នន័យធ្វើឡើងបាន ដោយផ្អែកទៅលើឯកសារដូចជា Ministry of Finance The Revenue Department, Deloitte, The better Cambodia ច្បាប់សារពើពន្ធ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ សៀវភៅសទ្ធានុក្រមពន្ធដារ សៀវភៅសិក្សាគោលមុខវិជ្ជា ច្បាប់ពន្ធដារកម្ពុជានៃវិទ្យាស្ថាន វ៉ាន់ដា។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ប្រព័ន្ធពន្ធដារនៃប្រទេសកម្ពុជា និងប្រទេសថៃ ពិតជាមានភាពខុសគ្នានៅក្នុងផ្នែកសំខាន់ៗមួយចំនួន ដូចជា ការគ្រប់គ្រងប្រព័ន្ធពន្ធដារ នីតិវិធីរដ្ឋបាល យន្តការអនុវត្តច្បាប់ ការប្រមូលពន្ធ ប្រភេទពន្ធ អត្រាពន្ធ និងរបបពន្ធ។ សរុបជារួម ប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរពិតជាមានភាពស្រដៀងគ្នា និងភាពខុសគ្នាជាច្រើនតាមរយៈការគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធពន្ធដារ។

១.សេចក្តីផ្តើម

ប្រទេសជាសមាជិកសមាគមន៍អាស៊ានដែលស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ (ASEAN) មានចំនួន១០ ប្រទេស។ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសទាំងនោះ បានធ្វើការអភិវឌ្ឍយ៉ាងល្អប្រសើរលើគ្រប់វិស័យ ប្រទេសអាស៊ានទាំងអស់សុទ្ធសឹងតែជាប្រទេសមានសេដ្ឋកិច្ចរីកចម្រើនគួរឱ្យកត់សម្គាល់។ បើងាកមើលពីប្រព័ន្ធពន្ធដារវិញនោះ គឺមានភាពខុសគ្នាទៅតាមគោលនយោបាយពន្ធដារនៃប្រទេសនីមួយៗ ដូចជា ប្រទេសកម្ពុជា និងប្រទេសថៃជាដើម។

ស្ថិតក្រោមស្ថានភាព និងបរិយាកាសដែលប្រទេសកម្ពុជា និងប្រទេសថៃមានម៉ាក្រូសេដ្ឋកិច្ចដ៏ល្អប្រសើរ និងកំពុងធ្វើសកលភាវូបនីកម្មលើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មទាំងថ្នាក់អន្តរជាតិ និងតំបន់។ ចំពោះវិស័យពាណិជ្ជកម្មវិញ ដើម្បីទាក់ទាញ និងលើកទឹកចិត្តវិនិយោគិនឱ្យចូលមកវិនិយោគនៅក្នុងប្រទេស រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរបានកំពុងអនុវត្តប្រព័ន្ធពន្ធដារដែលមានលក្ខណៈងាយយល់ និងសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចនៃប្រទេសនីមួយៗ ប៉ុន្តែការប្រមូលពន្ធតែងតែមានចំណុចដូចគ្នា និងខុសគ្នាមួយចំនួន អាស្រ័យទៅលើគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលទាំងពីរ។

ជាការពិតណាស់ ការអនុវត្ត និងការប្រមូលពន្ធប្រទេសទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នា។ ទើបមានប្រធានបទមួយលើកឡើងថា **«ការប្រៀបធៀបប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា និងប្រទេសថៃ»** យកមកសិក្សាស្រាវជ្រាវ ដើម្បីរៀបចំសរសេរជាអត្ថបទខ្លីៗសម្រាប់អ្នកសិក្សាស្រាវជ្រាវ។ ដូច្នេះ សូមលើកជាសំណួរពីរដូចខាងក្រោម៖

១.មូលហេតុអ្វីខ្លះដែលបណ្តាលឱ្យការប្រមូលពន្ធនៅប្រទេសកម្ពុជា និងប្រទេសថៃមានភាពខុសគ្នា?

២.តើប្រព័ន្ធពន្ធដារនៃប្រទេសកម្ពុជា និងប្រទេសថៃបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះ ដល់វិនិយោគិន និងសង្គមជាតិ?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យសម្រាប់រៀបរាប់ពីប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរ។ ការប្រមូលទិន្នន័យធ្វើឡើងបានដោយផ្អែកទៅលើឯកសារ ដូចជា Ministry of Finance The Revenue Department, Deloitte The better Cambodia, Orbitax ច្បាប់សារពើពន្ធ លិខិតបទដ្ឋាននៃ អគ្គនាយកពន្ធដារ សៀវភៅសទ្ធានុក្រមពន្ធដារ សៀវភៅសិក្សាគោល មុខវិជ្ជា ច្បាប់ពន្ធដារកម្ពុជា របស់វិទ្យាស្ថាន វ៉ាន់ដា។

សម្រាប់សំណួរស្រាវជ្រាវទី១ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យ ដូចជា សៀវភៅសិក្សាគោល មុខវិជ្ជា ច្បាប់ពន្ធដារកម្ពុជារបស់វិទ្យាស្ថានវ៉ាន់ដា និងស្រាវជ្រាវតាមរយៈគេហទំព័រ Deloitte, The Revenue Department, Orbitax ដើម្បីធ្វើការប្រៀបធៀបជាផលប្រយោជន៍សម្រាប់ក្នុងការយល់ដឹងពីភាពខុសគ្នានៃប្រព័ន្ធដាររបស់ប្រទេសទាំងពីរ។

សម្រាប់សំណួរស្រាវជ្រាវទី២ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យតាមរយៈគេហទំព័រ Deloitte, The better Cambodia ដើម្បីធ្វើការប្រៀបធៀបផលប្រយោជន៍ដែលវិនិយោគិនទទួលបានពីប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរ។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

ប្រៀបធៀប (Comparison) មានន័យថា ការប្រៀបធៀបដែលបង្ហាញពីកម្រិតនៃភាពខុស ឬដូចគ្នានៃរបស់ពីរយ៉ាងដោយប្រើប្រាស់គុណនាម ឬគុណកិរិយាណាមួយ[1]។

ពន្ធ (Tax) សំដៅដល់ពន្ធ និងអាករទាំងឡាយ។ ពាក្យថា "ពន្ធ" គឺសំដៅដល់ការកំណត់បន្ទុកហិរញ្ញវត្ថុជាកំហិតដោយរដ្ឋាភិបាលចំពោះអ្នកជាប់ពន្ធ (រូបវន្តបុគ្គល ឬនីតិបុគ្គល) សម្រាប់ទ្រទ្រង់ ចំណាយរបស់រដ្ឋាភិបាល និងចំណាយលើវិស័យសាធារណៈជាច្រើនប្រភេទ[2]។

ប្រព័ន្ធ (System) សំដៅដល់សំណុំឧបករណ៍កម្មវិធី ឬបរិក្ខារកុំព្យូទ័រដែលត្រូវបានគេរៀបចំ និងប្រើប្រាស់បញ្ចូលគ្នាក្នុងគោលបំណងណាមួយ[3]។

អត្ថប្រយោជន៍ (Benefit) អ្វីៗដែលមានផលប្រយោជន៍ គួរឱ្យចង់បាន[4]។

វិនិយោគិន (Investor) សំដៅដល់បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល។ អ្នកជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលចូលហ៊ុនដោយរំពឹងទទួលត្រលប់មកវិញនូវផល ចំណេញផ្នែកហិរញ្ញវត្ថុ[5]។

១.៣.២ ប្រវត្តិពន្ធដារនៅប្រទេសកម្ពុជា និងប្រទេសថៃ

ក.ប្រវត្តិពន្ធដារនៅប្រទេសកម្ពុជា

ឆ្នាំ១៩៥៣	នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង
ឆ្នាំ១៩៧៥-១៩៧៩	ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់
ឆ្នាំ១៩៨០-១៩៩៣	នាយកដ្ឋានពន្ធដារឧស្សាហកម្ម ពាណិជ្ជ ក្រសួងហិរញ្ញវត្ថុ
ឆ្នាំ១៩៩៣-២០០៨	នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឆ្នាំ២០០៨-បច្ចុប្បន្ន	ដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[6]។

ខ.ប្រវត្តិពន្ធដារនៅប្រទេសថៃ

ឆ្នាំ១៤៤៨	នាយកដ្ឋានរតនាគារបានបង្កើតឡើង
ឆ្នាំ១៨២៤-១៨៥១	ប្រព័ន្ធសម្បទានពន្ធត្រូវអនុម័ត
ឆ្នាំ១៨៥៣-១៩៦០	បានចុះហត្ថលេខាលើសន្ធិសញ្ញា Bowring ជាមួយប្រទេសអង់គ្លេស ដោយបើកប្រទេសថៃឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ និងបានយល់ព្រមផ្តាច់មុខលើទំនិញមួយចំនួន និងអត្រាពន្ធគយថេរ។
ឆ្នាំ១៨៦៨-១៨៧៧	បង្កើតរតនាគារជាភ្នាក់ងារកណ្តាលសម្រាប់ប្រមូលចំណូល

---

[1] Ahladang-អាឡាដាំង (2020.March 30). https://www.facebook.com/ahladangkh/posts/comparison

[2] អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ១៣២

[3] អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ១១០

[4] សង្គ្ហ.(២០២៣).*វចនានុក្រមសង្គ្ហ*. pshtt://www.sangapac.com/dictionary/a/6858

[5] អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ២២៦

[6] វិទ្យាស្ថាន វ៉ាន់ដា.(២០២៤).*ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើទី១ ទំព័រ៣

ឆ្នាំ១៩៣៣-បច្ចុប្បន្ន ប្តូរទៅជាក្រសួងហិរញ្ញវត្ថុ[7]។

២.ការប្រៀបធៀបប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា និងប្រទេសថៃ

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

ការប្រមូលពន្ធក្នុងប្រទេសកម្ពុជា និងប្រទេសថៃមានភាពខុសគ្នានៅក្នុងផ្នែកសំខាន់ៗមួយចំនួន រួមទាំងប្រព័ន្ធពន្ធដារ នីតិវិធីរដ្ឋបាល និងយន្តការអនុវត្តច្បាប់។ នេះជាទិដ្ឋភាពទូទៅនៃភាពខុសគ្នា ដូចខាងក្រោម៖

ប្រទេសកម្ពុជា	ប្រទេសថៃ
ប្រភេទពន្ធ និងអត្រាពន្ធ	
១.ពន្ធលើប្រាក់ចំណូល - អត្រាពន្ធ ២០%សហគ្រាស នីតិបុគ្គល។	**១.ពន្ធលើប្រាក់ចំណូល** - អត្រាពន្ធ ២០%សហគ្រាស នីតិបុគ្គល។
២.ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន - មិនទាន់មាន។	**២.ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន** - អត្រាពន្ធពី0% ដល់ ៣៥% សម្រាប់ចំពោះនិវាសនជន និងអនិវាសនជនដែលទទួលប្រាក់ចំណូលពីប្រទេសថៃ។
៣.ពន្ធលើប្រាក់បៀវត្ស - អត្រាពន្ធពី ០% ដល់ ២០% សម្រាប់និយោជិតនិវាសនជនដែលទទួលប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស - អត្រាពន្ធ ២០% សម្រាប់និយោជិតអនិវាសនជនដែលទទួលប្រាប់បៀវត្សប្រភពកម្ពុជា។	**៣.ពន្ធលើប្រាក់បៀវត្ស** - មិនមាន។
៤.អាករលើតម្លៃបន្ថែម - អត្រាពន្ធ ១០% សម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក និងទំនិញនាំចូល - អត្រាពន្ធ ០% សម្រាប់ការនាំចេញ។	**៤.អាករលើតម្លៃបន្ថែម** - អត្រាពន្ធ ៧% ដែលត្រូវបានអនុវត្តចំពោះទំនិញ និងសេវាកម្ម - អត្រាពន្ធ ០% សម្រាប់ការនាំចេញ។
៥.ពន្ធកាត់ទុទៅ - អត្រាពន្ធ ១៥% សម្រាប់សេវាកម្ម សួយសារការប្រាក់ - អត្រាពន្ធ ១០% សម្រាប់ថ្លៃឈ្នួលចលនទ្រព្យ ឬ អចលនទ្រព្យ - អត្រាពន្ធ ៤% និង៦% សម្រាប់ការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធ។	**៥.ពន្ធកាត់ទុទៅ** - អត្រាពន្ធ ១៥% សម្រាប់ការប្រាក់ - អត្រាពន្ធ ១% សម្រាប់ថ្លៃឈ្នួលអចលនទ្រព្យ - អត្រាពន្ធ ១% សម្រាប់ថ្លៃឈ្នួល - អត្រាពន្ធ ១០% សម្រាប់ភាគលាភ - អត្រាពន្ធ ៣% សម្រាប់សេវាកម្ម

[7] Ministry of Finance. (Saturday, November.2019.30).*History of Thailand's Ministry of Finance.* http://www2.mof.go.th/accessibility/www2history.html.

- អត្រាពន្ធ ១៤% ចំពោះអ្នកជាប់ពន្ធនិវាសនជនដែលមានប្រភពចំណូលកម្ពុជា។	
៦.ពន្ធលើប្រថាប់ត្រា	**៦.ពន្ធលើប្រថាប់ត្រា**
- អត្រាពន្ធ ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ អចលនទ្រព្យជាសំណង់ និងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន - អត្រាពន្ធ ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ - អត្រាពន្ធ ០.១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា - អត្រាពន្ធ ០.១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ - ១លានរៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត រួមមាន លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន និងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា រួមទាំងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយ មូលបត្រសាធារណៈ។	- ១បាត យកលើការជួលដី អាគារ សំណង់ផ្សេងៗ ឬផ្ទះបណ្តែតទឹក - ១បាត យកលើការជួលការងារ កម្ចីប្រាក់ ឬកិច្ចព្រមព្រៀងសម្រាប់ប្រាក់លើសធនាគារ គោលនយោបាយធានារ៉ាប់រង បង្ការនៃដែទំនិញនីមួយៗ បញ្ជាំ បង្ការនៃដែឃ្លាំង ការបញ្ជាទិញដឹកជញ្ជូន - ១បាត និង៥បាត យកលើការផ្ទេរភាគហ៊ុន ប័ណ្ណបំណុល សញ្ញាប័ណ្ណ និងវិញ្ញាបនបត្របំណុលដែលចេញដោយក្រុមហ៊ុន សមាគម ស្ថាប័នបុគ្គល ឬអង្គការណាមួយ - ១បាត និង៥បាតយកលើស្នូន ឬក្លែងបន្លំនៃឧបករណ៍ - ១បាត និង១០បាតយកលើសេចក្តីសម្រេចដែលផ្តល់ដោយអាជ្ញាកណ្តាល - ២បាត យកលើវិក័យប័ត្រ - ៣បាត យកលើមូលប្បទានប័ត្រ ឬការបញ្ជាទិញជាលាយលក្ខណ៍អក្សរដែលប្រើជំនួស មូលប្បទានប័ត្រសម្រាប់ឧបករណ៍នីមួយៗ - ៣បាត យកលើសែកអ្នកធ្វើដំណើរ - ១បាត ៥បាត និង១០បាតយកលើការធានាដែលមានកំណត់នូវចំនួនទឹកប្រាក់ធានា - ១០បាត និង៣០បាតយកលើទីភ្នាក់ងារ - ៥០បាត យកលើមាត្រាថ្មីនៃសមាគម ច្បាប់ចម្លងនៃអនុស្សរណៈនៃការធ្វើវិសោធនកម្មនៃសមាគម ឬមាត្រានៃសមាគមដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន - ៥០បាតនិង១០០បាតយកលើកិច្ចសន្យាជាដៃគូ

	- ២០០បាត យកលើអនុស្សរណៈនៃការរួបរួមរបស់ក្រុមហ៊ុនមានកម្រិតដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន - ២០០បាត យកលើសមាគមនៃក្រុមហ៊ុនមានកំណត់ដាក់ជូនមន្ត្រីអត្រានុកូលដ្ឋាន។
របបពន្ធ	
- ប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ អគ្គនាយកដ្ឋានពន្ធដារ ដែលបែងចែកជាពន្ធផ្ទាល់ និងពន្ធប្រយោល។ - អគ្គនាយកដ្ឋានពន្ធដារ គឺជាទីភ្នាក់ងារប្រមូលពន្ធខ្ពស់បំផុតដែលនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការកិច្ចក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ រៀបចំ អភិវឌ្ឍន៍ប្រព័ន្ធច្បាប់ពន្ធ ការត្រួតពិនិត្យ អនុវត្តច្បាប់ និងផ្តល់សេវាពន្ធដល់សហគ្រាស និងប្រជាពលរដ្ឋ។ - ប្រព័ន្ធពន្ធដារត្រូវបានកំណត់របបពន្ធតែមួយគត់ គឺជារបបស្វ័យប្រកាស ដែលបែងចែកអ្នកជាប់ពន្ធជា៣ប្រភេទ (អ្នកជាប់ពន្ធតូច មធ្យម និងធំ) ដែលអ្នកជាប់ពន្ធមានទំនួលខុសត្រូវក្នុងការធ្វើរបាយការណ៍អំពីប្រាក់ចំណូលរបស់ពួកគេឱ្យបានត្រឹមត្រូវ។ - អ្នកជាប់ពន្ធអាចធ្វើការបង់ប្រាក់ពន្ធតាម ប្រព័ន្ធអនឡាញ (e-Payment System) ដោយចូលទៅកាន់គេហទំព័ររបស់អគ្គនាយកពន្ធដារ និងនៅតាមធនាគារដែលជាដៃគូសហការ។	- ប្រព័ន្ធពន្ធដារប្រទេសថៃត្រូវបានគ្រប់គ្រងដោយក្រសួងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានចំណូលដែលបែងចែកជាពន្ធផ្ទាល់ និងពន្ធប្រយោល។ - នាយកដ្ឋានចំណូល គឺជាទីភ្នាក់ងារប្រមូលពន្ធខ្ពស់បំផុតនៅក្រោមក្រសួងហិរញ្ញវត្ថុ ដែលទទួលខុសត្រូវក្នុងការប្រមូលពន្ធ គ្រប់គ្រង អភិវឌ្ឍន៍ពន្ធតាមវិធាន និងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ពន្ធ។ - ប្រព័ន្ធពន្ធដារត្រូវបានកំណត់ចំណាត់ថ្នាក់សហគ្រាសជាចម្បងមាន សហគ្រាសធំ សហគ្រាសតូច និងមធ្យម (SMEs) - អ្នកជាប់ពន្ធអាចធ្វើការបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញដោយទៅកាន់គេហទំព័ររបស់អគ្គនាយកដ្ឋានចំណូល និងនៅតាមធនាគារជាដៃគូសហការ។
កិច្ចព្រមព្រៀងពន្ធទ្វេដង (DTAs)	
ប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងពន្ធទ្វេភាគី (DTAs) ជាមួយបណ្តារដ្ឋសមាជិកអាស៊ាន រួមទាំងប្រទេសថៃផងដែរ ដើម្បីកែលម្អការប្រមូលពន្ធ ការឆ្លងដែនពាណិជ្ជកម្ម ការវិនិយោគ និងកាត់បន្ថយការយកពន្ធទ្វេដង មានដូចជា៖	ប្រទេសថៃក៏បានចុះកិច្ចព្រមព្រៀងពន្ធទ្វេភាគី (DTAs) ជាមួយប្រទេសមួយចំនួនរួមទាំងកម្ពុជាផងដែរ ដើម្បីសម្រួលដល់ការប្រមូលពន្ធ ការឆ្លងដែនពាណិជ្ជកម្ម ការវិនិយោគ និងកាត់បន្ថយការយកពន្ធទ្វេដង មានដូចជា៖

- ការលុបបំបាត់ការបង់ពន្ធទ្វេដង - ការកំណត់អត្រាពន្ធសម្រាប់ប្រាក់ចំណូល ជាក់លាក់ ដូចជា ប្រាក់ចំណូលពីការចែក ភាគលាភ ការបង់ការប្រាក់ សួយសារ - ការកំណត់ទីតាំងបង់ពន្ធ - ការផ្លាស់ប្តូរព័ត៌មានរដ្ឋបាលពន្ធដារ - ការដោះស្រាយវិវាទពន្ធ - ការជំរុញវិនិយោគ - ការកំណត់អត្រាពន្ធលើប្រាក់ចំណូពីការលក់ទ្រព្យសម្បត្តិ	- ការលុបបំបាត់ការបង់ពន្ធទ្វេដង - ការកំណត់អត្រាពន្ធសម្រាប់ប្រាក់ចំណូល ជាក់លាក់ ដូចជា ប្រាក់ចំណូលពីការចែក ភាគលាភ ការបង់ការប្រាក់ សួយសារ - ការកំណត់ទីតាំងបង់ពន្ធ - ការផ្លាស់ប្តូរព័ត៌មានរដ្ឋបាលពន្ធដារ - ការដោះស្រាយវិវាទពន្ធ - ការជំរុញវិនិយោគ - ការកំណត់អត្រាពន្ធលើប្រាក់ចំណូលពីការលក់ទ្រព្យសម្បត្តិ

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ប្រទេសទាំងបានផ្តល់អត្ថប្រយោជន៍ដល់វិនិយោគិន និងសង្គមជាតិដូចជា៖

អត្ថប្រយោជន៍ដែលប្រទេសកម្ពុជាផ្តល់ឱ្យ វិនិយោគិន និងសង្គមជាតិ	**អត្ថប្រយោជន៍ដែលប្រទេសថៃផ្តល់ឱ្យ វិនិយោគិន និងសង្គមជាតិ**
១.ពន្ធលើប្រាក់ចំណូលសាជីវកម្ម៖ អត្រាពន្ធស្តង់ដា នៅប្រទេសកម្ពុជាគឺ២០% ប៉ុន្តែអាជីវកម្មដែលចូលរួមជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ដែលទទួលបានជាមួយអត្រា0% ។	១.ពន្ធលើប្រាក់ចំណូលសាជីវកម្ម៖ អត្រាពន្ធស្តង់ដានៅប្រទេសថៃគឺ២0% ទោះយ៉ាងណាក៏ដោយ មានការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ឧស្សាហកម្ម និងតំបន់មួយចំនួន។
២.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)៖ ការលើកទឹកចិត្តវិនិយោគិនទាក់ទាញគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) មានសិទ្ធិទទួលបានការលើកទឹកចិត្តជាច្រើន ដូចជា៖ - ការលើកលែងពន្ធលើប្រាក់ចំណូលរហូតដល់9 ឆ្នាំ ឬរំលស់ពិសេស - ការលើកលែងពន្ធលើការនាំចេញ - ការលើកលែងពន្ធទាំងស្រុងលើការនាំចូល (សម្ភារៈសំណង់ សម្ភារៈផ្សេងៗ ធាតុចូលផលិតកម្ម) - ការលើកលែងពន្ធសម្រាប់ធាតុចូលផលិតកម្ម ក្នុងស្រុក	២.ក្រុមប្រឹក្សាកិបាលនៃការវិនិយោគ (BOI)៖ វិនិយោគិនអាចទទួលបានអត្ថប្រយោជន៍ពីថ្ងៃឈប់សម្រាកពន្ធ កាត់បន្ថយអត្រាលើពន្ធប្រាក់ចំណូល និងការលើកទឹកចិត្តផ្សេងទៀតដោយការវិនិយោគ នៅក្នុងសកម្មភាពដែលត្រូវបានលើកកម្ពស់ដោយ BOI - ថ្ងៃឈប់សម្រាកពន្ធលើប្រាក់ចំណូលពី 3 ទៅ 8 ឆ្នាំសម្រាប់អាជីវកម្មដែលមានសិទ្ធិជំរុញការ វិនិយោគ - ការកាត់បន្ថយ ឬការលើកលែងពន្ធនាំចូលលើវត្ថុធាតុដើម និងគ្រឿងចក្រដែលនាំចូលសម្រាប់អាជីវកម្មដែលមានសិទ្ធិជំរុញការ វិនិយោគ ឬ

- ការកាត់ពន្ធ 150% សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ការច្នៃប្រឌិត ការបណ្តុះបណ្តាល សេវកម្ម និងបរិក្ខារនានាដើម្បីសុខុមាលភាពបុគ្គលិក&សេវាកម្ម ការដំឡើងសមត្ថភាពគ្រឿងម៉ាស៊ីន។	ឧស្សាហកម្មដែលបង្កើតឡើងនៅក្នុងតំបន់កែច្នៃនាំចេញ និងតំបន់ពាណិជ្ជកម្មសេរី - ការកាត់ពីរដងសម្រាប់ថ្លៃដឹកជញ្ជូន អគ្គិសនី និងការផ្គត់ផ្គង់ទឹកសម្រាប់ឧស្សាហកម្មដែលមានសិទ្ធិជំរុញការវិនិយោគ - ការកាត់បន្ថយ 200% សម្រាប់ការចំណាយលើការជួលអ្នកស្រាវជ្រាវដែលមានសមត្ថភាពធ្វើគម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍។ - ការកាត់បន្ថយ 150% សម្រាប់ការចំណាយលើការបណ្តុះបណ្តាលបុគ្គលិក ដើម្បីកែលម្អធនធានមនុស្ស។
៣.ការចុះបញ្ជី៖ ការសំណើគម្រោងវិនិយោគត្រូវដាក់ស្នើសុំនិងពិនិត្យតាមរយៈការិយាល័យច្រកចេញចូលតែមួយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ ប្រសិនបើវិស័យរបស់គម្រោងវិនិយោគដែលបានស្នើឡើងមិនស្ថិតនៅក្នុង "បញ្ជីហាមឃាត់" នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងចេញវិញ្ញាបនប័ត្រចុះបញ្ជីគម្រោងវិនិយោគក្នុងរយៈពេល ២០ថ្ងៃធ្វើការ។	៣.ការចុះបញ្ជី៖ ក្រុមហ៊ុនបរទេសដែលធ្វើអាជីវកម្មនៅក្នុងប្រទេសថៃ មិនថាបង្កើតសាខា ឬការិយាល័យ ត្រូវដាក់ពាក្យសុំលេខអត្តសញ្ញាណពន្ធពីនាយកដ្ឋានចំណូល។ ទម្រង់ពាក្យសុំ (ឡ.ប.១០.៣) រួមជាមួយនឹងឯកសារពាក់ព័ន្ធផ្សេងទៀត ដូចជា ច្បាប់ចម្លងអាជ្ញាប័ណ្ណចុះបញ្ជីក្រុមហ៊ុន ការចុះបញ្ជីផ្ទះជាដើម ត្រូវដាក់ជូនការិយាល័យចំណូលតំបន់ក្នុងរយៈពេល ៦០ថ្ងៃ សម្រាប់កាលបរិច្ឆេទនៃការចុះឈ្មោះ ឬប្រតិបត្តិការ។
៤.កិច្ចព្រមព្រៀងពន្ធទ្វេភាគី (DTAs)៖ ប្រទេសកម្ពុជាមាន (DTAs) ជាមួយប្រទេសផ្សេងៗ ដែលកាត់បន្ថយហានិភ័យនៃការយកពន្ធទ្វេភាគីសម្រាប់វិនិយោគិន។	៤.កិច្ចព្រមព្រៀងពន្ធទ្វេភាគី (DTAs)៖ ប្រទេសថៃមាន (DTAs) ជាមួយប្រទេសផ្សេងៗ ដែលកាត់បន្ថយហានិភ័យនៃការយកពន្ធទ្វេភាគីសម្រាប់វិនិយោគិន។
៥.ពន្ធកាត់ទុក អនុវត្តចំពោះថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ ភាគលាភ ការប្រាក់ សួយសារ និងថ្លៃសេវាបច្ចេកទេស ជាមួយនឹងអត្រាផ្សេងៗគ្នា អត្រាពន្ធជាទូទៅចន្លោះពី(១០%-១៥%)	៥.ពន្ធកាត់ទុក អនុវត្តចំពោះថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ ភាគលាភ ការប្រាក់ សួយសារ និងថ្លៃសេវាបច្ចេកទេស ជាមួយនឹងអត្រាផ្សេងៗគ្នា អត្រាពន្ធជាទូទៅចន្លោះពី(១០%-១៥%)
៦.ពន្ធអប្បបរមា៖ ត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តដល់សហគ្រាសដែលកាន់កាប់បញ្ជីកាគណនេយ្យត្រឹមត្រូវ មានអត្រាពន្ធ១% នេះគឺផ្អែកលើចំណូល (មិនរាប់បញ្ចូលអាករលើតម្លៃបន្ថែម) សូម្បីតែក្នុងអំឡុងពេលនៃប្រាក់ចំណេញទាបដ៏ដោយ។	៦.ការកាត់បន្ថយពន្ធ៖ អាជីវកម្មអាចកាត់កងការចំណាយទាក់ទងនឹងការស្រាវជ្រាវ និងការអភិវឌ្ឍ ការបណ្តុះបណ្តាល និងសកម្មភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀត។

៧.អាករលើតម្លៃបន្ថែម៖ អនុវត្តលើការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ដែលមានអត្រាអាករស្តង់ដា១០% ប៉ុន្តែនៅក្នុងវិស័យឧស្សាហកម្មវាយនកណ្ឌ ស្បែកជើង និងកាត់ដេរ អាចមានលក្ខណៈគ្រប់គ្រាន់ សម្រាប់អត្រាអាករលើតម្លៃបន្ថែម០%។	៧.អត្ថប្រយោជន៍សង្គម៖ ទោះបីជាមិនទាក់ទងដោយផ្ទាល់ទៅនឹងពន្ធក៏ដោយ ប្រទេសថៃផ្តល់អត្ថប្រយោជន៍សង្គម ដូចជា ការថែទាំសុខភាព ការអប់រំ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។
៨.អត្ថប្រយោជន៍សង្គម៖ គឺចូលរួមចំណែកក្នុងការអភិវឌ្ឍលើគ្រប់វិស័យ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ ចំណាយទូទៅ សង្គមកិច្ច សេដ្ឋកិច្ច និងអភិវឌ្ឍន៍។	

៣. សន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវខាងលើរួចមក សង្កេតឃើញថា ប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរពិតជាមានភាពស្រដៀងគ្នា និងភាពខុសគ្នាជាច្រើន ដូចខាងក្រោម៖

កត្តានៃភាពខុសគ្នា

- អត្រាពន្ធអាករ
- ការគ្រប់គ្រងប្រព័ន្ធបង់ពន្ធ
- ការតាមដាន និងការអនុវត្តទៅលើការបង់ពន្ធ

កត្តានៃភាពស្រដៀងគ្នា

- ប្រភេទពន្ធអាករ
- ប្រព័ន្ធពន្ធអាករ
- គោលដៅសំខាន់នៃការប្រមូលពន្ធ
- ការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក
- ការលើកកម្ពស់ការវិនិយោគ ដើម្បីជួយដល់កំណើនសេដ្ឋកិច្ចប្រទេសទាំងពីរ
- បន្តការអភិវឌ្ឍប្រព័ន្ធពន្ធដារឱ្យប្រសើរឡើង ដើម្បីសម្រួលដល់ការបង់ប្រាក់ពន្ធ។

ប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរគឺ មានភាពខុសគ្នានៅក្នុងផ្នែកសំខាន់ៗមួយចំនួន ដូចជា ការគ្រប់គ្រងប្រព័ន្ធពន្ធដារ នីតិវិធីរដ្ឋបាល យន្តការអនុវត្តច្បាប់ ការប្រមូលពន្ធ ប្រភេទពន្ធ អត្រាពន្ធ និងរបបពន្ធ។ សរុបជារួម ប្រព័ន្ធពន្ធដារនៃប្រទេសទាំងពីរពិតជាមានភាពស្រដៀងគ្នា និងភាពខុសគ្នាជាច្រើនតាមរយៈការគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធពន្ធដារ។

ឯកសារយោង

១. អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ១៣២

២. អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ១១០

៣. អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*សន្ធានុក្រមពន្ធដារ* បោះពុម្ពលើកទី១ ទំព័រ២២៦

៤. វិគីនានុក្រម វចនានុក្រមសេរី.(2019.April.25). https://km.wiktionary.org/wiki/

៥. សង្គ្ហ.(២០២៣).*វចនានុក្រមសង្គ្ហ*. https://www.sangapac.com/dictionary/a/6858

៦. វិគីនានុក្រម វចនានុក្រមសេរី.(2017.July.11). https://km.wiktionary.org/wiki/

៧. វិទ្យាស្ថាន វ៉ាន់ដា.(២០២៤).*ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើទី១ ទំព័រ៣ សរុប១៨៨ទំព័រ

៨ Ministry of Finance. (Saturday, November.2019.30). *History of Thailand's Ministry of Finance.* http://www2.mof.go.th/accessibility/www2history.html.

៩.The Revenue Department. (December 05,2020). About Us | The Revenue Department (English Site) (rd.go.th)

១០. Deloitte. (2020).*Tax Guide to taxation in Cambodia*. https://www2.deloitte.com

១១. Orbitax. (January 1,2018). Update-Tax Treaty between Cambodia and Thailand has Entered into Force- Orbitax Tax News & Alerts

១២. The better Cambodia. (March 20,2024). Surya Narayan. Cambodia's Evolving Tax Landscape
https://thebettercambodia.com/cambodias-evolving-tax-landscape-a-guide-for-businesses-and-investors/

ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា
The Growth of Digital Banking in Cambodia

យ៉ាក ឈុន្នី
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម និងគ្រប់គ្រងអាជីវកម្ម
ប្រធានអាសនៈហិរញ្ញវត្ថុ និងធនាគារ

មូលន័យសង្ខេប

គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺស្វែងយល់ពីអត្ថប្រយោជន៍ដែលអ្នកប្រើប្រាស់ទទួលបាន និងកត្តាជះឥទ្ធិពលដល់សេដ្ឋកិច្ចជាតិនៅពេលមានការរីកចម្រើននៃធនាគារឌីជីថល។ ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានបង្កើនការយល់ដឹងដល់អ្នកប្រើប្រាស់ទៅលើការប្រតិបត្តិការហិរញ្ញវត្ថុបានយ៉ាងឆាប់រហ័ស ចំណេញពេលវេលា ជួយលើកស្ទួយកិច្ចការវិនិយោគ និងកិច្ចការពាណិជ្ជកម្មអេឡិចត្រូនិកជាដើម។ បន្ថែមពីនេះ ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋ ការអភិវឌ្ឍបច្ចេកវិទ្យា ការលើកស្ទួយសេដ្ឋកិច្ចឯកជន និងអាជីវកម្មខ្នាតតូចជាដើម។ ការស្រាវជ្រាវនេះ បានធ្វើឡើងតាមរយៈការប្រមូលទិន្នន័យដំបូង (Primary Data) និងទិន្នន័យបន្ទាប់បន្សំ(Secondary Data)។

ការប្រមូលទិន្នន័យដំបូង(Primary Data) ត្រូវបានរៀបចំឡើងតាមរយៈការបង្កើតនូវកម្រងសំណួរស្ទង់មតិពីនិស្សិតដែលកំពុងសិក្សានៅវិទ្យាស្ថាន វ៉ាន់ដា ដោយប្រើប្រាស់បែបគុណវិស័យសម្រាប់បរិយាយពីចំនួនអ្នកប្រើប្រាស់ និងបែបបរិមាណវិស័យសម្រាប់បរិយាយពីអត្ថប្រយោជន៍ដែលអ្នកប្រើប្រាស់ និងសេដ្ឋកិច្ចទទួលបានពីការរីកចម្រើននៃធនាគារឌីជីថល។ ការវិភាគទិន្នន័យ(Data Analysis) ត្រូវធ្វើឡើងតាមបែបសន្និដ្ឋាន គឺធ្វើការប្រៀបធៀបរកភាពខុសគ្នារវាងអ្នកប្រើប្រាស់សេវាកម្មធនាគារពីអតីតកាល (២ឆ្នាំមុន)និងការប្រើប្រាស់សេវាកម្មធនាគារនាបច្ចុប្បន្ន។ ចំណែកឯការប្រមូលទិន្នន័យបន្ទាប់បន្សំ(Secondary Data) បានមកពីរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា មជ្ឈមណ្ឌលកម្ពុជា៤.០ និងអត្ថបទខ្លីៗពីគេហទំព័រមួយចំនួនពាក់ព័ន្ធនឹងសំណួរដែលបានចោទសួរ។ ការវិភាគទិន្នន័យ(Data Analysis) គឺធ្វើឡើងតាមរយៈការសំយោគឯកសារដែលបានមកពីប្រភពខាងលើទៅនឹងប្រធានបទ និងសំណួរចោទសួរ ដើម្បីសន្និដ្ឋានជារួម។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ទោះបីការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា មានគុណវិបត្តិខ្លះ ក៏ពិតមែន ប៉ុន្តែបានផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាច្រើន ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយភាពងាយស្រួល សុវត្ថិភាព និងជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានភាពទាន់សម័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

១. សេចក្តីផ្តើម

វិស័យហិរញ្ញវត្ថុនៅកម្ពុជារួមមាន វិស័យធនាគារ វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ មានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីផ្តល់សេវាកម្មហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និងដើម្បីឆ្លើយតបទៅនឹងតម្រូវការថ្មីៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនោះវិស័យធនាគារបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការជួយសម្រួលដល់ប្រតិបត្តិការទូទាត់ក្នុងចរន្តសេដ្ឋកិច្ច និងជួយលើកកម្ពស់ការវិនិយោគក្នុងស្រុក និងក្រៅស្រុក។ មិនតែប៉ុណ្ណោះវិស័យធនាគារនៅកម្ពុជា បានអភិវឌ្ឍយ៉ាងឆាប់រហ័សពីធនាគារប្រពៃណីទៅកាន់ធនាគារឌីជីថលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យោងតាមរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា បានបង្ហាញថា វិស័យធនាគារនៅកម្ពុជានាពេលបច្ចុប្បន្ន ធនាគារពាណិជ្ជមានចំនួន៥៩ ធនាគារឯកទេសមានចំនួន៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានចំនួន៨៣ បានពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការផ្សព្វផ្សាយពីប្រព័ន្ធបាគង និងការលើកកម្ពស់ប្រាក់រៀល(រ) តាមរយៈការអនុវត្តជាមួយភាគីពាក់ព័ន្ធ ដូចជា ការរៀបចំសិក្ខាសាលា ការតាំងពិព័រណ៍ផ្សេងៗនៅតាមទីសាធារណៈ ដែលបានបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់ឌីជីថល និងសារៈសំខាន់នៃការប្រើប្រាស់រូបិយវត្ថុជាតិ។

បច្ចុប្បន្នការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល បានជួយសម្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើការងារ និងជីវិតរស់នៅប្រចាំថ្ងៃក្នុងការប្រតិបត្តិការហិរញ្ញវត្ថុបានយ៉ាងឆាប់រហ័ស ចំណាយតិច និងមានសុវត្ថិភាពខ្ពស់។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យធនាគារ អាចឱ្យអ្នកប្រើប្រាស់ប្រតិបត្តិការហិរញ្ញវត្ថុក្នុងទម្រង់ឌីជីថល ដែលសកម្មភាពបែបនេះគេហៅថា ធនាគារឌីជីថល។ ធនាគារឌីជីថលបានវិត្តខ្លួនតាំងពីការចាប់ផ្តើមដាក់ឱ្យប្រើប្រាស់ទូម៉ាស៊ីនATM នៅឆ្នាំ១៩៦៧ជាលើកដំបូង រហូតដល់មានវត្តមាននៃសេវាធនាគារតាមផ្ទះ សេវាធនាគារតាមអ៊ីនធឺណិត សេវាធនាគារតាមគេហទំព័រ និងកម្មវិធីសេវាធនាគារចល័តដែលកំពុងពេញនិយមនាពេលបច្ចុប្បន្ន ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទទួលបានសេវាកម្មក្នុងទម្រង់ឌីជីថល ដូចជា ការទាញយករបាយការណ៍ហិរញ្ញវត្ថុធនាគារ ការដកសាច់ប្រាក់ ការផ្ទេរប្រាក់ ការគ្រប់គ្រងគណនី ការបើកគណនីប្រាក់បញ្ញើ ការគ្រប់គ្រងប្រាក់កម្ចី ការទូទាត់វិក្កយបត្រ ការស្នើសុំកាតនិម្មិត និងការត្រួតពិនិត្យគណនីជាដើម។

ដោយមើលឃើញពីអត្ថប្រយោជន៍ពីការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា ទើបមានសំណួរពីរលើកឡើងថា៖

១. តើការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់អ្នកប្រើប្រាស់?

២. តើការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានផ្តល់សារៈសំខាន់អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងពីរខាងលើ ការស្រាវជ្រាវនេះបានធ្វើឡើងតាមរយៈការប្រមូលទិន្នន័យពីរប្រភេទ គឺទិន្នន័យដំបូង(Primary Data) និងទិន្នន័យបន្ទាប់បន្សំ(Secondary Data)។

ការប្រមូលទិន្នន័យដំបូង(Primary Data) ត្រូវបានរៀបចំឡើងតាមរយៈការបង្កើតនូវកម្រងសំណួរស្ទង់មតិពីនិស្សិតដែលកំពុងសិក្សានៅវិទ្យាស្ថាន វ៉ាន់ដា ទីតាំងគោលមានចំនួន៩១នាក់ ក្នុងនោះនិស្សិតស្រីមានចំនួន៨៦.៨% ប្រុសចំនួន១៣.២% សិក្សាជំនាញគណនេយ្យចំនួន៧៣.៦% និងជំនាញហិរញ្ញវត្ថុ និងធនាគារចំនួន២៦.៤% កំពុងសិក្សានៅឆ្នាំទី៣ ឆមាសទី២ ដោយប្រើប្រាស់បែបគុណវិស័យសម្រាប់បរិយាយពីចំនួនអ្នកប្រើប្រាស់ និងបែបបរិមាណវិស័យសម្រាប់បរិយាយពីអត្ថប្រយោជន៍ដែលអ្នកប្រើប្រាស់ និងសេដ្ឋកិច្ចទទួលបានពីការរីកចម្រើននៃធនាគារឌីជីថល។ ការវិភាគទិន្នន័យ(Data Analysis) ត្រូវធ្វើឡើងតាមបែបសន្និដ្ឋាន គឺធ្វើការប្រៀបធៀបរកភាពខុសគ្នារវាងអ្នកប្រើប្រាស់សេវាកម្មធនាគារពីអតីតកាល(២ឆ្នាំមុន) និងការប្រើប្រាស់សេវាកម្មធនាគារនាពេលបច្ចុប្បន្ន។

ការប្រមូលទិន្នន័យបន្ទាប់បន្សំ (Secondary Data) បានមកពីរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤របស់ធនាគារជាតិនៃកម្ពុជា អត្ថបទសិក្សាស្តីពីបច្ចេកវិទ្យា និងធនាគារឌីជីថលនៅកម្ពុជារបស់មជ្ឈមណ្ឌលកម្ពុជា៤.០ និងគេហទំព័រមួយចំនួន ដូចជា https://sdk.finance/what-is-digital-banking/, https://kms-solutions.asia/blogs/digital-banking-development, https://hyperverge. co/blog /digital-banking-meaning-benefits-types/។ ការវិភាគទិន្នន័យបន្ទាប់បន្សំ គឺធ្វើឡើងតាមរយៈការសំយោគឯកសារបានមកពីប្រភពខាងលើទៅនឹងប្រធានបទ និងសំណួរដែលបានចោទសួរដើម្បីសន្និដ្ឋានជារួម។

១.៣ ការស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

ធនាគារឌីជីថល (Digital Banking) សំដៅដល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងសេវាកម្ម ជាមួយធនាគារក្នុងទម្រង់ឌីជីថល ដោយជំនួសនូវការធ្វើប្រតិបត្តិការតាមបែបប្រពៃណី ដែលតម្រូវឱ្យអតិថិជនធ្វើដំណើរទៅធនាគារ[1]។

ធនាគារប្រពៃណី (Traditional Banking) សំដៅដល់ស្ថានភាពដែលអតិថិជនត្រូវទៅធ្វើប្រតិបត្តិការសេវាកម្មធនាគារដោយផ្ទាល់[2]។

ប្រព័ន្ធបាគង ឬបាគង (Bakong) ជាប្រព័ន្ធទូទាត់បែបទំនើបថ្មីមួយ ដោយតភ្ជាប់ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្តល់សេវាទូទាត់នៅកម្ពុជា ដើម្បីអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈកម្មវិធីទូរសព្ទ ពីធនាគារមួយទៅធនាគារមួយទៀត ឬពីក្រុមហ៊ុនផ្តល់សេវាទូទាត់ណាមួយទៅសមាជិកដទៃទៀត ជាមួយនឹងភាពងាយស្រួល ឆាប់រហ័ស សុវត្ថិភាព និងចំណាយតិច[3]។

បច្ចេកវិទ្យាឌីជីថល (Digital Technology) សំដៅលើបច្ចេកវិទ្យាដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងធនធានគណនាសម្រាប់បង្កើត ផ្ទុកបំប្លែង និងវិភាគទិន្នន័យ[4]។

---

[1] មជ្ឈមណ្ឌលកម្ពុជា៤.០. (២០២៤). *កម្ពុជា៤.០*. Retrieved ធ្នូ ១៣, ២០២៤, from https://cambodia4point0. org/kh/Digital Banking 06012023

[2] Kekcent. (2020, April 27). *News & media website*. Retrieved December 13, 2024, from https://www.facebook.com/kakcentkh/

[3] Bakong. (2019, December 06). *Financial service*. Retrieved December 13, 2024, from https://www.facebook.com/ bakongsystem/ posts

[4] សាលាឌីជីថល. (n.d.). *@saladigital*. Retrieved December 13, 2024, from https://sala.moeys.gov.kh/kh/ contents

បច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology) សំដៅដល់បណ្តាធុរកិច្ចទាំងឡាយណាដែលប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់ ឬធ្វើស្វ័យប្រវត្តិកម្មលើសេវាកម្មហិរញ្ញវត្ថុ និងគ្រប់ទម្រង់ការ[5]។

បញ្ញាសិប្បនិម្មិត AI (Artificial Intelligence) សំដៅលើជ្រុងមួយនៃវិទ្យាសាស្ត្រកុំព្យូទ័រ ផ្តោតលើការបង្កើតសុសវែរកម្មវិធី ឬឧបករណ៍ដែលមានសមត្ថភាពអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន ឬធ្វើសកម្មភាពជំនួសមនុស្សបាន[6]។

១.៣.២ ប្រវត្តិនៃធនាគារឌីជីថល

ធនាគារឌីជីថល ត្រូវបានគេស្គាល់ផងដែរថា ជាធនាគារតាមអ៊ីនធឺណិត ឬ E-banking សំដៅលើការផ្តល់សេវាហិរញ្ញវត្ថុតាមរយៈបណ្តាញឌីជីថល ដូចជា អ៊ីនធឺណិត ឧបករណ៍ចល័ត និងម៉ាស៊ីនប្រាប់ដោយស្វ័យប្រវត្តិ។ ធនាគារឌីជីថលបានក្លាយជាការពេញនិយមកាន់តែខ្លាំងឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ខាងក្រោមនេះជាប្រវត្តិសង្ខេបនៃធនាគារឌីជីថល៖

- ស្វ័យប្រវត្តិកម្មដំបូង (1960s ដល់ 1980s)

ទម្រង់ដំបូងនៃធនាគារឌីជីថលអាចត្រូវបានគេតាមដាននៅទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលដែលធនាគារបានចាប់ផ្តើមប្រើប្រាស់កុំព្យូទ័រមេ ដើម្បីធ្វើស្វ័យប្រវត្តិកម្មមុខងារធនាគារផ្សេងៗ ដូចជា ដំណើរការមូលប្បទានបត្រ និងការគ្រប់គ្រងគណនីអតិថិជន។ នៅទសវត្សរ៍ឆ្នាំ១៩៨០ ធនាគារបានចាប់ផ្តើមផ្តល់សេវាហៅតាមទូរសព្ទ ដែលអនុញ្ញាតឱ្យអតិថិជនចូលប្រើគណនីរបស់ពួកគេតាមរយៈកុំព្យូទ័រនៅផ្ទះរបស់ពួកគេ។

ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ធនាគារ Bank of America បានណែនាំម៉ាស៊ីនស្វ័យប្រវត្តិ(ATM) ដំបូងដែលអនុញ្ញាតឱ្យអតិថិជនដកសាច់ប្រាក់ចេញពីគណនីរបស់ពួកគេ ដោយមិនចាំបាច់មានអ្នកប្រាប់ពីធនាគារ។ ដូចគ្នានេះផងដែរ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ធនាគារ Citibank បានណែនាំប្រព័ន្ធធនាគារអនឡាញដំបូងគេដែលអនុញ្ញាតឱ្យអតិថិជនចូលប្រើព័ត៌មានគណនី និងធ្វើប្រតិបត្តិការជាមូលដ្ឋានតាមរយៈការតភ្ជាប់តាមទូរសព្ទ។

- ការណែនាំអំពីធនាគារអនឡាញ (ទសវត្សរ៍ឆ្នាំ1990 ដល់ឆ្នាំ 2000)

ផតថលធនាគារតាមអ៊ីនធឺណិត (Online banking portals) ត្រូវបានបង្កើតឡើងដោយសារតែការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងឆ្នាំ២០០០។ ធនាគារបានចាប់ផ្តើមបង្កើតផតថលអនឡាញ ដើម្បីឱ្យអ្នកប្រើប្រាស់មើលឃើញសមតុល្យគណនី ផ្ទេរប្រាក់ និងបង់រំកិលយបត្រពីកុំព្យូទ័រនៅផ្ទះរបស់ពួកគេ។ ធនាគារតាមអ៊ីនធឺណិតបានក្លាយទៅជាជម្រើសដ៏ពេញនិយមសម្រាប់មនុស្សជាច្រើនយ៉ាងឆាប់រហ័ស ដោយសារតែភាពងាយស្រួលរបស់វា។

ឧទាហរណ៍ ក្នុងឆ្នាំ១៩៩៤ សហភាពឥណទានសហព័ន្ធ Stanford បានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុដំបូងគេដែលផ្តល់សេវាធនាគារតាមអ៊ីនធឺណិតដល់សមាជិករបស់ខ្លួន ហើយនៅឆ្នាំ១៩៩៦ Wells Fargo បានក្លាយជាធនាគារដំបូងគេដែលផ្តល់សេវាធនាគារតាមអ៊ីនធឺណិតដល់អតិថិជនរបស់ខ្លួន។

---

[5] សហការី. (២០២០, តុលា ០៥). *នគរវត្ត*. Retrieved ធ្នូ ១៣, ២០២៤, from http://nokorwatnews.com/archives/1028430

[6] Semtararath. (2024, May 08). *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍*. Retrieved December 2024, 2024, from https://mptc.gov.kh/2024

- សេវាធនាគារចល័ត (2000s ដល់បច្ចុប្បន្ន)

ការរីកសាយនៃទូរស័ព្ទទំនើបនៅចុងទសវត្សរ៍ឆ្នាំ២០០០ និងដើមទសវត្សរ៍ឆ្នាំ២០១០ បាននាំឱ្យមានការលេចឡើងនៃសេវាធនាគារចល័ត។ ធនាគារបានចាប់ផ្តើមផ្តល់ជូននូវកម្មវិធីទូរស័ព្ទដែលអនុញ្ញាតឱ្យអតិថិជនចូលប្រើគណនីរបស់ពួកគេពីស្មាតហ្វូនរបស់ពួកគេ ដោយអនុញ្ញាតឱ្យពួកគេពិនិត្យមើលសមតុល្យគណនី ផ្ទេរប្រាក់ និងបង់រំក្ដុយបត្រនៅពេលធ្វើដំណើរ។ សព្វថ្ងៃនេះ ធនាគារចល័តបានក្លាយទៅជាផ្នែកសំខាន់មួយនៃទិដ្ឋភាពធនាគារឌីជីថល[7]។

២. ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

នៅពេលប្រព័ន្ធធនាគារឌីជីថលនៅកម្ពុជាកាន់តែរីកចម្រើន និងចូលទីផ្សារកាន់តែច្រើន ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មដែលជាអ្នកប្រើប្រាស់ក្នុងការទទួលបាននូវឱកាសជោគជ័យ ភាពងាយស្រួលសម្រាប់សកម្មភាពក្នុងការរស់នៅ ការធ្វើប្រតិបត្តិការអាជីវកម្មឱ្យកាន់តែប្រសើរជាងការប្រើប្រាស់ប្រព័ន្ធធនាគារបែបប្រពៃណី។ ដូចនេះ ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់ ដូចខាងក្រោម៖

- ការកាត់បន្ថយចំណាយ(Cost Savings)៖ មុនពេលមានធនាគារឌីជីថលរាល់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់របស់ធនាគារប្រពៃណី តម្រូវឱ្យអ្នកប្រើប្រាស់ធ្វើដំណើរទៅកាន់ទីតាំងផ្ទាល់ ដែលត្រូវចំណាយពេល និងថវិកាក្នុងការធ្វើដំណើរ ហើយរាល់ពេលមានប្រតិបត្តិការ ដូចជា ការផ្ទេរប្រាក់ពីធនាគារមួយទៅកាន់ធនាគារមួយទៀត ត្រូវបង់ថ្លៃសេវា និងប្រើពេលយូរ។ ជាក់ស្តែង នៅពេលមានការរីកចម្រើននៃធនាគារឌីជីថល បានជួយដល់ការកាត់បន្ថយចំណាយ និងពេលវេលាជាច្រើន ពិសេសថ្លៃសេវាពេលមានការផ្ទេរប្រាក់ ឬទូទាត់ចំណាយតាមរយៈការប្រើប្រាស់ QR Code KHQR ។
- ការបង្កើនប្រសិទ្ធភាព និងភាពងាយស្រួល(Increased Efficiency and Convenience)៖ ធនាគារឌីជីថលបានផ្តល់នូវភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដែលមិនអាចប្រៀបផ្ទឹមបាន ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់(អតិថិជន)ធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានគ្រប់ទីកន្លែង គ្រប់ពេលវេលា ប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះផងដែរ រាល់ប្រតិបត្តិការហិរញ្ញវត្ថុនឹងបង្ហាញនៅលើគណនីរបស់អ្នក ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចគ្រប់គ្រងបានគ្រប់ពេលវេលាគ្រប់ប្រតិបត្តិការបានយ៉ាងត្រឹមត្រូវផងដែរ។

[7] Alicr Ivey (2023, APril 20). *cointelegraph*. Retrieved December 13, 2024, from https://cointelegraph.com/news/a-brief-history-of-digital-banking

- ភាពប្រសើរឡើងនៃការប្រើប្រាស់ (Improved Usability)៖ អ្នកប្រើប្រាស់ និងធនាគារឌីជីថល អាចបើកគណនីពីឧបករណ៍ដែលអាចប្រើអ៊ីនធឺណិតបាន ក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ ធនាគារឌីជីថលអាចបម្រើសេវាជូនអតិថិជនបានយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ដោយសារប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណ និងការវាយតម្លៃហានិភ័យ ដែលអនុញ្ញាតឱ្យអតិថិជនមិនមែនជាធនាគារអាចទទួលបានសេវាហិរញ្ញវត្ថុ។
- បង្កើនភាពឯកត្តជន (Increased Individualization)៖ ធនាគារឌីជីថលអនុញ្ញាតឱ្យមានយុទ្ធសាស្ត្រកំណត់បុគ្គលដ៏ទំនើប ដែលដំណើរការដោយបញ្ញាសិប្បនិម្មិត Artificial Intelligence (AI) និងការធ្វើបដិរូបកម្មតាមម៉ាស៊ីនរៀនសូត្រ Machine Learning (ML) គឺអាចធ្វើទៅបានដោយកម្មវិធីធនាគារឌីជីថល។ ធនាគារអាចផ្តល់ជូនអតិថិជននូវជម្រើសហិរញ្ញវត្ថុពាក់ព័ន្ធឧបករណ៍អន្តរកម្ម និងធនធានអប់រំនៅពេលត្រឹមត្រូវ។ ការរៀបចំថវិកាដោយស្វ័យប្រវត្តិ ការវិភាគការចំណាយ ការរំលឹក ការសន្សំ និងឧបករណ៍ជាច្រើនទៀតជួយជូនដំណឹង និងចូលរួមជាមួយអតិថិជន។
- លក្ខណៈពិសេសអស្ចារ្យ(Wow-Features)៖ ធនាគារឌីជីថលមានលក្ខណៈពិសេសជាច្រើនរួចទៅហើយដែលធនាគារបានបង្កើតឡើង គ្រាន់តែមិនអាចផ្តល់ជូន ដូចជា ការវិនិយោគលើទីផ្សារភាគហ៊ុនដោយផ្ទាល់នៅក្នុងកម្មវិធីធនាគារ។
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកំណត់ផ្ទាល់ខ្លួន (Financial Control and Personalization)៖ សេវាកម្មធនាគារឌីជីថល ទាំងតាមរយៈសេវាធនាគារចល័ត និងធនាគារតាមអ៊ីនធឺណិត អនុញ្ញាតឱ្យអ្នកមានការគ្រប់គ្រងពេញលេញលើប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់អ្នក។ ចាប់ផ្តើមពីការសន្សំ ការផ្ទេរ ការដកប្រាក់ ការទូទាត់ ការវិនិយោគអាចត្រូវបានធ្វើឡើងនៅក្នុងពេលវេលាជាក់ស្តែង។ អតិថិជនអាចគ្រប់គ្រង ចូលប្រើ និងទទួលបានការផ្តល់ជូនសេវាកម្មធនាគារដែលសមស្របទៅនឹងតម្រូវការរបស់ពួកគេបំផុត។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា មានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាតិ ដូចខាងក្រោម៖

- ការកែលម្អបរិយាកាសសេដ្ឋកិច្ច (Improving the economic environment)៖ ការរីកចម្រើននៃធនាគារឌីជីថលបានជួយសម្រួលនីតិវិធីហិរញ្ញវត្ថុ និងធ្វើឱ្យការចុះបញ្ជីអាជីវកម្ម និងប្រតិបត្តិការឱ្យមានភាពងាយស្រួលជាងមុន។ លក្ខណៈសំខាន់គឺ លើកស្ទួយបរិយាកាសពាណិជ្ជកម្ម និងទាក់ទាញវិនិយោគិនពីក្រៅប្រទេស។
- ការកែលម្អប្រសិទ្ធភាពរបស់ប្រព័ន្ធធនាគារ(Improving the efficiency of the banking system)៖ ធនាគារឌីជីថលអាចធ្វើការទូទាត់ និងប្រតិបត្តិការទាំងអស់បានយ៉ាងរហ័ស និងមានប្រសិទ្ធភាពដោយបញ្ចុះការចំណាយនៃការប្រើប្រាស់ធនធាន និងពេលវេលាការងារ។ នេះអាចជួយដល់ការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិដោយធ្វើឱ្យមានកំណត់ការប្រកបអាជីវកម្មដែលមានសក្តានុពលល្អ។

- ការពង្រីកការចូលរួមដំណើរការលើសេវាកម្មធនាគារ (Expanding participation in banking services)៖ ប្រព័ន្ធធនាគារឌីជីថល អាចឱ្យអ្នកប្រើប្រាស់មានភាពងាយស្រួលក្នុងការចូលរួមដំណើរការនូវសេវានានារបស់ធនាគារ ទោះបីជាការកំណត់ទីកន្លែង ឬទីតាំងក៏ដោយ។ នេះអាចជួយពង្រីកការចូលរួមដំណើរការរបស់មនុស្សជាច្រើន ដែលធ្វើឱ្យមានប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ។
- បង្កើនប្រសិទ្ធភាពក្នុងការត្រួតពិនិត្យវិបត្តិសេដ្ឋកិច្ច(Increase efficiency in monitoring economic crises)៖ ប្រព័ន្ធធនាគារឌីជីថលអាចជួយឱ្យរដ្ឋាភិបាល និងធនាគារកណ្តាលធ្វើការត្រួតពិនិត្យវិបត្តិសេដ្ឋកិច្ច ឬកំណត់មូលដ្ឋានទិន្នន័យដែលអាចអនុវត្តបានក្នុងការពិនិត្យប្រកបដោយប្រសិទ្ធភាពនៃវិធានការតំបន់ និងឧស្សាហកម្ម។
- បង្កើនឱកាសការងារ និងការអភិវឌ្ឍបច្ចេកវិទ្យា (Increase job opportunities and technological development)៖ ការរីកចម្រើននៃធនាគារឌីជីថលអាចបង្កើតឱកាសការងារថ្មីៗក្នុងវិស័យបច្ចេកវិទ្យា ការប្រើប្រាស់ព័ត៌មាន ការវិភាគព័ត៌មាន និងការផ្តល់សេវាធនាគារឌីជីថលជាដើម។ នេះអាចជួយសម្រួលការអភិវឌ្ឍគ្រប់វិស័យការប្រើប្រាស់សេវាឌីជីថលទូទៅ។
- ការប្រមូលការវិនិយោគ និងគាំទ្រដល់វិស័យសេដ្ឋកិច្ចថ្មី (Attracting investment and supporting new economic sectors)៖ ការរីកចម្រើននៃធនាគារឌីជីថលអាចបង្កើតឱកាសសម្រាប់ការវិនិយោគក្នុងសេវាឌីជីថលនានា និងអាជីវកម្មជាច្រើនដែលទាក់ទងនឹងបច្ចេកវិទ្យា និងសេវាកម្មឌីជីថល ដូចជា cryptocurrency ឬ decentralized finance (DeFi)។

៣. សន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវទៅលើប្រធានបទ ស្តីពីការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា បានផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាតិជាច្រើន ធ្វើឱ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមរយៈទូរសព្ទចល័ត ឬកុំព្យូទ័រ ដោយមិនចាំបាច់ទៅកាន់សាខារបស់ធនាគារទេ។ សេវាកម្មបែបឌីជីថលអាចផ្តល់ការជួញដូរ ការទូទាត់បានយ៉ាងឆាប់រហ័ស ចំណាយពេល និងថវិកាតិច។ សម្រាប់សេដ្ឋកិច្ចជាតិ ធនាគារឌីជីថលអាចជួយបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ធនាគារអាចផ្តល់សេវាកម្មដែលមានតម្លៃទាបជាងសេវាកម្មធនាគារប្រពៃណី ដោយការកាត់បន្ថយចំណាយទៅលើមធ្យោបាយធ្វើដំណើរ និងសារព័ត៌មាន។

ផ្ទុយទៅវិញទោះបីជាយ៉ាងណាក្តី ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជាក៏មានគុណវិបត្តិ ដែលអាចប៉ះពាល់ដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាតិផងដែរ ព្រោះធនាគារឌីជីថលអាចដំណើរការទៅបានអាស្រ័យលើបច្ចេកវិទ្យា និងអ៊ីនធឺណិត ដែលអ្នកប្រើប្រាស់អាចជួបប្រទះនឹងបញ្ហាទាំងនេះ និងធ្វើឱ្យមានការបាត់បង់សាច់ប្រាក់ ឬព័ត៌មានផ្ទាល់ខ្លួន។ ប្រជាពលរដ្ឋដែលមិនចេះប្រើប្រាស់អ៊ីនធឺណិត ឬបច្ចេកវិទ្យាអាចមានការបាត់បង់ឱកាសក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុជាមួយស្ថាប័នធនាគារ។

សរុបជារួម ការរីកចម្រើននៃធនាគារឌីជីថលនៅកម្ពុជា មិនត្រឹមតែធ្វើឱ្យអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុមានភាពងាយស្រួល និងសុវត្ថិភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានភាពទាន់សម័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ទៀតផង។

ឯកសារយោង

១. ធនាគារជាតិនៃកម្ពុជា. (២០២៤). *របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤.* Retrieved ធ្នូ ១៤, ២០២៤, from https://www.nbc.gov.kh/download_files/publication/annual_rep_kh/Semi_Final_Report_2024.pdf

២. មជ្ឈមណ្ឌលកម្ពុជា៤.០. (n.d.). *បច្ចេកវិទ្យា និងធនាគារឌីជីថលនៅកម្ពុជា.* Retrieved ធ្នូ ១៤, ២០២៤, from https://cambodia4point0.org/kh/pdf-content/research-papers?page=3#

៣. មជ្ឈមណ្ឌលកម្ពុជា៤.០. (២០២៤). *កម្ពុជា៤.០.* Retrieved ធ្នូ ១៣, ២០២៤, from https://cambodia4point0. org/kh/Digital Banking 06012023

៤. សាលាឌីជីថល. (n.d.). *@saladigital*. Retrieved December 13, 2024, from https://sala.moeys.gov.kh/kh/ contents/ 65bb0c69 ee6c1 6f22e9cfc1a

៥. សហការី. (២០២០, តុលា ០៥). *នគរវត្ត.* Retrieved ធ្នូ ១៣, ២០២៤, from http://nokorwatnews.com/archives/1028430

៦. Alex Malyshey. (2023, November 07). *SDK.finance.* Retrieved December 14, 2024, from https://sdk.finance/what-is-digital-banking/

៧. Alicr Ivey (2023, APril 20). *cointelegraph*. Retrieved December 13, 2024, from https://cointelegraph.com/news/a-brief-history-of-digital-banking

៨. Bakong. (2019, December 06). *Financial service*. Retrieved December 13, 2024, from https://www.facebook.com/ bakongsystem/ posts /

៩. Kekcent. (2020, April 27). *News & media website*. Retrieved December 13, 2024, from https://www.facebook.com/kakcentkh/ videos/3794309207277746/

១០. NupuraUghade. (2024, September 18). *hyperverge.* Retrieved December 14, 2024, from https://hyperverge.co/blog/digital-banking-meaning-benefits-types/

១១. Semtararath. (2024, May 08). *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.* Retrieved December 2024, 2024, from https://mptc.gov.kh/2024

១២. VanPham. (2024, August 20). *kmssolutions.* Retrieved December 14, 2024, from https://kms-solutions.asia/blogs/digital-banking-development

ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព
Effective Property Plant Equipment Management

សុខ ដារ៉ា
បេក្ខបណ្ឌិត សេដ្ឋកិច្ច
គ្រូ គណនេយ្យ

មូលន័យសង្ខេប

ជាការពិតណាស់នៅក្នុងក្រុមហ៊ុនត្រូវតែមានការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាព និងត្រូវការធនធានបច្ចេកវិទ្យា បទពិសោធន៍ការគ្រប់គ្រង ជំនាញកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ហេតុនេះ ហើយបានជាខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវទៅលើប្រធានបទ «**ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព**» ដើម្បីស្វែងយល់អំពីដំណើរការ ឬបច្ចេកទេសនៃការគ្រប់គ្រងអចលកម្មរបស់ក្រុមហ៊ុន និងរក្សាទុកជាឯកសារជំនួយដល់ប្អូនៗនិស្សិតមានបំណងចង់យកទៅប្រើប្រាស់។ ក្រុមហ៊ុនគួរតែមានកម្មវិធីគ្រប់គ្រងអចលកម្ម ដែលវាអាចជួយកែលម្អការគ្រប់គ្រងដោយស្វ័យប្រវត្តិកម្ម និងសម្រួលដំណើរការផ្សេងៗ។ ជាមួយនឹងប្រព័ន្ធគ្រប់គ្រង ក្រុមហ៊ុនអាចតាមដាន និងគ្រប់គ្រងអចលកម្មរបស់ពួកគេយ៉ាងងាយស្រួល នេះអាចជួយកាត់បន្ថយហានិភ័យនៃការបាត់បង់ ឬចោរកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងថែទាំអចលកម្ម។

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី «ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព»។ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីគេហទំព័រ Hector and Rayda ដែលមានសារៈសំខាន់ក្នុងការជួយផ្តល់នូវទិន្នន័យពាក់ព័ន្ធដល់នីតិវិធីក្នុងការគ្រប់គ្រងអចលកម្ម សម្រាប់រៀបចំ និងចងក្រងអត្ថបទខ្លីស្តីអំពីការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព។

ការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាពគឺជាដំណើរការនៃការគ្រប់គ្រង និងចងក្រងសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងអចលកម្ម រួមទាំងសកម្មភាពផ្ទាល់ខ្លួន និងបច្ចេកទេស ដើម្បីធានាថា អចលកម្មត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព និងសម្របសម្រួលតាមតម្រូវការរបស់ក្រុមហ៊ុន ហើយវាជាការរួមចំណែកដល់ក្រុមហ៊ុន និងស្ថេរភាពហិរញ្ញវត្ថុ និងនិរន្តរភាពរយៈពេលវែង។ តាមរយៈការកត់ត្រា តាមដាន វាយតម្លៃជាទៀងទាត់ ដែលធ្វើឱ្យអាជីវកម្មអាចវាយតម្លៃប្រសិទ្ធភាពនៃអចលកម្មរបស់ខ្លួន និងធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ការវិនិយោគ និងការធ្វើផែនការយុទ្ធសាស្ត្រ។

១. សេចក្តីផ្តើម

នៅក្នុងសង្គមនាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាមានក្រុមហ៊ុនជាច្រើនកំពុងពង្រីកសក្តានុពលរបស់ខ្លួនក្នុងតំបន់។ ទន្ទឹមនឹងភាពរីកចម្រើនរបស់ក្រុមហ៊ុន អចលកម្មក៏ជាផ្នែកមួយដ៏សំខាន់ជួយជំរុញទៅដល់ក្រុមហ៊ុនឱ្យមានភាពរីកចម្រើន។ អញ្ចឹងហើយបានជាក្រុមហ៊ុនចាំបាច់ត្រូវតែមានអចលកម្មដើរតួនាទី និងចូលរួមក្នុងការផលិតនៅប្រាក់ចំណូលត្រឡប់មកវិញ ប្រសិនបើក្រុមហ៊ុនមិនមានអចលកម្មគ្រប់គ្រាន់ក្នុងការប្រើប្រាស់នោះទេ ប្រាកដជាអាចធ្វើឱ្យប៉ះពាល់ដល់ការផលិតប្រាក់ចំណូលជាក់ជាមិនខាន។

ការគ្រប់គ្រងអចលកម្ម គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រតិបត្តិការអាជីវកម្មដែលមានផលចំណេញ និងយូរអង្វែង ដោយសារមានយុទ្ធសាស្ត្រយ៉ាងសកម្ម ជំរុញក្នុងការជួយកែលម្អសុខភាពហិរញ្ញវត្ថុ ការសន្សំការចំណាយ និងប្រសិទ្ធភាពប្រតិបត្តិការផងដែរ។ ជាធម្មតា អ្នកបង្កើតក្រុមហ៊ុននីមួយៗ តែងតែសិក្សាលម្អិតអំពីសេដ្ឋកិច្ច ទីផ្សារ និងតម្រូវការផ្សេងៗទាក់ទងដល់ក្រុមហ៊ុនរបស់គេ។ ក្រុមហ៊ុនអាចដំណើរការទៅបានលុះត្រាតែមានការចូលរួមពីថ្នាក់គ្រប់គ្រងបុគ្គលិកប្រតិបត្តិ និងជាពិសេសត្រូវមានចំណែក អចលកម្មចូលរួមនៅក្នុងក្រុមហ៊ុន ប្រសិនបើគ្មានអចលកម្មយកមកចូលរួមបម្រើអាជីវកម្មនោះទេ និងធ្វើឱ្យការបង្កើនប្រសិទ្ធិភាពនៃការផលិតប្រាក់ចំណូលរបស់ក្រុមហ៊ុនថយចុះជាក់ជាមិនខាន។ ដោយឃើញថាអចលកម្មមានសារៈសំខាន់ចំពោះក្រុមហ៊ុន ព្រោះវាពិពណ៌នាអំពីមូលដ្ឋានគ្រឹះ និងស្ថេរភាពរយៈពេលវែងនៃអាជីវកម្ម។ អចលកម្មក៏ត្រូវបានគេប្រើប្រាស់ដើម្បីបង្កើតប្រាក់ចំណូល និងជាប្រភពនៃហិរញ្ញប្បទាននៅពេលក្រុមហ៊ុនមានតម្រូវការក្នុងការបង្កើនដើមទុន និងពង្រីកសក្តានុពលរបស់ខ្លួនឱ្យកាន់តែរីកចម្រើន។

ដូចនេះហើយបានជាក្រុមហ៊ុនត្រូវតែរៀបចំការគ្រប់គ្រង និងថែរក្សាអចលកម្មរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីផ្តល់ឱ្យក្រុមហ៊ុនជោគជ័យក្នុងអាជីវកម្ម ឆ្ពោះទៅសម្រេចគោលដៅ បេសកកម្ម និងចក្ខុវិស័យរបស់ខ្លួន។ ដោយមើលឃើញពីសារៈសំខាន់ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព ទើបមានសំណួរពីរលើកឡើងថា៖

១. តើមាននីតិវិធីអ្វីខ្លះក្នុងការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព?

២. តើការគ្រប់គ្រងអចលកម្មបានល្អផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ក្រុមហ៊ុន?



១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី «ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព»។ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីគេហទំព័រ Hector and Rayda សម្រាប់រៀបចំ និងចងក្រងអត្ថបទខ្លីស្តីអំពី ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព។

សម្រាប់សំណួរស្រាវជ្រាវទី១ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីគេហទំព័រ Hector and Rayda ដែលមានសារៈសំខាន់ក្នុងការជួយផ្តល់នូវទិន្នន័យពាក់ព័ន្ធដល់នីតិវិធីក្នុងការគ្រប់គ្រងអចលកម្ម សម្រាប់រៀបចំ និងចងក្រងអត្ថបទខ្លីស្តីអំពីការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព។

សម្រាប់សំណួរស្រាវជ្រាវទី២ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីគេហទំព័រ Hector and Rayda ដែលមានសារៈសំខាន់ក្នុងការជួយផ្តល់នូវទិន្នន័យពាក់ព័ន្ធផលប្រយោជន៍នៃការគ្រប់គ្រងអចលកម្មបានល្អ សម្រាប់រៀបចំ និងចងក្រង អត្ថបទខ្លីស្តីអំពីការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

នីតិវិធី (Procedure) គឺជាសំណុំនៃជំហាន ឬសកម្មភាពជាក់លាក់មួយដែលចាំបាច់ត្រូវអនុវត្តតាមដើម្បីបំពេញកិច្ចការ ឬសម្រេចបាននូវគោលដៅមួយ។ នីតិវិធីជារឿយៗត្រូវបានប្រើប្រាស់ក្នុងវិស័យផ្សេងៗ ដូចជា អាជីវកម្ម ការថែទាំសុខភាព និងបច្ចេកវិទ្យា ដើម្បីធានាថាការងារត្រូវបានអនុវត្តជាប់លាប់និងប្រកបដោយប្រសិទ្ធភាព[1]។

ការគ្រប់គ្រង (Management) គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពមួយឱ្យទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ (Planning) ការដឹកនាំ (Leading) ការចាត់ចែង (Organizing) ការត្រួតពិនិត្យឡើងវិញ (Controlling) និងការធ្វើសេចក្តីសម្រេចចិត្ត (Making decision)[2]។

អចលកម្ម (Property, Plant and Equipment) គឺបានដល់ទ្រព្យទាំងឡាយណាដែលមានលក្ខណៈដូចខាងក្រោម៖

១.ទិញមកគ្មានគោលបំណងលក់ចេញ

២.ទុកបម្រើក្នុងអាជីវកម្ម

៣.អាយុកាលប្រើប្រាស់យូរជាងមួយឆ្នាំ និងជាកម្មវត្ថុសម្រាប់ធ្វើរំលស់ ហើយអចលកម្មរូបី[3]។

---

[1] MERRIAM (2024, jun10) https://www.merriam-webster.com/dictionary/procedure

[2] វិទ្យាស្ថាន វ៉ាន់ដា(២០១៧) Principle of Management បោះពុម្ពលើកទី៦ ទំព័រទី៣

[3] វិទ្យាស្ថាន វ៉ាន់ដា(២០២៣) Intermediate Part I បោះពុម្ពលើកទី១២ ទំព័រទី២

ប្រសិទ្ធភាព (Effectiveness) គឺជាសមត្ថភាពផលិតលទ្ធផលដែលចង់បាន។ នៅពេលដែលអ្វីមួយត្រូវបានចាត់ទុកថាមានប្រសិទ្ធភាព វាមានន័យថាវាមានលទ្ធផលដែលបានគ្រោងទុក ឬរំពឹងទុក ឬបង្កើតចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅ និងរស់រវើក[4]។

២. ការគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

ការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់សម្រាប់ក្រុមហ៊ុន ឬអង្គការនានាក្នុងការតាមដាន ថែរក្សា និងបង្កើនប្រសិទ្ធភាពអចលកម្ម។ ការគ្រប់គ្រងអចលកម្មមិនថា ជាគ្រឿងចក្រ យានជំនិះ អគារ ឬឧបករណ៍នោះទេ ត្រូវធានាថាអចលកម្មទាំងនោះនៅតែដំណើរការបានល្អ និងជួយការពារការខាតបង់។

ខាងក្រោមនេះ គឺជាគន្លឹះមួយចំនួនដើម្បីគ្រប់គ្រងអចលកម្មឱ្យមានប្រសិទ្ធភាព៖

១. ការមានបញ្ជីតាមដានអចលកម្មត្រឹមត្រូវ

ការបង្កើតបញ្ជីតាមដានអចលកម្មត្រឹមត្រូវ គឺមានសារៈសំខាន់ក្នុងការគ្រប់គ្រងអចលកម្មរបស់ក្រុមហ៊ុន។ បញ្ជីតាមដានអចលកម្ម គឺជាកំណត់ត្រាដ៏ទូលំទូលាយនៃអចលកម្មរូបី និងហិរញ្ញវត្ថុទាំងអស់ដែលក្រុមហ៊ុនមាន។ អចលកម្មទាំងនេះជាធម្មតាមានអាយុកាលយូរអង្វែង ហើយត្រូវបានប្រើប្រាស់ដើម្បីបង្កើតប្រាក់ចំណូលសម្រាប់អាជីវកម្ម ដូច្នេះ ការរៀបចំបញ្ជីតាមដាន និងការកត់ត្រាអចលកម្មបានត្រឹមត្រូវពិតជាងាយស្រួលក្នុងការគ្រប់គ្រង។ វិធីនៃការគ្រប់គ្រងអចលកម្មមានដូចជា៖

១.១ តាមដាន និងត្រួតពិនិត្យរាល់ការប្រើប្រាស់អចលកម្ម

-ផែនការថែទាំជាប្រចាំ ដើម្បីជំរុញដល់ការកាត់បន្ថយការចំណាយ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការកាន់តែប្រសើរ

-ត្រួតពិនិត្យជាប្រចាំទៅលើអាយុកាលរបស់អចលកម្ម

-កំណត់អត្តសញ្ញាណរបស់អចលកម្មណាដែលដំណើរការមិនប្រក្រតី ឬត្រូវការការជួសជុល ឬជំនួសថ្មីដើម្បីជួយការពារការខាតបង់ពេលវេលា ឬគ្រោះថ្នាក់ផ្សេងៗ។

១.២ តាមដានទៅលើការកត់ត្រា និងធ្វើរំលស់បានត្រឹមត្រូវរបស់អចលកម្មដើម្បី៖

-បង្ហាញថ្លៃដើមនៃអចលកម្មត្រឹមត្រូវក្នុងរបាយការណ៍តុល្យការ

-បង្ហាញទឹកប្រាក់រំលស់ (Accumulated depreciation) និងសំវិធានធនលើអចលកម្ម (Impairment of PP&E) ត្រឹមត្រូវក្នុងរបាយការណ៍តុល្យការ

-បង្ហាញតម្លៃពិតគណនេយ្យ (Book Value) ត្រឹមត្រូវក្នុងរបាយការណ៍តុល្យការ

-ការបង្ហាញតួលេខត្រឹមត្រូវក្នុងរបាយការណ៍តុល្យការអាចជួយឱ្យអ្នកវិនិយោគ និងភាគីពាក់ព័ន្ធងាយស្រួលក្នុងការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច

-អាចកំណត់អត្តសញ្ញាណអចលកម្មដែលត្រូវបានប្រើប្រាស់តិច ឬមិនប្រើប្រាស់ទាល់តែសោះ

[4] WIKIPEDIA (2024, August 13) https://en.wikipedia.org/wiki/Effectiveness

-អាចធ្វើការសម្រេចចិត្តបានល្អប្រសើរក្នុងការរក្សាទុក ឬបោះចោល និងរបៀបបែងចែកធនធានឱ្យកាន់តែមានប្រសិទ្ធភាព។

២. ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាផ្នែក

ទោះបីជាការគ្រប់គ្រងអចលកម្ម ជាធម្មតាធ្វើឡើងដោយផ្នែកហិរញ្ញវត្ថុមួយក៏ដោយ វាក៏ជារឿងសំខាន់ក្នុងការបង្កើតកិច្ចប្រជុំជាទៀងទាត់រវាងផ្នែកហិរញ្ញវត្ថុ និងបណ្តាផ្នែកផ្សេងៗ ដើម្បីជំរុញឱ្យអ្នកពាក់ព័ន្ធទទួលបានព័ត៌មានអំពីរបៀបកត់ត្រាបន្ថែមផ្សេងទៀតក្នុងដំណើរការហិរញ្ញវត្ថុឆ្ពោះទៅរកគោលដៅរួមនៃការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាព។

៣. នីតិវិធីគ្រប់គ្រងអចលកម្មតឹងរ៉ឹង និងការណែនាំច្បាស់លាស់

នីតិវិធីគ្រប់គ្រងអចលកម្មតឹងរ៉ឹង និងការណែនាំច្បាស់លាស់ មានប្រយោជន៍ខ្លាំងណាស់សម្រាប់ស្ថាប័ន ព្រោះជួយឱ្យប្រាកដថា អចលកម្មទាំងអស់ត្រូវបានគណនាយ៉ាងត្រឹមត្រូវ ហើយកំពុងត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ នីតិវិធីគ្រប់គ្រងតឹងរ៉ឹងមួយក៏ជួយការពារកំហុស និងភាពមិនស្របគ្នាក្នុងការតាមដាន និងគ្រប់គ្រងអចលកម្មតាមរយៈការផ្តល់គោលការណ៍ណែនាំច្បាស់លាស់ និយោជិតដឹងច្បាស់អំពីរបៀបដោះស្រាយ ជៀសវាងកំហុសធ្ងង កាត់បន្ថយការចំណាយ និងកាត់បន្ថយហានិភ័យ។

៤. កម្មវិធីគ្រប់គ្រងអចលកម្ម(Software)

ក្រុមហ៊ុនត្រូវមានកម្មវិធីគ្រប់គ្រងអចលកម្មដែលអាចជួយកែលម្អការគ្រប់គ្រងដោយស្វ័យប្រវត្តិកម្ម និងសម្រួលដំណើរការផ្សេងៗ ដែលប្រព័ន្ធគ្រប់គ្រងនេះអាចតាមដាន និងគ្រប់គ្រងអចលកម្មបានយ៉ាងងាយស្រួល ជាពិសេសជួយកាត់បន្ថយហានិភ័យនៃការបាត់បង់ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងថែទាំអចលកម្ម។ ប្រព័ន្ធគ្រប់គ្រងក៏អាចផ្តល់ទិន្នន័យតាមដាន កំណត់ពេលវេលាជាក់ស្តែង តម្លៃនៃអចលកម្ម ដោយជួយឱ្យក្រុមហ៊ុនធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានអំពីការចាត់ចែង និងការបោះបង់ចោលអចលកម្ម។

៥. ការវាស់ពីប្រសិទ្ធភាពនៃការប្រើប្រាស់អចលកម្ម

$$\text{Fixed Asset Turnover Ratio} = \frac{\text{Net Revenue}}{\text{Average Fixed Assets}}$$

Fixed Asset Turnover (FAT) ជាសមាមាត្រអាចវាស់ពីប្រសិទ្ធភាពនៃការប្រើប្រាស់អចលកម្មទាំងអស់ដែលអាចផលិតចំណូលលើលក់បានប៉ុន្មាន។ សមាមាត្រនេះបែងចែកការលក់សុទ្ធដោយអចលកម្ម ដោយប្រើការគណនាវាជាប្រចាំឆ្នាំ។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ប្រាកដណាស់ ការគ្រប់គ្រងអចលកម្មបានល្អផ្តល់នូវផលប្រយោជន៍ជាច្រើនដល់អាជីវកម្ម។ ផលប្រយោជន៍សំខាន់មួយគឺការធ្វើឱ្យប្រសើរឡើងនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ។ តាមរយៈការតាមដាន

និងគ្រប់គ្រងអចលកម្មយ៉ាងត្រឹមត្រូវ អាជីវកម្មអាចធានាថារបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេឆ្លុះបញ្ចាំងពីតម្លៃពិតនៃអចលកម្មដែលបានកាន់កាប់។ នេះមិនត្រឹមតែជួយក្នុងការអនុលោមតាម ស្តង់ដាគណនេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱ្យអ្នកពាក់ព័ន្ធនូវរូបភាពកាន់តែច្បាស់អំពីសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនផងដែរ។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃអចលកម្មនឹងផ្តល់នូវផលប្រយោជន៍ ដូចជា៖

១. បង្កើនប្រសិទ្ធភាពប្រតិបត្តិការ៖ តាមរយៈការគ្រប់គ្រងអចលកម្មយ៉ាងសកម្ម អាចការពារការបែកបាក់ដែលមិននឹកស្មានដល់ និងធានាថាអចលកម្មដំណើរការល្អបំផុត ជួយកាត់បន្ថយពេលវេលាផលិតភាពខ្ពស់ និងលំហូរការងារកាន់តែរលូន។

២. ធ្វើឱ្យប្រសើរឡើងនូវរបាយការណ៍ហិរញ្ញវត្ថុ៖ ការតាមដានអចលកម្ម និងការគណនារំលស់ត្រឹមត្រូវ នាំឱ្យរបាយការណ៍ហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តជាងមុន ល្អសម្រាប់ក្រុមហ៊ុន និងវិនិយោគិន។

៣. កាត់បន្ថយការចំណាយ៖ កាត់បន្ថយការខ្ជះខ្ជាយដោយការពារការទិញដែលមិនចាំបាច់ បង្កើនប្រសិទ្ធភាពកាលវិភាគថែទាំ និងការពន្យារអាយុអចលកម្ម។ ហេតុអ្វីត្រូវចំណាយលុយទិញឧបករណ៍ថ្មី នៅពេលអ្នកអាចគ្រប់គ្រងឧបករណ៍ដែលមានស្រាប់បានប្រសើរជាងមុន និងប្រើប្រាស់បានយូរ។

៤. បង្កើនអាយុអចលកម្ម៖ ការថែទាំជាប្រចាំ និងវិធានការបង្ការពន្យារអាយុជីវិតនៃអចលកម្មបង្កើនការត្រឡប់មកវិញលើការវិនិយោគ និងពន្យារពេលការជំនួសថ្លៃដើម។

៥. ការកាត់បន្ថយហានិភ័យ៖ ការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាពជួយកំណត់យ៉ាងសកម្មនូវហានិភ័យដែលអាចកើតមានទាក់ទងនឹងការបរាជ័យនៃអចលកម្ម ឬចោរកម្ម។ អនុវត្តវិធានការបង្ការ និងកាត់បន្ថយការខាតដែលអាចកើតមានចំពោះប្រតិបត្តិការរបស់អ្នក។

៦. តម្លាភាព និងគណនេយ្យភាពប្រសើរឡើង៖ ប្រព័ន្ធគ្រប់គ្រងអចលកម្មលើកកម្ពស់តម្លាភាព និងគណនេយ្យភាពទូទាំងស្ថាប័ន។ បុគ្គលពាក់ព័ន្ធអាចទទួលបានព័ត៌មានអចលកម្មត្រឹមត្រូវ សម្រាប់សម្រួលកិច្ចសហការកាន់តែប្រសើរ និងធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មាន។

៣. សន្និដ្ឋាន

សរុបមក ការគ្រប់គ្រងអចលកម្មប្រកបដោយប្រសិទ្ធភាពគឺជាដំណើរការនៃការគ្រប់គ្រង និងចងក្រងសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងអចលកម្ម រួមទាំងសកម្មភាពផ្ទាល់ខ្លួន និងបច្ចេកទេស ដើម្បីធានាថា អចលកម្មត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព និងសម្រាប់សម្រួលតាមតម្រូវការរបស់ក្រុមហ៊ុន ហើយជាការរួមចំណែកដល់ក្រុមហ៊ុន រក្សាស្ថេរភាពហិរញ្ញវត្ថុ និងនិរន្តរភាពរយៈពេលវែង។ តាមរយៈការកត់ត្រា តាមដាន វាយតម្លៃជាទៀងទាត់នឹងធ្វើឱ្យអាជីវកម្មអាចវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់អចលកម្ម និងធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានត្រឹមត្រូវដែលទាក់ទងនឹងការគ្រប់គ្រងអចលកម្ម ការវិនិយោគ និងការធ្វើផែនការយុទ្ធសាស្ត្រ។

ឯកសារយោង

១. MERRIAM (2024, jun10) https://www.merriam-webster.com/dictionary/procedure

២. វិទ្យាស្ថាន វ៉ាន់ដា(២០១៧) Principle of Management បោះពុម្ពលើកទី៦ ទំព័រទី៣ សរុប៦៥ទំព័រ

៣. វិទ្យាស្ថាន វ៉ាន់ដា(២០២៣) Intermediate Part I បោះពុម្ពលើកទី១២ ទំព័រទី២ សរុប១៦២ទំព័រ

៤. WIKIPEDIA (2024, August 13) https://en.wikipedia.org/wiki/Effectiveness

៥. Investopedia. (2024, jul17) https://www.investopedia.com/terms/f/fixed-asset-turnover.asp

៦. Hector. (2023, Nov01) https://hectorassetmanager.com/blog/4-tips-improvement-management-assets

៧. Rayda. (2024, jan26) https://blog.rayda.co/how-fixed-asset-management-works/

ការបង់ពន្ធរបស់អាជីវកម្មអនឡាញ
Online Businesses Tax Payment

វិចិត្ត ទិដ្ឋការ
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម
គ្រូមុខវិជ្ជា គណនេយ្យអនុវត្តន៍ និងពន្ធ

មូលន័យសង្ខេប

ប្រទេសកម្ពុជាបច្ចុប្បន្ន គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍសឹងតែគ្រប់វិស័យ ជាពិសេសនោះ គឺអាជីវកម្មអនឡាញកំពុងតែមានការកើនឡើងផុសផុលពីមួយថ្ងៃទៅមួយថ្ងៃ និងបានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗតាមប្រព័ន្ធអ៊ីនធឺណេត ហើយអគ្គនាយកដ្ឋានពន្ធដារបានធ្វើការសម្រេចចិត្តក្នុងការដកហូតពន្ធពីអាជីវកម្មអនឡាញទាំងនោះ។ ដោយមើលឃើញពីនិន្នាការនៃអាជីវកម្មអនឡាញបានលេចរូបរាងជាបណ្តើរៗឥតឈប់ឈរបែបនេះ ទើបមានការស្រាវជ្រាវទៅលើប្រធានបទមួយនេះកើតឡើងក្នុងគោលបំណងដើម្បីយល់ដឹងពីការចូលរួមចំណែក យល់ដឹងពីអត្ថប្រយោជន៍ កាតព្វកិច្ច និងនីតិវិធីក្នុងការបង់ពន្ធតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

ការស្រាវជ្រាវនេះ គឺប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យតាមបែបគុណវិស័យ ដែលជាវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលឯកសារ និងទិន្នន័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ តាមរយៈគេហទំព័រដូចជា Freshnewsasia, Cambizian, ខេមបូណូមីស RFI ខេមរភាសា ព្រះរាជក្រមលេខនស/រកម/១១១៩/០១៧ ច្បាប់សារពើពន្ធ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ សៀវភៅអេឡិចត្រូនិកសម្រាប់ធុរកិច្ច និងឯកសារក្នុងសៀវភៅគោលមុខវិជ្ជាគណនេយ្យអនុវត្តន៍ និងពន្ធរបស់វិទ្យាស្ថាន វ៉ាន់ដា។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ភាគច្រើនអាជីវកម្មអនឡាញមួយចំនួនធំ មិនបានចុះបញ្ជី និងមិនបានបង់ពន្ធជូនរដ្ឋនោះទេ ដែលប្រហែលមកពីអ្នកប្រកបអាជីវកម្មអនឡាញទាំងនោះគិតថា វាគ្រាន់តែជាមុខរបរលក់ដូរបន្តិចបន្តួចជាលក្ខណៈគ្រួសារ ឬគ្រាន់តែជាការលក់ក្នុងការផុសផ្សព្វផ្សាយ និងឡាយស៍ក្នុងប្រព័ន្ធSocial Media តែប៉ុណ្ណោះ ដែលមិនចាំបាច់ទៅចុះបញ្ជី ហើយបង់ពន្ធដូចគ្នា និងអាចបណ្តាលមកពីមិនបានយល់ដឹងអំពីការចុះបញ្ជី និងការបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធ។ សរុបមកវិញ ការយកពន្ធលើអាជីវកម្មអនឡាញ គឺជាចំណូលជាតិដ៏សំខាន់ដើម្បីកសាងប្រទេសជាតិទាំងមូល ចាំបាច់ណាស់សម្រាប់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ការធានាបាននូវភាពយុត្តិធម៌ ការបង្កើតប្រាក់ចំណូល ការការពារការគេចវេសពន្ធ និងមិនចាំបាច់បោះពុម្ពលុយច្រើនដែលអាចបង្កឱ្យមានបញ្ហាអតិផរណា ហើយក៏ជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេសផងដែរ។

១. សេចក្តីផ្តើម

នៅក្នុងសង្គមជាតិយើងសព្វថ្ងៃ ការធ្វើអាជីវកម្មអនឡាញគឺមានការកើនឡើងយ៉ាងច្រើនពីមួយឆ្នាំទៅមួយឆ្នាំដោយមានការចូលរួមពីវិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក។ ទន្ទឹមនឹងនេះដែរ ដើម្បីជួយឱ្យប្រទេសកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មីពីប្រទេសកំពុងអភិវឌ្ឍឱ្យក្លាយទៅជាប្រទេសជឿនលឿន អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំការដកហូតពន្ធ ពីអ្នកប្រកបអាជីវកម្មទាំងអស់ មិនថាជាសហគ្រាស តូច មធ្យម ធំ ឬអាជីវកម្មអនឡាញក្តី គឺសុទ្ធសឹងតែមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋាភិបាលដូចគ្នា។

ដោយមើលឃើញពីនិន្នាការនៃអាជីវកម្មអនឡាញបានកើនឡើង និងបានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗតាមប្រព័ន្ធអ៊ីនធឺណេត ស្របពេលដែលអតិថិជនកំពុងសម្របខ្លួនជា បណ្តើរៗក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យានានា។ ទោះយ៉ាងណា ស្ថិតនៅក្នុងបរិបទនេះ កម្ពុជាមិនទាន់មានយន្តការជាក់លាក់ណាមួយក្នុងការប្រមូលចំណូលសារពើពន្ធពីប្រតិបត្តិការអាជីវកម្មអនឡាញនៅឡើយ។ អាជីវកម្មអនឡាញទាំងអស់ចាំបាច់ណាស់ត្រូវតែបង់ពន្ធ ព្រោះការបង់ពន្ធនេះ គឺជាចំណូលជាតិដ៏សំខាន់ដែលបានចូលរួមចំណែកយ៉ាងច្រើនក្នុងការជួយកសាងសេដ្ឋកិច្ចជាតិ ដូចជា ការកសាងសាលារៀន សាងសង់ស្ពាន មន្ទីរពេទ្យ បើកប្រាក់បៀវត្សជូនគ្រូបង្រៀន កងទ័ពការពារព្រំដែន កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យមានសណ្តាប់ធ្នាប់ ល្អ ល្អ ។ ដូចនេះ ការប្រមូលចំណូលពីការបង់ពន្ធពីអ្នកដែលប្រកបអាជីវកម្មអនឡាញគឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេសផងដែរ។ ដោយមើលឃើញខាងលើបែបនេះ ហេតុដូច្នេះទើបមានសំណួរពីរបានលើកឡើងថា៖

១. តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យអាជីវកម្មអនឡាញត្រូវបង់ពន្ធ?

២. តើពន្ធដារមានន័យវិធីយ៉ាងណាក្នុងការប្រមូលពន្ធពីអាជីវកម្មអនឡាញ?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យតាមបែបគុណវិស័យ ដែលជាវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលឯកសារ និងទិន្នន័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ តាមរយៈគេហទំព័រដូចជា Freshnewsasia, Cambizian, ខេមបូណូមីស, RFI ខេមរភាសា, ព្រះរាជក្រមលេខនស/រកម/១១១៩/០១៧ ច្បាប់សារពើពន្ធ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ សៀវភៅគោលមុខវិជ្ជាគណនេយ្យអនុវត្តន៍ និងពន្ធរបស់វិទ្យាស្ថាន វ៉ាន់ដា។

សម្រាប់សំណួរទី១ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការប្រមូលដកស្រង់ចេញពីទិន្នន័យតាមរយៈគេហទំព័រដូចជា Freshnewsasia, Cambizian, ខេមបូណូមីស RFI ខេមរភាសា ព្រះរាជក្រមលេខនស/រកម/១១១៩/០១៧ និងឯកសារក្នុងសៀវភៅគោលមុខវិជ្ជាគណនេយ្យអនុវត្តន៍ និងពន្ធរបស់វិទ្យាស្ថាន វ៉ាន់ដា ដើម្បីធ្វើការសរសេរចងក្រងឡើងវិញសម្រាប់ក្នុងការយល់ដឹងអំពីការចូលរួមចំណែក និងមូលហេតុនៃការបង់ពន្ធ។

សម្រាប់សំណួរទី២ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ចេញពីទិន្នន័យតាមរយៈគេហទំព័រដូចជា ច្បាប់សារពើពន្ធ លិខិតបទដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ

សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និងឯកសារក្នុងសៀវភៅគោលមុខវិជ្ជាគណនេយ្យអនុវត្តន៍ និងពន្ធរបស់វិទ្យាស្ថាន វ៉ាន់ដា និងចងក្រងឡើងវិញ សម្រាប់ជាផលប្រយោជន៍ក្នុងការយល់ដឹងអំពីកាតព្វកិច្ច និងនីតិវិធីក្នុងការបង់ពន្ធតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

១.៣ ការសិក្សាស្រាវជ្រាវពាក់ព័ន្ធ

១.៣.១ និយមន័យ

ពន្ធ (Taxation) គឺជាកាតព្វកិច្ចបង់ជាប្រាក់ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួល តម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ[1]។

អាជីវកម្ម (Business) គឺជាសកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលក្នុងគោលដៅផលិត និងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិឬសកម្មភាពផ្សេងទៀតរួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានាដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រា ៥ នៃច្បាប់សារពើពន្ធ[2]។

អនឡាញ (Online) គឺជាការទំនាក់ទំនងដែលប្រើប្រាស់អ៊ីនធឺណេតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ តាមរយៈគេហទំព័រ និងកម្មវិធីកុំព្យូទ័រ ដើម្បីចែករំលែកព័ត៌មានអ្វីមួយនៅលើអ៊ីនធឺណេត[3]។

អាជីវកម្មអនឡាញ (Online Business) គឺជាការជួញដូរទំនិញឬសេវាកម្ម តាមរយៈការប្រាស្រ័យទាក់ទងរវាងអតិថិជន និងអ្នកលក់ដោយប្រព័ន្ធទីផ្សារបែបឌីជីថលឬបណ្តាញសង្គមដែលកំពុងមានប្រជាប្រិយភាពដូចជា ហ្វេសប៊ុក អ៊ីនស្តាក្រាម និងគេហទំព័រអនឡាញមួយចំនួនទៀតដោយប្រើប្រាស់អ៊ីនធឺណេត[4]។

១.៣.២ សាវតារពន្ធដារ

- ១៩៥៣ : នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង
- ១៩៧៥-១៩៧៩: ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់
- ១៩៨០-១៩៩៣: នាយកដ្ឋានពន្ធដារឧស្សាហកម្មពាណិជ្ជក្រសួងហិរញ្ញវត្ថុ
- ១៩៩៣-២០០៨: នាយកដ្ឋានពន្ធដារ(អង្គភាពពន្ធដារ)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ២០០៨-បច្ចុប្បន្ន: អគ្គនាយកដ្ឋានពន្ធដារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[5]។

---

[1] វិទ្យាស្ថាន វ៉ាន់ដា. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១ ទំព័រទី២

[2] វិទ្យាស្ថាន វ៉ាន់ដា. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១ ទំព័រទី១៣

[3] Cambridge Dictionary. https://dictionary.cambridge.org/dictionary/english/online

[4] ខេមបូហ្វាយនែន. (August 01 2021). *អាជីវកម្មអនឡាញ (Online Business) និងអាជីវកម្មបែបផ្ទាល់ (Physical Business)*: https://www.facebook.com/CamboFinance/posts/1149514835543244

[5] វិទ្យាស្ថាន វ៉ាន់ដា. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១ ទំព័រទី៣

២. ការបង់ពន្ធរបស់អាជីវកម្មអនឡាញ

លទ្ធផលសម្រាប់សំណួរទី១

មូលហេតុដែលបណ្តាលឱ្យអាជីវកម្មអនឡាញត្រូវបង់ពន្ធគឺ

-ច្បាប់តម្រូវឱ្យអាជីវកម្មអនឡាញទាំងអស់ត្រូវចុះបញ្ជី

ក. កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០កន្លងទៅ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានអនុម័ត ដើម្បីគ្រប់គ្រងទៅលើការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកឬអាជីវកម្មអនឡាញ ក្នុងគោលបំណងសម្រួល និងជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងក្នុង និងក្រៅប្រទេសក្នុងការផ្តល់នូវទំនុកចិត្ត និងការការពារដល់អ្នកប្រើប្រាស់ជាដើម។ គ្រប់ការប្រកបអាជីវកម្មទាំងអស់គឺត្រូវមានការស្នើសុំច្បាប់អនុញ្ញាតឬចុះបញ្ជីឱ្យបានត្រឹមត្រូវ។

ខ. យោងអនុសាសន៍របស់លោក គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានពន្យល់យ៉ាងលម្អិតដល់សាធារណជនឱ្យកាន់តែច្បាស់បន្ថែមអំពីការបង់ពន្ធលើការកេស៊ីក្នុងអាជីវកម្មអនឡាញ។ ថ្លែងក្នុងកម្មវិធីស្តីពី **«ការផ្តល់សេវា និងបច្ចុប្បន្នភាពព្រឹត្តិការណ៍ផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ»** នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមរយៈការ Live តាមFacebookពន្ធដារ លោក គង់ វិបុល បានឱ្យដឹងថា នៅក្នុងសម័យអនឡាញជាបញ្ហាដ៏ស្មុគស្មាញរបស់រដ្ឋបាលសារពើពន្ធទាំងកម្ពុជាទាំងអន្តរជាតិ។

គ. អាជីវកម្មអនឡាញត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតអាជីវកម្មឬចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងត្រូវចុះបញ្ជីពន្ធដារផងដែរ ចំពោះអ្នកប្រកបអាជីវកម្មតាមអនឡាញដែលមានចំណូលចាប់ពី ២៥០លានរៀលឡើងទៅក្នុងមួយឆ្នាំ។

ឃ. សូមបញ្ជាក់ផងដែរថា មិនមែនគ្រប់អាជីវកម្មអនឡាញសុទ្ធតែត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីនោះទេ ដោយក្នុងនោះ ក្រសួងក៏មានការលើកលែងលើអាជីវកម្មចំនួន៦ប្រភេទដែរ។ អាជីវកម្មតាមអនឡាញ ដែលត្រូវបានលើកលែង ដោយមិនចាំបាច់មកចុះបញ្ជីនោះរួមមាន៖

១.អាជីវកម្មដែលគ្រាន់តែផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញឬសេវារបស់ខ្លួន ដូចជា ការផ្សព្វផ្សាយទំនិញកសិផលល្អ ប៉ុន្តែមិនបានប្រកាសអំពីតម្លៃរបស់កសិផល។

២. ការកក់បម្រុងទុកនូវសេវាដែលមិនមានការកក់ប្រាក់ គឺអាចផ្តល់ព័ត៌មានផ្សេងៗសម្រាប់អតិថិជនឬអ្នកប្រើប្រាស់។ មានន័យថា មានការជជែកជាមួយអ្នកទិញបាន ប៉ុន្តែមិនមានសេវាកក់ប្រាក់ឡើយ ជារួមគឺមិនមានបង្កើតសំណើនៃកិច្ចសន្យានោះទេ ដូច្នេះក៏មិនចាំបាច់ចុះបញ្ជីនោះដែរ។

៣. ការលក់ទំនិញឬសេវា របស់រូបវន្តបុគ្គល ដែលមានផលរបបក្រោមកម្រិតផលរបបជាអ្នកជាប់ពន្ធតូច។ មានន័យថា ប្រសិនបើអ្នករកស៊ី ស្ថិតនៅការរកស៊ីក្រោមកម្រិតផលរបបជាអ្នកជាប់ពន្ធតូច (ក្រោម ២៥០លានរៀលក្នុង១ឆ្នាំ)។

៤. ការលក់ទំនិញឬផ្តល់សេវា ដែលមានលក្ខណៈគ្រួសារតាមរដូវកាល។

៥. ការលក់ទំនិញជាស្នាដៃសិល្បៈ។

៦.ការបង្ហាត់បង្រៀនសិស្ស តាមប្រព័ន្ធអនឡាញជាឯកជនឬការបង្ហាត់បង្រៀន ជាសិក្ខាសាលាជាដើម។

-ការបង្កើនប្រាក់ចំណូលពន្ធ

ក. ការយកពន្ធនៃអាជីវកម្មអនឡាញគឺជាចំណូលជាតិដ៏សំខាន់ក្នុងការចូលរួមចំណែកថវិកាជាតិ និងការអភិវឌ្ឍប្រទេសជាតិយ៉ាងច្រើនក្នុងការជួយកសាងសេដ្ឋកិច្ចជាតិ ដូចជាការកសាងសាលារៀន កសាងស្ពាន កសាងមន្ទីរពេទ្យ សាងសង់ផ្លូវ បើកប្រាក់បៀវត្សជូនគ្រូបង្រៀន កងទ័ពការពារព្រំដែន កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យមានសណ្តាប់ធ្នាប់ ១ បៀបរៀបរយនៅក្នុងសង្គមជាតិទាំងមូល។

ខ. ការបង្កើនចំណូលជាតិដើម្បីឱ្យរដ្ឋមានលទ្ធភាពយកទៅទូទាត់ចំណាយដោយមិនចាំបាច់បោះពុម្ពក្រដាសប្រាក់ដែលអាចបង្ក ឱ្យមានបញ្ហាអតិផរណា។

គ. ការប្រមូលពន្ធពីអ្នកដែលប្រកបអាជីវកម្មអនឡាញ គឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេសផងដែរ។

លទ្ធផលសម្រាប់សំណួរទី២

អ្នកប្រកបអាជីវកម្មអនឡាញ តាមមាត្រា២០៣ នៃច្បាប់សារពើពន្ធនៅក្នុងប្រទេសកម្ពុជា គឺត្រូវតែមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងបង់ពន្ធ។ អាជីវកម្មអនឡាញ មានកាតព្វកិច្ចចុះបញ្ជីជាអ្នកជាប់ពន្ធតូចតាមរបបស្វ័យប្រកាស ចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងត្រូវចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ។ ការប្រមូលពន្ធពីអាជីវកម្មអនឡាញនៅកម្ពុជា ពន្ធដារមាននីតិវិធីដូចតទៅ៖

1. **ការចុះឈ្មោះអាជីវកម្ម**: អាជីវកម្មអនឡាញត្រូវតែចុះឈ្មោះជាផ្លូវការជាមួយនាយកដ្ឋានពន្ធដារ នេះរួមមានការផ្តល់ព័ត៌មានអំពីអាជីវកម្ម និងការទទួលបានលេខសម្គាល់ពន្ធ (TIN)។

បុគ្គលទាំងឡាយ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ចឬក្រោយពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជីឬលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

ការចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសឯកបុគ្គល អ្នកជាប់ពន្ធត្រូវបំពេញទម្រង់101-P5 និងត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

១. លិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួងពាណិជ្ជកម្មឬក្រសួង-ស្ថាប័នពាក់ព័ន្ធ

២. លិខិតប្រកាសដោយសុទ្ធចិត្ត អំពីការពុំមានជាប់ទោសពៃ៍ក្នុងកិច្ចពាណិជ្ជកម្ម រដ្ឋប្បវេណីឬព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការក្រសួងឬស្ថាប័នរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

៣.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់កម្មសិទ្ធិករឬអ្នកគ្រប់គ្រង

- រូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅឬលិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

៤. រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌សចំនួន០២សន្លឹករបស់កម្មសិទ្ធិករឬអ្នកគ្រប់គ្រង

៥. បណ្ណកម្មសិទ្ធិទីតាំងឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមកាទីតាំងរបស់ទីស្នាក់ការឬទីចាត់ការសហគ្រាស

- ទីតាំងដែលគ្មានអគារឬជាដីទំនេរឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ រៀងរាល់តែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ

៦. លិខិតជូនដំណឹងស្តីពីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ

- ប្រសិនបើមានអ្នកទទួលបន្ទុកជំនួស

៧. លិខិតបញ្ជាក់ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារឬសៀវភៅគណនីធនាគារ)។

បន្ថែមជាងនេះទៅទៀត នីតិវិធីការចុះបញ្ជីអាជីវកម្មនៅប្រទេសកម្ពុជាពីមុន (ចុះបញ្ជីដោយផ្ទាល់) ធ្លាប់ជានីតិវិធីមួយដែលស្មុគស្មាញ ធ្វើឱ្យម្ចាស់អាជីវកម្ម និងធុរជនចំណាយពេលវេលា ថវិការច្រើន ដោយម្ចាស់អាជីវកម្ម និងធុរជនត្រូវចំណាយពេលបំពេញព័ត៌មាន ផ្តល់ឯកសារដដែលៗ និងត្រូវធ្វើដំណើរទៅកាន់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់ស្នើសុំចុះបញ្ជី។ ការផ្តល់ព័ត៌មាន និងផ្តល់ឯកសារដែលម្ចាស់អាជីវកម្ម និងធុរជនបានផ្តល់ជូនមិនត្រូវបានចែករំលែកជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនោះទេ។ ដើម្បីជាកិច្ចឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ក៏ដូចជាមតិពីសំណាក់វិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន (ចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន) ក្នុងនោះដោយមានការចូលរួមពីសំណាក់ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ តាមរយៈនីតិវិធីចុះបញ្ជីថ្មីនេះ ម្ចាស់អាជីវកម្ម និងធុរជនអាចចុះបញ្ជីជាកញ្ចប់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានរៀបរាប់ខាងលើ និងចំណាយពេលវេលាតិចជាងមុនដោយរយៈពេលនៃការត្រួតពិនិត្យត្រូវបានកាត់បន្ថយមកនៅត្រឹម ៨ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនជាឯកសារ និងព័ត៌មានដែលបានផ្តល់ត្រឹមត្រូវពិតប្រាកដ និងគ្រប់គ្រាន់។ ការត្រួតពិនិត្យនៅក្រោមក្រសួងពាណិជ្ជកម្មមានរយៈពេល ៣ថ្ងៃ នៅក្រោមអគ្គនាយកដ្ឋានពន្ធដារមានរយៈពេល ៤ថ្ងៃ និងនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល១ថ្ងៃ។ បន្ថែមពីលើនេះផងដែរ តម្លៃសេវាចុះបញ្ជីត្រូវបានកាត់បន្ថយ៤០% បើប្រៀបធៀបជាមួយនីតិវិធីចាស់ ដែលតម្លៃសេវានៃការចុះបញ្ជីអាជីវកម្មនឹងប្រើប្រួលទៅតាមប្រភេទអ្នកជាប់ពន្ធ និងប្រភេទសហគ្រាស/ក្រុមហ៊ុន។ គួរបញ្ជាក់ផងដែរថា ក្នុងគោលដៅលើកទឹកចិត្ត និងជំរុញការចុះអាជីវកម្មនៅក្នុងប្រទេសកម្ពុជា អ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវបង់ពន្ធប៉ាតង់ត្រឹមតែ ៥០% នៃប្រាក់ពន្ធប៉ាតង់ប៉ុណ្ណោះសម្រាប់ឆ្នាំដំបូង។ នីតិវិធីថ្មីនេះ ជានីតិវិធីដែលប្រើប្រាស់គោលការណ៍ផ្តល់ព័ត៌មានតែមួយដង ដោយទិន្នន័យនឹងត្រូវបានចែកចាយទៅកាន់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធតាមរយៈថ្នាល CamDX។ ការចុះបញ្ជីអាជីវកម្មតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន ត្រូវបានធ្វើឡើងតាមរយៈអនឡាញទាំងស្រុង រាប់ចាប់ពីការបំពេញ

ឯកសារ ការបង់ប្រាក់ ការទាញយកអាជ្ញាបណ្ណ និងវិញ្ញាបនបត្រ ដោយមិនមានការតម្រូវឱ្យផ្តល់នូវឯកសារទម្រង់រឹងនោះឡើយ។ ដើម្បីអាចធ្វើការចុះបញ្ជីអាជីវកម្មបាន ធុរជនទាំងអស់ត្រូវចូលទៅកាន់គេហទំព័រ http://www.registrationservices.gov.kh រួចចុចលើពាក្យ «ចុះបញ្ជីអាជីវកម្ម» ហើយត្រូវបង្កើតគណនី CamDigiKey មួយ ដើម្បីអាចស្កេន QR Code និងចូលដល់ផ្នាលចុះបញ្ជី។

បុគ្គលស្នើសុំត្រូវអនុវត្តតាម **"សៀវភៅមគ្គុទេសក៍ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន"** ដែលមានជំហានដូចខាងក្រោម៖

ជំហានទី១៖ បង្កើតគណនី CamDigiKey

ស្វែងយល់បន្ថែមស្តីពីរបៀបចុះបញ្ជីបានតាមរយៈវីដេអូឬរូបភាពខាងក្រោម៖

ជំហានទី២៖ ចូលទៅកាន់គេហទំព័រ http://www.registrationservices.gov.kh រួចចុច "ចុះបញ្ជីអាជីវកម្ម"



ជំហានទី៣៖ ស្កេន QR Code

ចុច "ទាញយក QR Code" រួចស្កេន QR Code ដោយប្រើប្រាស់កម្មវិធី CamDigiKey របស់លោកអ្នក

ជំហានទី៤៖ ចុចសំណើចុះបញ្ជី រួចបំពេញព័ត៌មាន រួចចុចពាក្យ "បន្ទាប់"




ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
ឆេង ច័ន្ទកន្ត្រា
ការចុះបញ្ជីក្រុមហ៊ុន
ក្រុមហ៊ុនរបស់ខ្ញុំ
សេចក្តីព្រៀង
បម្រុងទុកនាមករណ៍ក្រុមហ៊ុន
ចុះបញ្ជីបំពេញបន្ថែមកាតព្វកិច្ច
បញ្ជីស្នើសុំកែតម្រូវ
បញ្ជីសុំផ្ទេរសិទ្ធិគ្រប់គ្រង
ផ្តល់មតិ
v3.0.2
ចុះបញ្ជីពាណិជ្ជកម្ម
ចុះបញ្ជីពន្ធដារ
សេចក្តីប្រកាសថ្នមដំណឹងបើកសហគ្រាស
ពិនិត្យឡើងវិញ
ព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម
(សញ្ញា * * * មានន័យថាព័ត៌មានចាំបាច់ត្រូវតែមាន)
ក្រុមហ៊ុនមូលធន
ក្រុមហ៊ុនបរទេស
សហគ្រាសឯកបុគ្គល
ក្រុមហ៊ុនសហកម្មសិទ្ធិ
9. នាមករណ៍សហគ្រាសឯកបុគ្គល
ជ្រើសរើសនាមករណ៍បម្រុងទុក?
នាមករណ៍ដែលបានស្នើ (ជាភាសាខ្មែរ) *
សុពលភាពនាមករណ៍
នាមករណ៍ដែលបានស្នើ (ជាភាសាខ្មែរ) ត្រូវតែបញ្ចូល
សម្គាល់៖ ផ្នែកលើប្រភេទក្រុមហ៊ុន/សហគ្រាស ដែលអ្នកជ្រើសរើស នាមករណ៍ក្រុមហ៊ុនរបស់អ្នកមិនត្រូវបញ្ចប់ដោយ "ឯ.ក", "ម.ក", "ស.ទ" ឬ "ស.ក" បានទេ។
នាមករណ៍ដែលបានស្នើ (ជាភាសាអង់គ្លេស) *
សុពលភាពនាមករណ៍
នាមករណ៍ដែលបានស្នើ (ជាភាសាអង់គ្លេស) ត្រូវតែបញ្ចូល
សម្គាល់៖ ផ្នែកលើប្រភេទក្រុមហ៊ុន/សហគ្រាស ដែលអ្នកជ្រើសរើស នាមករណ៍ក្រុមហ៊ុនរបស់អ្នកមិនត្រូវបញ្ចប់ដោយ "CO., LTD.", "COMPANY LIMITED", "PLC", "PLC.", "PUBLIC LIMITED COMPANY", "GP", "GENERAL PARTNERSHIP", "LP" ឬ "LIMITED PARTNERSHIP" បានទេ។
Welcome back, let us know if you have any questions.
២. សកម្មភាពអាជីវកម្ម


ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
ឆេង ច័ន្ទកន្ត្រា
ការចុះបញ្ជីក្រុមហ៊ុន
ក្រុមហ៊ុនរបស់ខ្ញុំ
សេចក្តីព្រៀង
បម្រុងទុកនាមករណ៍ក្រុមហ៊ុន
ចុះបញ្ជីបំពេញបន្ថែមកាតព្វកិច្ច
បញ្ជីស្នើសុំកែតម្រូវ
បញ្ជីសុំផ្ទេរសិទ្ធិគ្រប់គ្រង
ផ្តល់មតិ
v3.0.2
ចុះបញ្ជីពាណិជ្ជកម្ម
ចុះបញ្ជីពន្ធដារ
សេចក្តីប្រកាសថ្នមដំណឹងបើកសហគ្រាស
ពិនិត្យឡើងវិញ
ព័ត៌មានសម្រាប់ចុះបញ្ជីពន្ធដារ
(សញ្ញា * * * មានន័យថាព័ត៌មានចាំបាច់ត្រូវតែមាន)
១. ព័ត៌មាននៃការស្នើសុំចុះបញ្ជីពន្ធដារ
ឆ្នាំជាប់ពន្ធរបស់សហគ្រាស
ចាប់ពីថ្ងៃខែ *
01
01
រហូតដល់ថ្ងៃខែ *
31
12
២. ព័ត៌មានស្តីពីនិយោជិត
ចំនួននិយោជិត *
0
ប្រាក់ខែសរុប *
0
៣. ផ្នាកយីហោ/ផ្នាកផ្សាយពាណិជ្ជកម្ម
តើសហគ្រាសរបស់អ្នកបានលើកផ្នាកយីហោឬនៅ?
មិនមាន
មាន
៤. ការចាប់ផ្តើមសកម្មភាព
កាលបរិច្ឆេទធ្វើការផ្តត់ផ្គង់ទំនិញ ឬសេវាដំបូង? *
ផលរបរនៃការផ្តត់ផ្គង់ទំនិញ ឬសេវាក្នុងរយៈពេល ១២ខែកន្លងមក *
ចាប់ផ្តើមផលរបរនៃការផ្តត់ផ្គង់ទំនិញ ឬសេវាក្នុងរយៈពេល ១២ខែខាងមុន *
៥. អ្នកតំណាងក្នុងចាត់តាំង



ជំហានទី៥៖ ពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មាន, ចុចដាក់ស្នើ រួចបង់ប្រាក់





ប្រសិនជាឯកសារព័ត៌មានដែលបានផ្តល់ត្រឹមត្រូវពិតប្រាកដ និងគ្រប់គ្រាន់ ធុរជននឹងអាចទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងរយៈពេល ៨ថ្ងៃនៃថ្ងៃធ្វើការ។ ការបញ្ជូនត្រឡប់នឹងកើតឡើង ក្នុងករណីមានការផ្តល់ព័ត៌មាន និងឯកសារមិនត្រឹមត្រូវឬមិនគ្រប់គ្រាន់នៅក្នុងពាក្យស្នើសុំ។ រាល់ពាក្យស្នើសុំដែលត្រូវបានបញ្ជូនត្រលប់ មិនតម្រូវឱ្យអ្នកចុះបញ្ជីបង់ប្រាក់ជាលើកទី២នោះទេ។ នៅពេលដែលពាក្យស្នើសុំនោះត្រូវបានដាក់ស្នើម្តងទៀត ក្រោយពីអ្នកចុះបញ្ជីបានផ្តល់ព័ត៌មាន និងឯកសារតាមរយៈប្រព័ន្ធ ហើយពេលវេលាត្រួតពិនិត្យនឹងត្រូវរាប់សារឡើងវិញ។ ធុរជនក៏អាចស្វែងរកជំនួយពីក្រុមការងារគាំទ្របាន តាមរយៈមធ្យោបាយដូចជា៖

- ទំព័រហ្វេកប៊ុក: Online Business Registration Service
- ការជជែកតាម Live Chat
- អ៊ីម៉ែល: registrationservices@mef.gov.kh
- លេខទូរស័ព្ទ: ០៨១ ៨៨៨ ២៩៦ ។

2. សិទ្ធិទទួលបានក្រោយចុះបញ្ជី

ការចុះបញ្ជីអាជីវកម្មមិនត្រឹមត្រូវតែផ្តល់ភាពស្របច្បាប់ដល់អាជីវកម្មនោះទេ ប៉ុន្តែម្ចាស់អាជីវកម្ម/សហគ្រាសក៏អាចទទួលបានផលប្រយោជន៍ផ្សេងៗដូចខាងក្រោម។ ម្ចាស់អាជីវកម្ម/សហគ្រាសគួរតែចុះបញ្ជីអាជីវកម្ម ដើម្បីទាញយកនូវផលប្រយោជន៍ ក៏ដូចជាចូលរួមលើកកម្ពស់ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។



នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន៖



3. កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ

3.1 កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ
- ដាក់លិខិតប្រកាសសារពើពន្ធ និងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ
- បង់ពន្ធតាមកាលបរិច្ឆេទកំណត់
- កាន់កាប់ថែរក្សា និងត្រូវបង្ហាញបញ្ជីលិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ
- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទ ដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាល
- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ
- ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ

- ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធក្នុការបំពេញកាតព្វកិច្ច។

3.2 សិទ្ធិរបស់អ្នកជាប់ពន្ធ

- ទទួលបានការរក្សាទុកជាសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយពន្យល់ណែនាំឱ្យបានយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តកាតព្វកិច្ចសារពើពន្ធ
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធតាមការជ្រើសរើស ដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ
- ទទួលបានការអនុវត្តដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ
- ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ។

4. ការបញ្ជូនរបាយការណ៍សារពើពន្ធ: អាជីវកម្មអនឡាញត្រូវតែបញ្ជូនរបាយការណ៍សារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ។ អ្នកប្រកបអាជីវកម្មអនឡាញ ត្រូវកាន់កាប់បញ្ជីគណនេយ្យសាមញ្ញដើម្បីជួយសម្រួលដល់អាជីវកម្មតូចៗ លក្ខណៈគ្រួសារ ក្នុងការកត់ត្រាប្រតិបត្តិការប្រចាំថ្ងៃ ហើយបញ្ជីនេះរួមមាន បញ្ជីទិញប្រចាំថ្ងៃ បញ្ជីលក់ប្រចាំថ្ងៃ និងបញ្ជីស្តុកទំនិញ ហើយត្រូវអនុវត្តកាតព្វកិច្ចតាមច្បាប់ស្តីពីសារពើពន្ធ។ ការកត់ត្រាត្រូវផ្អែកលើវិក្កយបត្រ យ៉ាងយូរត្រឹម៧ថ្ងៃមុន/ក្រោយការប្រគល់ទំនិញឬសេវានៅពេលទទួលការផ្តត់ផ្គង់(ទិញ)ឬនៅពេលធ្វើការផ្តត់ផ្គង់(លក់)។

- **បញ្ជីទិញប្រចាំថ្ងៃ** (Purchase Day Book): គឺជាកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រាជាប្រចាំថ្ងៃនូវរាល់ចំណាយដែលបានកើតឡើងក្នុងគោលដៅប្រកបអាជីវកម្មរបស់ខ្លួនដូចជា៖
  - ចំណាយទៅលើទំនិញសម្រាប់លក់ (Goods for Sales)
  - ចំណាយលើទ្រព្យអចលកម្ម សម្រាប់ប្រើប្រាស់ក្នុងការប្រកបអាជីវកម្ម (Fixed Assets) (លើកលែងតែដីធ្លី អគារ គូប និងរថយន្តទេសចរណ៍)
  - ចំណាយបុគ្គលិក (Wages and Salaries)
  - ចំណាយទឹក-ភ្លើង ប្រេង និងថាមពល (Utilities, Gasoline and Gas)
  - ចំណាយលើការជួល (Rental)
  - ចំណាយលើសេវា (Services)
  - ចំណាយផ្សេងៗដែលក្រៅពីចំណាយខាងលើ។
- **បញ្ជីលក់ប្រចាំថ្ងៃ** (Sale Day Book): គឺជាកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រាជាប្រចាំថ្ងៃនូវរាល់ប្រតិបត្តិការនៃការផ្តត់ផ្គង់ទំនិញឬសេវា៖

-ទំនិញដែលមានតម្លៃខ្ពស់ (១ឯកតាចាប់ពី៥០ដុល្លារឡើងទៅ) ត្រូវកត់ត្រាតាមវិក្កយបត្រដែលបានចេញឱ្យអតិថិជននីមួយៗ

-ទំនិញដែលលក់រាយឬទំនិញច្រើនមុខលើវិក្កយបត្រតែមួយ អ្នកជាប់ពន្ធអាចកត់ត្រាការ លក់សរុបប្រចាំថ្ងៃ។

❖ **បញ្ជីស្តុកទំនិញ** (Inventory Book): គឺកំណត់ត្រាដែលអ្នកជាប់ពន្ធត្រូវធ្វើការកត់ត្រានូវព័ត៌មានមួយចំនួនទាក់ទិនទៅនឹងស្តុកទំនិញដើមគ្រា ទំនិញដែលបានទិញក្នុងគ្រា និងស្តុកទំនិញចុងគ្រា។

5. ការដាក់លិខិតប្រកាសពន្ធ និងការបង់ពន្ធ: អាជីវកម្មអនឡាញត្រូវតែដាក់លិខិតប្រកាសពន្ធ បង់ពន្ធតាមអត្រា និងតាមកាលបរិច្ឆេទដែលបានកំណត់ដោយច្បាប់ពន្ធដារ។

***ពន្ធប្រចាំខែសំខាន់ៗរួមមាន៖**

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖ ប្រាក់រំដោះពន្ធនេះត្រូវបង់ជារៀងរាល់ខែ តាមអត្រា ១%នៃផលរបររួមទាំងអាករនានា លើកលែងអាករលើតម្លៃបន្ថែម
- អាករលើតម្លៃបន្ថែម៖ ត្រូវបង់សម្រាប់ខែនីមួយៗ បានអនុញ្ញាតជាឥណទានអាករលើធាតុចូល ៨០% សម្រាប់កាត់កងនឹងអាករលើធាតុចេញ ទោះមានឬគ្មានវិក្កយបត្របញ្ជាក់
- ពន្ធកាត់ទុកលើការជួល៖ អ្នកជាប់ពន្ធត្រូវបានអនុគ្រោះពីកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក លើកលែងតែពន្ធកាត់ទុកលើថ្លៃឈ្នួលលើចលនទ្រព្យ និងអចលនទ្រព្យ សម្រាប់អត្រាពន្ធ ១០%
- ពន្ធលើប្រាក់ប៉ៃវ៉ាត្ស៖ សម្រាប់សហគ្រាសដែលមានបុគ្គលិកត្រូវជាប់ពន្ធ

អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធប្រចាំខែចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២០ នៃខែបន្ទាប់នៅអគ្គនាយកដ្ឋានពន្ធដារឬដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធ GDT Tax Pre-filing App។

***ពន្ធប្រចាំឆ្នាំសំខាន់ៗរួមមាន៖**

- ពន្ធប៉ាតង់៖ ៤០ម៉ឺនរៀល ក្នុង១ឆ្នាំ សម្រាប់១សកម្មភាព
- ពន្ធលើប្រាក់ចំណូល៖ ការគណនាប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំណាមួយ ត្រូវយកប្រាក់ចំណូលសរុបប្រចាំឆ្នាំនោះ ដកថ្លៃដើមទំនិញឬសេវាដែលបានលក់ ដកចំណាយចរន្ត ដករំលស់ទ្រព្យអចលកម្ម។ ឯអត្រាពន្ធត្រូវអនុវត្ត តាមអត្រាពន្ធកំណើនតាមថ្នាក់ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ពន្ធអប្បបរមា ៖ កំណត់តាមអត្រា ១% លើផលរបរប្រចាំឆ្នាំរួមទាំងអាករនានា លើកលែងអាករលើតម្លៃបន្ថែម (ក្នុងករណីកាន់បញ្ជីគណនេយ្យមិនបានត្រឹមត្រូវ)។

6. ការបង់ពន្ធតាមអ៊ីនធឺណេត: អាជីវកម្មអនឡាញអាចបង់ពន្ធតាមប្រព័ន្ធអ៊ីនធឺណេត ដោយប្រើប្រាស់គណនីធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយនឹងនាយកដ្ឋានពន្ធដារ។

7. ការផ្តល់សេវាកម្មអនឡាញ: នាយកដ្ឋានពន្ធដារផ្តល់សេវាកម្មអនឡាញ ដើម្បីជួយអាជីវកម្មក្នុងការបញ្ជូនរបាយការណ៍ និងបង់ពន្ធបានងាយស្រួល។

8. ការត្រួតពិនិត្យ និងការតាមដាន: នាយកដ្ឋានពន្ធដារអាចធ្វើការត្រួតពិនិត្យ និងការតាមដាន ដើម្បីធានាថាអាជីវកម្មអនឡាញបានបំពេញកាតព្វកិច្ចបង់ពន្ធរបស់ខ្លួនត្រឹមត្រូវ។

៣. សន្និដ្ឋាន

ភាគច្រើនអាជីវកម្មអនឡាញមួយចំនួនធំ មិនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅរដ្ឋបាលសារពើពន្ធ ហើយមិនបានបង់ពន្ធជូនរដ្ឋនោះទេ ដែលប្រហែលមកពីអ្នកប្រកបអាជីវកម្មអនឡាញទាំងនោះគិតថា វាគ្រាន់តែជាមុខរបរលក់ដូរបន្តិចបន្តួចជាលក្ខណៈគ្រួសារឬគ្រាន់តែជាការលក់ក្នុងការផ្ទុសផ្សព្វផ្សាយនិងឡាយស៍ក្នុងប្រព័ន្ធSocial Mediaតែប៉ុណ្ណោះ ដែលមិនចាំបាច់ទៅចុះបញ្ជី ហើយបង់ពន្ធដូចគ្នា និងអាចបណ្តាលមកពីមិនបានយល់ដឹងអំពីការចុះបញ្ជី និងការបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធ។

ដោយឃើញហេតុនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រកាសកាលពីខែមីនា ឆ្នាំ២០២០ ប៉ុន្មានឆ្នាំកន្លងមកនេះថា រាល់សកម្មភាពសេដ្ឋកិច្ចដែលកើតឡើង១៥ថ្ងៃ គ្រប់សហគ្រាសអ្នកជាប់ពន្ធធំ មធ្យម និងតូចមិនថាអាជីវកម្មអនឡាញក្តី ត្រូវតែមកចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធទាំងអស់ តាមមាត្រា២០៣នៃច្បាប់សារពើពន្ធ ព្រោះវាគឺជាកាតព្វកិច្ចការចូលរួមបង់ពន្ធរបស់សហគ្រាស អ្នកប្រកបអាជីវកម្មអនឡាញ និងប្រជាពលរដ្ឋគ្រប់រូប ដែលជាចំណូលជាតិដ៏សំខាន់ ដើម្បីកសាងប្រទេសជាតិទាំងមូល។ សរុបមកវិញការយកពន្ធពីអាជីវកម្មអនឡាញគឺចាំបាច់ណាស់សម្រាប់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវភាពយុត្តិធម៌ ការបង្កើនប្រាក់ចំណូល និងការការពារការគេចវេសពន្ធក្នុងចំណោមហេតុផលផ្សេងទៀត។

ឯកសារយោង

១. វិទ្យាស្ថាន វ៉ាន់ដា. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១ ទំព័រទី២ ១៨៨ទំព័រ

២. វិទ្យាស្ថាន វ៉ាន់ដា. (2024). *ច្បាប់ពន្ធដារកម្ពុជា* បោះពុម្ពលើកទី១ ទំព័រទី១៣ ១៨៨ទំព័រ

៣. Cambridge Dictionary. https://dictionary.cambridge.org/dictionary/english/online

៤. ខេមបូហ្វាយនែន. (2021, August 01). *អាជីវកម្មអនឡាញ(Online Business) និងអាជីវកម្មបែបផ្ទាល់ (Physical Business)*: https://www.facebook.com/CamboFinance/posts/1149514835543244

៥. Freshnewsasia. អនុសាសន៍លោកគង់ រ៉ាបុល. (2020, March 12). *អ្នកលក់ Online ត្រូវមកចុះបញ្ជីពន្ធដារ ស្របតាមច្បាប់សារពើពន្ធ*: https://m.freshnewsasia.com/index.php/en/localnews/151322-2020-03-12-09-09-11

៦. Cambizian. (2020, June 12). *អាជីវកម្មតាម Online ត្រូវចុះបញ្ជី និងបង់ពន្ធ* https://shorturl.at/qs0uX

៧. ព្រះរាជក្រមលេខនស/រកម/១១១៩/០១៧. (2020, May 02). *ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*: https://data.opendevelopmentcambodia.net/km/laws_record/law-on-e-commerce

៨. ខេមបូណូមីស. ខន រ៉ែណា. (2014, July 21). *ក្រសួងពាណិជ្ជកម្មលើកលែងការចុះបញ្ជីសម្រាប់អាជីវកម្មអនឡាញ៦ប្រភេទ*: https://cambonomist.com/news/ministry-of-commerce-exempts-registration-for-six-types-of-online-businesses

៩. វិទ្យាស្ថាន វ៉ាន់ដា. (2022). *គណនេយ្យអនុវត្តន៍ និងពន្ធ* ភាគ១ បោះពុម្ពលើកទី៣ ទំព័រទី៣ ១៩០ទំព័រ

១០. ព្រះរាជក្រមលេខនស.រកម.០៥២៣.០០៤. (2023, May 16). *ច្បាប់ស្តីពីសារពើពន្ធ* មាត្រា២០៣

១១. អគ្គនាយកដ្ឋានពន្ធដារ. (2021, September 11). *ព័ត៌មានលម្អិតស្តីពី កាតព្វកិច្ចសារពើពន្ធអ្នកជាប់ពន្ធ ភ្ជាប* :https://www.tax.gov.kh/km/content-detail/ry2Gj4955067300099

១២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (2021, January 12). *ប្រកាស ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាម រយៈស្វ័យប្រកាស* : https://www.tax.gov.kh

១៣. សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច. (2022, September 20). *របៀបចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន*: https://shorturl.at/GQOXO

១៤. សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច. (2023). *សៀវភៅមគ្គុទេសក៍ដំណើរការចុះបញ្ជីអាជីកម្មតាមប្រព័ន្ធអនឡាញ*: https://registrationservices.gov.kh/media/2024/02/E-commerce-Guideline-Book.pdf

១៥. វិទ្យាស្ថាន វ៉ាន់ដា. (2022). *គណនេយ្យអនុវត្តន៍ និងពន្ធ* ភាគ៣ បោះពុម្ពលើកទី៣ ទំព័រទី១៣៩ សរុប ២០២ទំព័រ

ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត
The Importance of Financial Management for Decision Making

ហុង ម៉ុនថន
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម និងគ្រប់គ្រងពាណិជ្ជកម្ម
គ្រូ គណនេយ្យ

មូលន័យសង្ខេប

ការស្រាវជ្រាវនេះ មានគោលបំណងទៅលើ ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត ពិតជាមានផលប្រយោជន៍ខ្លាំងណាស់សម្រាប់អ្នកគ្រប់គ្រងហិរញ្ញវត្ថុនានា។ ពួកគេតែងតែខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការចំណាយលើលទ្ធកម្មហិរញ្ញវត្ថុ និងប្រើប្រាស់វាក្នុងលក្ខណៈចំណេញច្រើនបំផុត ដូចជា ការសម្រេចចិត្តវិនិយោគ ការសម្រេចចិត្តលើការផ្តល់ហិរញ្ញប្បទាន និងការសម្រេចចិត្តភាគលាភ។ គោលដៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ គួរតែត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដើម្បីជួយសម្រេចចិត្តនូវគោលបំណងនៃការធ្វើឱ្យកើនទ្រព្យ និងការរកប្រាក់ចំណេញបានច្រើនបំផុត។ នីតិវិធីទាំងនេះត្រូវបានគាំទ្រដោយសំណុំនៃគោលការណ៍យុទ្ធសាស្ត្រដែលបានរចនាឡើង ដើម្បីណែនាំអង្គភាពក្នុងការសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុ កំណើន និងនិរន្តរភាព។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុដ៏រឹងមាំអាជីវកម្មអាចបែងចែកធនធានប្រកបដោយប្រសិទ្ធភាព និងទាញយកប្រយោជន៍ពីឱកាសនៅក្នុងទីផ្សារនាពេលបច្ចុប្បន្ន។

ការស្រាវជ្រាវនេះ ត្រូវបានប្រើតាមវិធីសាស្ត្រតាមបែបគុណវិស័យ ដោយផ្តោតជាចម្បងលើការវិភាគទិន្នន័យបន្ទាប់បន្សំ។ ការប្រមូលទិន្នន័យមកពី សៀវភៅវិទ្យាស្ថាន វ៉ាន់ដា Financial Management Part 1 និងគេហទំព័រ The Importance of Financial Management ផ្តោតលើសារៈសំខាន់ការគ្រប់គ្រងហិរញ្ញវត្ថុ, The- Importance of Financial Decision Making ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព, Oboloo FAQ’s ផ្តោតលើសារៈសំខាន់ និងផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ, What is Financial Management Procedure? ផ្តោតលើនីតិវិធីការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ។

សរុបសេចក្តីមក ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត វាពិតជាសំខាន់ខ្លាំងណាស់សម្រាប់អង្គភាពអាជីវកម្មនីមួយៗ។ បើអង្គភាពមួយមានការរៀបចំ និងមានវិធីសាស្ត្រគ្រប់គ្រងបានល្អទៅលើហិរញ្ញវត្ថុនោះ នឹងមានភាពល្អប្រសើរ ជាពិសេសអាចបង្កើនការប្រកួតប្រជែងក្នុងទីផ្សារ និងដណ្តើមបាន កេរ្តិ៍ឈ្មោះជាក់ជាមិនខាន នៅក្នុងទីផ្សារសេរីនាពេលបច្ចុប្បន្ន។ ដូច្នេះ អង្គភាពត្រូវតែយកចិត្តទុកដាក់ និងខិតខំពង្រឹងសមត្ថភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានល្អប្រសើរ។

១ សេចក្តីផ្តើម

ក្នុងការប្រកបអាជីវកម្ម យើងតែងតែប្រាថ្នាចង់បានភាពជោគជ័យ និងប្រាក់ចំណេញជាអតិបរមា។ ដើម្បីដំណើរការអាជីវកម្មទទួលបានជោគជ័យ យើងត្រូវមានការយល់ដឹងអំពី គោលការណ៍គណនេយ្យ ស្តង់ដា ប្រតិបត្តិការអាជីវកម្ម សេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុជាមុនសិន។ ក្នុងនោះ ការគ្រប់គ្រងហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការអាជីវកម្ម ព្រោះការគ្រប់គ្រងហិរញ្ញវត្ថុសំដៅទៅលើការរៀបចំផែនការយុទ្ធសាស្ត្រ ការរៀបចំ ការដឹកនាំ និងការត្រួតពិនិត្យរាល់សកម្មភាពហិរញ្ញវត្ថុនៅក្នុងអង្គភាពអាជីវកម្មមួយ។

ប្រសិទ្ធភាពនៃអ្នកគ្រប់គ្រងហិរញ្ញវត្ថុកើតមានទៅបាន គឺអាស្រ័យដោយមានការកំណត់គោលដៅច្បាស់លាស់នៅពេលយើងសម្រេចចិត្តធ្វើអ្វីមួយ ដើម្បីកំណត់តាមស្តង់ដាសម្រាប់អនុវត្តន៍ ហើយការគ្រប់គ្រងហិរញ្ញវត្ថុ ទាក់ទងនឹងការរៀបចំ ការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុជាដើម ដើម្បីធានាដល់ម្ចាស់ភាគហ៊ុនទទួលបានប្រាក់ចំណេញពីការវិនិយោគរបស់ពួកគេ បង្កើតឱកាសការវិនិយោគ និងផ្តល់សុវត្ថិភាពក្នុងការវិនិយោគ។ ជារៀងរាល់ថ្ងៃអ្នកគ្រប់គ្រងទាំងអស់ ឬម្ចាស់សហគ្រាសតែងតែធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទិននឹងហិរញ្ញវត្ថុជាប្រចាំ ដោយផ្អែកតាមទិន្នន័យដែលទទួលបានពីផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ អ្នកតែងតែផ្តល់សេចក្តីជឿទុកចិត្ត និងសេចក្តីជឿជាក់ទាំងស្រុងលើការទទួលខុសត្រូវ និងវិជ្ជាជីវៈរបស់បុគ្គលិកគណនេយ្យ និងហិរញ្ញវត្ថុ ក៏ប៉ុន្តែ ក្នុងនាមជាអ្នកគ្រប់គ្រង ឬម្ចាស់សហគ្រាស អ្នកគួរតែត្រួតពិនិត្យលើគុណភាពនិងភាពត្រឹមត្រូវនៃទិន្នន័យទាំងនោះ ព្រោះជាលទ្ធផលហិរញ្ញវត្ថុធុរកិច្ចរបស់អ្នក។

ការគ្រប់គ្រងហិរញ្ញវត្ថុ ជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តន៍គោលគំនិតនៃការគ្រប់គ្រងទូទៅរបស់អង្គភាពអាជីវកម្ម។ ដោយយោងតាមទស្សនៈខាងលើ ទើបលើកយកប្រធានបទ "ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត " សំណួរពីរចោទសួរដូចខាងក្រោម៖

១. តើការគ្រប់គ្រងហិរញ្ញវត្ថុមានផលប្រយោជន៍សម្រាប់ធ្វើការសម្រេចចិត្តអ្វីខ្លះ?

២. តើមាននីតិវិធីអ្វីខ្លះ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព?

១.២ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ សម្រាប់រៀបរាប់ពីផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត ការប្រមូលទិន្នន័យធ្វើឡើងដោយផ្អែកសំណួរពីរខាងលើ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ដោយធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ដូចជា: សៀវភៅ Financial Management Part 1 នៃវិទ្យាស្ថាន វ៉ាន់ដា (ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុ), និងគេហទំព័រដូចជា: មិត្តនិស្សិត (ស្តីពីការគ្រប់គ្រង), What Does Finance Mean? Its History, Types, and Importance Explained (ផ្តោតលើប្រវត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុ), The Importance of Financial Management(ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុ) និង Oboloo FAQ's (ផ្តោតលើសារៈសំខាន់ និងផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ)។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ពីគេហទំព័រដូចជា: The Importance

of Financial Decision Making (ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព), What is Financial Management Procedure? (ផ្តោតលើនីតិវិធីការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព)។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

ការគ្រប់គ្រង (Management)គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្ស និងធនធានដទៃទៀត ដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[1]។

ហិរញ្ញវត្ថុ (Finance) ត្រូវបានកំណត់ថា ជាការគ្រប់គ្រងលុយ ហើយរួមបញ្ចូលសកម្មភាពដូចជា ការវិនិយោគ ការខ្ចីប្រាក់ ការផ្តល់ប្រាក់កម្ចី ថវិកា ការសន្សំ និងការព្យាករណ៍[2]។

ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management) គឺជាការរៀបចំផែនការ ការរៀបចំដឹកនាំ និងគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុ ដូចជា ការបង្កើត និងការប្រើប្រាស់មូលនិធិរបស់សហគ្រាស[3]។

គោលការណ៍ (Principle) គឺជាគោលការណ៍ សេចក្ដីពិតជាមូលដ្ឋាន ឬសំណើដែលដើរតួជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធនៃជំនឿ ឬអាកប្បកិរិយា ឬខ្សែសង្វាក់នៃហេតុផល[4]។

ប្រសិទ្ធភាព (Efficiency) គឺជាប្រសិទ្ធភាព ជាគំនិតដែលអាចវាស់វែងបាន អាចកំណត់បានដោយប្រើសមាមាត្រនៃទិន្នផលដែលមានប្រយោជន៍ដល់ការបញ្ចូលសរុប[5]។

នីតិវិធី (Procedure) គឺជាបែបបទផ្លូវការធ្វើអ្វីមួយ ស៊ីរីនៃសកម្មដែលប្រព្រឹត្តទៅតាមលំដាប់លំដោយមួយចំនួន[6]។

១.៣.២ ប្រវត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ ជាការសិក្សាអំពីទ្រឹស្ដី និងការអនុវត្តខុសពីវិស័យសេដ្ឋកិច្ច បានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០ និងឆ្នាំ១៩៥០ ជាមួយនឹងស្នាដៃរបស់ Harry Markowitz, William F. Sharpe, Fischer Black, Myron Scholes ដើម្បីដាក់ឈ្មោះមួយចំនួន។ វិស័យហិរញ្ញវត្ថុ ជាពិសេស ដូចជា ធនាគារ ការផ្តល់ប្រាក់កម្ចី និងការវិនិយោគ[7]។

២. ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

នៅក្នុងអង្គភាពមួយ អ្នកគ្រប់គ្រងតែងតែខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការចំណាយលើលទ្ធកម្មហិរញ្ញវត្ថុ និងប្រើប្រាស់វាក្នុងលក្ខណៈចំណេញច្រើនបំផុត។

---

[1] Daily Archives: (2011, May,31) *មិត្តនិស្សិត*. https://clubniset.wordpress.com/2011/05/31

[2] Davis, H. A. (2005). The Definition of Structured Finance: Results from a Survey. *Journal of Structured Finance*, *11*(3), 5. https://corporatefinanceinstitute.com/resources/wealth-management/what-is-finance-definition/

[3] វិទ្យាស្ថាន វ៉ាន់ដា(២០២១).*Financial management part I* បោះពុម្ពលើកទី៤ ទំព័រទី៣

[4] Sunstein, C. R. (1994). The anticaste principle. *Michigan Law Review*, *92*(8), 2410-2455. https://en.wikipedia.org/wiki/Principle

[5] Banton, C., Boyle, M. J., & Schmitt, K. R. (2022). Efficiency: What it means in economics, the formula to measure it. *G uide To Microeconomics, https://www. investopedia. com/terms/e/efficienc y. asp*.

[6] The Sun Dictionary (2023,May,2) *នីតិវិធី_Procedure*. https://www.youtube.com/watch?v=gz4W4j46zjM

[7] Cassis, Y. (Ed.). (2002). *Finance and* financiers *in European history 1880-1960*. Cambridge University Press. https://www.investopedia.com/terms/f/finance.asp.

រចនាសម្ព័ន្ធនៃការសម្រេចចិត្តទាំងអស់នោះមានដូចខាងក្រោម៖



❖ **ការសម្រេចចិត្តវិនិយោគ (Investment Decision)**

អ្នកគ្រប់គ្រងចាំបាច់ត្រូវសម្រេចចិត្តលើចំនួនទឹកប្រាក់នៃការវិនិយោគ ដែលអាចរកបានក្រៅពីហិរញ្ញវត្ថុ ដែលមានស្រាប់ដោយផ្អែកលើរយៈពេលវែង និងរយៈពេលខ្លី។ ការសម្រេចចិត្តវិនិយោគមានពីរប្រភេទ៖

-ការសម្រេចចិត្តវិនិយោគរយៈពេលវែង ឬ Capital Budgeting គឺជាប្រាក់ដែលបានចូលរួមក្នុង Capital Budgeting ទៅលើទ្រព្យសកម្ម។

-ការសម្រេចចិត្តវិនិយោគរយៈពេលខ្លី ឬ ក៏ការគ្រប់គ្រងទៅលើ Working Capital គឺជាប្រាក់ដែលបានចូលរួមក្នុង Working Capital ទៅលើ Current Assets។

❖ **ការសម្រេចចិត្តលើការផ្តល់ហិរញ្ញប្បទាន (Financing Decision)**

អ្នកគ្រប់គ្រង ក៏ធ្វើការសម្រេចចិត្តទាក់ទងនឹងការបង្កើនហិរញ្ញវត្ថុពីប្រភពរយៈពេលវែង និងប្រភពរយៈពេលខ្លី។ ការសម្រេចចិត្តលើការផ្តល់ហិរញ្ញប្បទានមានពីរប្រភព៖

-ការសម្រេចចិត្តលើផែនការហិរញ្ញវត្ថុ (Financial Planning Decisions) ដែលទាក់ទងនឹងការប៉ាន់ប្រមាណប្រភព និងការអនុវត្តមូលនិធិ។ វាមានន័យការប៉ាន់ស្មានជាមុន នូវតម្រូវការហិរញ្ញវត្ថុរបស់អង្គការមួយ ដើម្បីទទួលបានហិរញ្ញវត្ថុគ្រប់គ្រាន់។ គោលបំណងចម្បងនៃការធ្វើផែនការហិរញ្ញវត្ថុ គឺដើម្បីធ្វើផែនការ និងធានាថាមូលនិធិអាចរកបាននិងនៅពេលចាំបាច់។

-ការសម្រេចចិត្តលើរចនាសម្ព័ន្ធមូលធន (Capital Structure Decisions) ដែលពាក់ព័ន្ធនឹងការកំណត់ប្រភពថវិកា។ ពួកគេក៏ពាក់ព័ន្ធនឹងការសម្រេចចិត្តទាក់ទងនិងការជ្រើសរើសប្រភពខាងក្រៅ ដូចជាបោះប័ណ្ណភាគហ៊ុន មូលបត្របំណុល ការខ្ចីប្រាក់ពីធនាគារ ឬប្រភពផ្ទៃក្នុង ដូចជា ទុនបម្រុង។

❖ **ការសម្រេចចិត្តភាគលាភ (Dividend Decisions)**

ទាំងនេះពាក់ព័ន្ធនឹងការសម្រេចចិត្តដែលទាក់ទង និងចំណែកនៃប្រាក់ចំណេញដែលនឹងត្រូវចែកចាយជាភាគលាភ។ ម្ចាស់ភាគហ៊ុនតែងតែទាមទារភាគលាភខ្ពស់ ចំណែកឯអ្នកគ្រប់គ្រងចង់រក្សាប្រាក់ចំណេញសម្រាប់តម្រូវការអាជីវកម្ម។ ដូច្នេះ គឺជាការសម្រេចចិត្តអ្នកគ្រប់គ្រងដ៏ស្មុគស្មាញ។

❖ **គោលដៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ**

គោលដៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ គួរតែត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដើម្បីជួយសម្រេចចិត្តនូវគោលបំណងនៃការធ្វើទ្រព្យ និងការរកប្រាក់ចំណេញបានច្រើនបំផុត។ គោលដៅហិរញ្ញវត្ថុអាចត្រូវបានបញ្ជាក់ថា ជាការបង្កើនប្រាក់ចំណេញក្នុងរយៈពេលខ្លី និងកាត់បន្ថយហានិភ័យ។

❖ សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ

ទម្រង់នៃការគ្រប់គ្រងនេះ គឺមានសារៈសំខាន់សម្រាប់ហេតុផលផ្សេងៗដូចជា៖

- ជួយអង្គភាពក្នុងការរៀបចំផែនការហិរញ្ញវត្ថុ
- ជួយអង្គភាពក្នុងការរៀបចំផែនការ និងការទិញមូលនិធិ
- ជួយអង្គភាពក្នុងការប្រើប្រាស់ និងបែងចែកមូលនិធិដែលទទួលបាន ឬប្រកបដោយប្រសិទ្ធភាព
- ជួយអង្គភាពក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុសំខាន់ៗ
- ជួយធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណេញរបស់អង្គភាព
- បង្កើនតម្លៃរួមនៃក្រុមហ៊ុន
- ផ្តល់ស្ថិរភាពសេដ្ឋកិច្ច លើកទឹកចិត្តបុគ្គលិកសន្សំប្រាក់ដែលជួយពួកគេក្នុងការរៀបចំផែនការហិរញ្ញវត្ថុផ្ទាល់ខ្លួន។

ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាសកម្មភាពសំខាន់នៃអាជីវកម្មមួយ ហើយវាភ្ជាប់មកជាមួយអត្ថប្រយោជន៍ដូចជា៖

-ការគ្រប់គ្រងហិរញ្ញវត្ថុ ក្រុមហ៊ុនអាចរក្សាលំហូរសាច់ប្រាក់បានត្រឹមត្រូវដោយកាត់បន្ថយការចំណាយ និងបង្កើនប្រាក់ចំណេញអតិបរមា។ តាមរយៈការតាមដានប្រតិបត្តិការហិរញ្ញវត្ថុ អាជីវកម្មអាចកំណត់តំបន់ដែលពួកគេកំពុងចំណាយប្រាក់ច្រើនពេក និងកែសម្រួលថវិការបស់ពួកគេតាមតម្រូវការ។

-ការគ្រប់គ្រងហិរញ្ញវត្ថុ ជួយក្រុមហ៊ុនធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងអំពីការវិនិយោគមិនថាចង់ពង្រីកអាជីវកម្ម ឬវិនិយោគលើបច្ចេកវិទ្យាថ្មីទេ ការយល់ដឹងអំពីការចំណាយដែលពាក់ព័ន្ធគឺមានសារៈសំខាន់សម្រាប់ការសម្រេចចិត្តត្រឹមត្រូវដែលនឹងផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនក្នុងរយៈពេលយូរ។

-ការមានការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុខ្លាំង ធ្វើឱ្យអាជីវកម្មកាន់តែទាក់ទាញអ្នកវិនិយោគ និងអ្នកខ្ចី។ វិនិយោគិនចង់យើញថា អាជីវកម្មមួយមានការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនមុនពេលធ្វើការវិនិយោគ ។

-ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព នាំឱ្យមានការព្យាករណ៍ និងផែនការកាន់តែប្រសើរឡើង ដែលធានានូវភាពជោគជ័យរយៈពេលវែងសម្រាប់អាជីវកម្ម ជាមួយនឹងទិន្នន័យត្រឹមត្រូវនៅលើដៃអំពីលំហូរសាច់ប្រាក់ ចំណូល និងចំណាយតាមពេលវេលា។ អាជីវកម្មអាចប្រមើលមើលនិន្នាការនាពេលអនាគតនៅក្នុងលក្ខខណ្ឌនៃការលក់ ឬទីផ្សារ និងរៀបចំផែនការបានត្រឹមត្រូវ។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

នៅពេលដែលក្រុមហ៊ុនរុករកភាពស្មុគស្មាញនៃទិដ្ឋភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ ការយល់ដឹងនិងការអនុវត្តនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់ជាងពេលណាទាំងអស់។ នៅក្នុងខ្លឹមសាររបស់វា នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុរួមបញ្ចូលនូវវិធីសាស្ត្រជាប្រព័ន្ធ ដែលអង្គភាពត្រូវធ្វើឡើង ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួន។ វាបម្រើជាក្របខណ្ឌដ៏ទូលំទូលាយដែលគ្រប់គ្រងពីរបៀបដែលធនធានហិរញ្ញវត្ថុត្រូវបានបែងចែក គ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព។ ចាប់ពីការរៀបចំ និងការព្យាករណ៍រហូតដល់ការវាយតម្លៃហានិភ័យ និងការវិភាគ

ការវិនិយោគគ្រប់ផ្នែកនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវស្ថិតនៅក្រោមការតាមដាននៃនីតិវិធីគ្រប់គ្រងរបស់ខ្លួន។

យុទ្ធសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុ៖ នីតិវិធីទាំងនេះត្រូវបានគាំទ្រដោយសំណុំនៃគោលការណ៍យុទ្ធសាស្ត្រដែលបានរចនាឡើងដើម្បីណែនាំអង្គភាពក្នុងការសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុ កំណើន និងនិរន្តរភាព។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុដ៏រឹងមាំ អាជីវកម្មអាចបែងចែកធនធានប្រកបដោយប្រសិទ្ធភាព កាត់បន្ថយហានិភ័យ និងទាញយកប្រយោជន៍ពីឱកាសនៅក្នុងទីផ្សារនាពេលបច្ចុប្បន្ន។

ការគ្រប់គ្រងដំណើរការហិរញ្ញវត្ថុ៖ ដំណើរការកណ្តាលនៃការគ្រប់គ្រងហិរញ្ញវត្ថុគឺជាគោលគំនិតនៃការគ្រប់គ្រងដំណើរការហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការរៀបចំឯកសារជាប្រព័ន្ធ ការប្រតិបត្តិ និងការធ្វើឱ្យប្រសើរនៃដំណើរការហិរញ្ញវត្ថុនៅក្នុងស្ថាប័នមួយ។ តាមរយៈការសម្រួលលំហូរការងារ ការងារស្វ័យប្រវត្តិកម្ម និងការអនុវត្តការអនុវត្តល្អបំផុត ការគ្រប់គ្រងដំណើរការហិរញ្ញវត្ថុបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៅទូទាំងសកម្មភាពហិរញ្ញវត្ថុទាំងអស់។

ឧទាហរណ៍នៃនីតិវិធីហិរញ្ញវត្ថុ៖ ឧទាហរណ៍នៃនីតិវិធីហិរញ្ញវត្ថុរួមមានការអភិវឌ្ឍ និងការត្រួតពិនិត្យការគ្រប់គ្រងលំហូរសាច់ប្រាក់ របាយការណ៍ និងការវិភាគហិរញ្ញវត្ថុ ការត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាមតម្រូវការបទប្បញ្ញត្តិ។ នីតិវិធីនីមួយៗទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសុខភាពហិរញ្ញវត្ថុ និងសុចរិតភាពរបស់អង្គភាព ដឹកនាំដំណើរការធ្វើការសម្រេចចិត្ត និងការជូនដំណឹងអំពីគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រ។

មូលដ្ឋានគ្រឹះទាំង៣នៃការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុដើរតួនាទីជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់អង្គការ ដែលអនុញ្ញាតឱ្យអាជីវកម្មសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ពួកគេ រក្សាសុខភាពហិរញ្ញវត្ថុ និងរុករកភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច។ តាមរយៈការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុល្អ អាជីវកម្មអាចបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន កាត់បន្ថយហានិភ័យ និងទាញយកប្រយោជន៍ពីឱកាសសម្រាប់កំណើន។

ថវិកា៖ ជាស្នូលនៃការគ្រប់គ្រងហិរញ្ញវត្ថុ គឺជំណើរការរៀបចំថវិកា ដែលពាក់ព័ន្ធនឹងការធ្វើផែនការនិងការបែងចែកធនធានហិរញ្ញវត្ថុដល់សកម្មភាព និងគំនិតផ្តួចផ្តើមផ្សេងៗ។ តាមរយៈការបង្កើតថវិកាលម្អិត អាជីវកម្មអាចតាមដានប្រាក់ចំណូល និងការចំណាយរបស់ពួកគេ កំណត់តំបន់នៃឱកាស ឬកង្វល់ និងធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មាន ដើម្បីបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន។

ការគ្រប់គ្រងលំហូរសាច់ប្រាក់៖ ការគ្រប់គ្រងលំហូរសាច់ប្រាក់មានសារៈសំខាន់សម្រាប់ធានាសាច់ប្រាក់ងាយស្រួល និងដំណោះស្រាយនៃអាជីវកម្ម។ តាមរយៈការត្រួតពិនិត្យលំហូរសាច់ប្រាក់ចូល និងចេញ អង្គភាពនានាអាចប្រមើលមើលការខ្វះខាតសាច់ប្រាក់ បង្កើនប្រសិទ្ធភាពដើមទុនធ្វើការ និងធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ។

ការគ្រប់គ្រងហានិភ័យ៖ នៅក្នុងបរិយាកាសធុរកិច្ចដែលប្រែប្រួលនាពេលបច្ចុប្បន្ននេះ ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការការពារទ្រព្យសម្បត្តិ និងកាត់

បន្ថយការខាតបង់ផ្នែកហិរញ្ញវត្ថុ។ តាមរយៈការកំណត់អត្តសញ្ញាណ វាយតម្លៃ និងកាត់បន្ថយហានិភ័យអាជីវកម្មអាចការពារសុខភាពហិរញ្ញវត្ថុរបស់ពួកគេ និងទាញយកប្រយោជន៍ពីឱកាសសម្រាប់កំណើន។

៣. សន្និដ្ឋាន

ការគ្រប់គ្រងហិរញ្ញវត្ថុ ពិតជាសំខាន់ខ្លាំងណាស់សម្រាប់អង្គភាពអាជីវកម្មនីមួយៗ ដែលមិនអាចអត់វាបាន អង្គភាពត្រូវតែយកចិត្តទុកដាក់ និងខិតខំពង្រឹងសមត្ថភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ព្រោះថាវាមានទំនាក់ទំនងដល់ហិរញ្ញវត្ថុដែលជាសរសៃឈាមដ៏សំខាន់បំផុតនៃការគ្រប់គ្រងអាជីវកម្ម។ បើអង្គភាពមួយមានការរៀបចំ និងមានវិធីសាស្ត្រគ្រប់គ្រងបានល្អទៅលើហិរញ្ញវត្ថុនោះនឹងមានភាពល្អប្រសើរ ជាពិសេសអាចបង្កើនការប្រកួតប្រជែងក្នុងទីផ្សារ និងដណ្តើមបានកេរ្តិ៍ឈ្មោះជាក់ជាមិនខាន នៅក្នុងទីផ្សារសេរីនាពេលបច្ចុប្បន្ន។ ដូច្នេះ ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត វាពិតជាដើរតួយ៉ាងសំខាន់ណាស់មុនធ្វើការវិនិយោគ សម្រាប់អ្នកដែលមានគោលបំណងបើកអាជីវកម្ម ឬអ្នកដែលមានអាជីវកម្មក្នុងដៃរួចមកហើយ។

សរុបមកវិញ ផលប្រយោជន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត គឺជាការរៀបចំនិងកំណត់ទិសដៅហិរញ្ញវត្ថុ ដើម្បីយកទៅអនុវត្តក្នុងគោលបំណងធ្វើការកែលម្អរាល់ការគ្រប់គ្រងហិរញ្ញវត្ថុមួយចំនួន ធ្វើយ៉ាងណាឱ្យចំគោលដៅ សមហេតុផល មានប្រសិទ្ធភាព និងសមស្របតាមស្ថានភាពសេដ្ឋកិច្ចក្នុងអង្គភាព ជំរុញប្រាក់ចំណេញមានភាពប្រសើរឡើង និងបន្តនិរន្តរភាពរហូតដល់ពេលអនាគតផងដែរ។

ឯកសារយោង

១. វិទ្យាស្ថាន វ៉ាន់ដា.(២០២១). *Fianancial Mangement part I* . បោះពុម្ពលើកទី៤ ទំព័រ ៣,៤,៥ សរុប ៩៤ ទំព័រ

២. Staff,L.(2023).*The Importance of Financial Management*. Retrieved from https://www.lsbf.org.uk/blog/news/importance-of-financial-management/117410

៣. Etim Ima, E. *Oboloo FAQ's*. https://oboloo.com/blog/what-is-the-importance-of-using-financial-management-for-business-decisions/

៤. SRIVASTAVA, AAMAR (2024). *The Importance of Financial Decision Making.* https://www.linkedin.com/pulse/importance-financial-decision-making-aamar-3kqfc

៥. Knowledge Centre. (2024). *What is Financial Management Procedure?* https://beslick.com/what-is-financial-management-procedure/

៦. Daily Archives: (2011, May,31) *មិត្តនិស្សិត*. https://clubniset.wordpress.com/2011/05/31

៧. Davis, H. A. (2005). The Definition of Structured Finance: Results from a Survey. *Journal of Structured Finance*, *11*(3), 5. https://corporatefinanceinstitute.com/resources/wealth-management/what-is-finance-definition/

៨. Sunstein, C. R. (1994). The anticaste principle. *Michigan Law Review*, *92*(8), 2410-2455. https://en.wikipedia.org/wiki/Principle

៩. Banton, C., Boyle, M. J., & Schmitt, K. R. (2022). Efficiency: What it means in economics, the formula to measure it. *G uide To Microeconomics, https://www. investopedia. com/terms/e/efficienc y. asp*.

១០. Cassis, Y. (Ed.). (2002). *Finance and financiers in European history 1880-1960*. Cambridge University Press. https://www.investopedia.com/terms/f/finance.asp.

១១. The SUN Dictionary (2023,May,02). *នីតិវិធី_Procedure* https://www.youtube.com/watch?v=gz4W4j46zjM

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់

The Responsibility of Financial Statements for Users

ហុង កែវជារ៉ា
បរិញ្ញាបត្រជាន់ខ្ពស់ សវនកម្ម
គ្រូ គណនេយ្យ

មូលន័យសង្ខេប

គោលបំណងរបស់របាយការណ៍ហិរញ្ញវត្ថុ គឺឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួលស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ មុននឹងអ្នកប្រើប្រាស់យករបាយការណ៍ហិរញ្ញវត្ថុទៅអាន វិភាគ និងធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របាយការណ៍នោះត្រូវឆ្លងកាត់ការធ្វើសវនកម្មពីក្រុមហ៊ុនសវនកម្មឯករាជ្យ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវតាមស្តង់ដាជាមុនសិន។

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី **"ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់"**។ ការប្រមូលទិន្នន័យតាមរយៈសៀវភៅវិទ្យាស្ថាន វ៉ាន់ដា Intermediate Accounting part 3 ឆ្លុះបញ្ចាំងពីសមាសធាតុ និងមុខងាររបស់របាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសមាសធាតុចំនួន៥ គឺ របាយការណ៍តុល្យការ របាយការណ៍លទ្ធផល របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍បម្រែបម្រួលមូលធន និងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ហើយរបាយការណ៍នីមួយៗមានមុខងារផ្សេងៗគ្នា។ ចំណែកឯគេហទំព័រ KHEMSARITH ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលជាតម្រូវការរបស់អ្នកប្រើប្រាស់។ ម្យ៉ាងវិញទៀត សៀវភៅធម្មនុញ្ញភាពគណនេយ្យសម្រាប់រៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ បានឆ្លុះបញ្ចាំងពីការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់ ដើម្បីឱ្យកាន់តែទទួលបានទំនុកចិត្តពីអ្នកប្រើប្រាស់ ដូច្នេះក្រុមហ៊ុនត្រូវមានការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយគោរព តាមលក្ខខណ្ឌ ដូចជា របាយការណ៍ហិរញ្ញវត្ថុត្រូវមានភាពត្រឹមត្រូវនិងការពិតតម្លាភាព អនុលោមភាពតាមស្តង់ដា គណនេយ្យភាព និងការពិចារណាអំពីក្រមសីលធម៌ជាដើម។

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក ខ្ញុំយល់ឃើញថា របាយការណ៍ហិរញ្ញវត្ថុពិតមានផលប្រយោជន៍ណាស់ចំពោះអ្នកប្រើប្រាស់ ព្រោះថាអ្នកប្រើប្រាស់ទាំងអស់ត្រូវការរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីយកទៅអាន វិភាគ និងធ្វើការសម្រេចចិត្តមុននឹងដាក់ការវិនិយោគចូលក្រុមហ៊ុណាមួយ។ ប្រសិនបើអ្នកប្រើប្រាស់នោះមានការវិភាគ និងសម្រេចចិត្តត្រឹមត្រូវ ពួកគេនឹងទទួលបានលទ្ធផល និងអត្ថប្រយោជន៍ល្អពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះ។

១. សេចក្តីផ្តើម

បច្ចុប្បន្ននេះ យើងសង្កេតឃើញថា មានក្រុមហ៊ុនជាច្រើនបានបង្កើតឡើង និងបានធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការប្រកបអាជីវកម្ម ក្រុមហ៊ុនទាំងអស់ត្រូវកត់ត្រាប្រតិបត្តិការចូលទៅក្នុងបញ្ជីគណនេយ្ય ដើម្បីដំឡើងជារបាយការណ៍ហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ឱ្យទៅអ្នកប្រើប្រាស់អាន វិភាគ និងធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

របាយការណ៍ហិរញ្ញវត្ថុ ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាបានឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួលស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទទួលបាននូវការទុកចិត្តពីអ្នកប្រើប្រាស់ របាយការណ៍នោះត្រូវតែឆ្លងកាត់ការធ្វើសវនកម្មពីក្រុមហ៊ុនសវនកម្មឯករាជ្យ ដែលជាភាគីទីបីមិនពាក់ព័ន្ធនឹងក្រុមហ៊ុនឡើយ។ ក្នុងនាមជាអ្នកតំណាងក្រុមហ៊ុនត្រូវតែទទួលខុសត្រូវគ្រប់បែបយ៉ាងចំពោះអ្នកប្រើប្រាស់ និងចំពោះមុខច្បាប់។

ដោយយល់ឃើញថា របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ចំពោះក្រុមហ៊ុន និងអ្នកប្រើប្រាស់បែបនេះហើយ ទើបខ្ញុំលើកយកប្រធានបទ **"ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់"** មកសិក្សាស្រាវជ្រាវ និងមានចោទជាសំណួរចំនួនពីរ ដើម្បីបកស្រាយដូចខាងក្រោម៖

១. តើរបាយការណ៍ហិរញ្ញវត្ថុមានសមាសធាតុប៉ុន្មាន? គឺអ្វីខ្លះ? ហើយមានមុខងារ និងសារៈសំខាន់ដូចម្តេចសម្រាប់អ្នកប្រើប្រាស់?

២. តើក្រុមហ៊ុនត្រូវមានការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់យ៉ាងដូចម្តេច?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី "ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់"។ ការប្រមូលទិន្នន័យតាមរយៈសៀវភៅវិទ្យាស្ថាន វ៉ាន់ដា Intermediate Accounting Part 3 គេហទំព័រ KHEMSARITH និងសៀវភៅធម្មនុញ្ញភាពគណនេយ្យសម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីសៀវភៅវិទ្យាស្ថាន វ៉ាន់ដា Intermediate Accounting Part3 និងគេហទំព័រKHEMSARITH ដើម្បីគាំទ្រដល់សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងមុខងារ និងសារៈសំខាន់។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីសៀវភៅធម្មនុញ្ញភាពគណនេយ្យសម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហរិញ្ញវត្ថុ ដើម្បីគាំទ្រដល់ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

របាយការណ៍ហិរញ្ញវត្ថុ (Financial Statement) គឺជារបាយការណ៍ដែលបង្ហាញពីព័ត៌មានហិរញ្ញវត្ថុ ស្តីពីសកម្មភាពដែលបានធ្វើអាជីវកម្មកន្លងមក[1]។

អ្នកប្រើប្រាស់ (Users) គឺជាបុគ្គល ឬអង្គភាពដែលចូលរួមជាមួយផលិតផល សេវាកម្ម ឬជាប្រព័ន្ធមួយចំនួន ដូចជា ការប្រើប្រាស់វា ឬអន្តរកម្មជាមួយក្រុមហ៊ុន[2]។

ការទទួលខុសត្រូវ (Responsibility) គឺជាការងារដែលជាក់លាក់សម្រាប់បុគ្គលម្នាក់ៗ អាស្រ័យលើជំនាញ តួនាទី ឬចំណុចខ្លាំងរបស់ពួកគេ។ ការទទួលខុសត្រូវ គឺផ្តោតលើការងារមនុស្សគ្រប់រូបនៅក្នុងក្រុម គឺទទួលខុសត្រូវចំពោះកិច្ចការដែលបានផ្តល់ឱ្យ។ ទំនួលខុសត្រូវ ផ្តោតលើតួនាទីដែលបានកំណត់ក្នុងការពិពណ៌នាការងារ និងដំណើរការការងារ ដើម្បីសម្រេចឱ្យបាននូវផែនការ[3]។

២. ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុចំពោះអ្នកប្រើប្រាស់

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយប្រភេទដែលរៀបចំឡើងផ្អែកទៅតាមវិធីសាស្ត្រគណនេយ្យ ដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ នៅពេលកំណត់ជាក់លាក់ណាមួយ។ របាយការណ៍ហិរញ្ញវត្ថុទាំងនោះរួមមានសមាសធាតុចំនួន៥ដូចជា៖ របាយការណ៍តុល្យការ របាយការណ៍លទ្ធផល របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍បម្រែបម្រួលមូលធន និងកំណត់សម្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

-របាយការណ៍តុល្យការ (Balance Sheet/Financial Position)

របាយការណ៍តុល្យការ គឺជារបាយការណ៍មួយដែលបង្ហាញឱ្យឃើញនូវទ្រព្យ (Assets) បំណុល (Liabilities) និងទុន (Equity) របស់ក្រុមហ៊ុនតាំងពីកកើតក្រុមហ៊ុនរហូតដល់ថ្ងៃដំឡើង។ របាយការណ៍នេះមានមុខងារដូចជា ៖

- បង្ហាញពីតួលេខលម្អិតនៃទ្រព្យសកម្មទាំងអស់ ទាំងទ្រព្យរយៈពេលខ្លី និងទ្រព្យរយៈពេលវែង ដែលជាធនធានរបស់ក្រុមហ៊ុនមានទុកបម្រើការក្នុងអាជីវកម្ម។
- បង្ហាញពីតួលេខបំណុល រួមមានបំណុលរយៈពេលខ្លី និងបំណុលរយៈពេលវែងទាំងអស់ ដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុននឹងត្រូវសងគេនៅថ្ងៃអនាគត។
- បង្ហាញពីតួលេខមូលធនសរុប ជាដើមទុនរបស់ក្រុមហ៊ុនដែលមានទុកសម្រាប់បង្កើតទ្រព្យសកម្ម ដើម្បីបម្រើការក្នុងអាជីវកម្ម។

---

[1] វិទ្យាស្ថាន វ៉ាន់ដា(១០១៩). *Basic financial accounting part I* បោះពុម្ពលើកទី១២. ទំព័រទី ១២៦

[2] Chisel glossary. (2023). https://chisellabs.com/glossary/what-is-user/

[3] TOTA Banking (2022). https://www.facebook.com/permalink.php/?story_fbid=442764267501496&id=109817480796178

Company Name

Balance Sheet

Date: 31 December 20XX

Assets	
Current assets:	
Cash	xxx
Accounts Receivable	xxx
Prepaid expenses	xxx
Inventory	xxx
Total current assets	**xxx**
Property & Equipment	xxx
Total Assets	**xxx**
Liabilities	
Current liabilities:	
Accounts payable	xxx
Accrued expenses	xxx
Unearned revenue	xxx
Total current liabilities	**xxx**
Long-term debt	xxx
Other long-term liabilities	xxx
Total Liabilities	**xxx**
Shareholder's Equity	
Investment capital	xxx
Retained earnings	xxx
Shareholder's Equity	**xxx**
Total Liabilities & Shareholder's Equity	**xxx**

-របាយការណ៍លទ្ធផល (Income Statement/Financial Performance)

របាយការណ៍លទ្ធផល គឺជារបាយការណ៍ដែលបង្ហាញឱ្យឃើញនូវចំណូល (Revenues) និងចំណាយ (Expenses) ព្រមទាំងលទ្ធផលចំណេញ ឬខាតនៃការរកស៊ីរបស់ក្រុមហ៊ុនមួយក្នុងការិយបរិច្ឆេទមួយជាក់លាក់។ របាយការណ៍នេះ មានមុខងារដូចជា ៖

- បង្ហាញតួលេខលម្អិត អំពីចំណូលទាំងអស់ដែលក្រុមហ៊ុនមាន រួមមាន ចំណូលអាជីវកម្មដែលបានមកពីការលក់ទំនិញ ឬសេវាកម្ម ចំណូល និងចំណេញបន្ទាប់បន្សំដែលកើតឡើងនៅក្នុងក្រុមហ៊ុន។
- បង្ហាញតួលេខលម្អិត អំពីចំណាយទាំងអស់កើតឡើងនៅក្នុងក្រុមហ៊ុន រួមមាន ចំណាយអាជីវកម្មដូចជា ចំណាយថ្លៃដើមទំនិញ សេវាកម្ម ឬផលិតកម្ម ចំណាយ និងការខាតបន្ទាប់បន្សំមួយចំនួនទៀតផងដែរ។

Company Name
Income Statement
Date: 31 December 20XX

Revenue	
Sales Revenue	xxx
Service Revenue	xxx
Interest Revenue	xxx
Gain of Sales of Assets	xxx
Total Revenue & Gains	**xxx**
Expenses	
Advertising	xxx
Depreciation	xxx
Interest	xxx
Rent/Lease	xxx
Travel	xxx
Wages	xxx
Other Expenses	xxx
Total Expenses	**xxx**
Income before tax	**xxx**
Income tax expense	xxx
Net Profit (Loss)	**xxx**

-របាយការណ៍លំហូរសាច់ប្រាក់ (Cash Flow Statement/Financial Position Change)

របាយការណ៍លំហូរសាច់ប្រាក់ គឺជារបាយការណ៍ដែលបង្ហាញអំពីលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់ (Cash) និងសាច់ប្រាក់ប្រហាក់ប្រហែល (Cash Equivalent) និងប្រភពធនធានដែលបានប្រើប្រាស់ក្នុងការិយបរិច្ឆេទ តាមរយៈ៣សកម្មភាព ដូចជា ៖

១.សកម្មភាពប្រតិបត្តិការ (Operating Activities)

២.សកម្មភាពវិនិយោគ (Investing Activities)

៣.សកម្មភាពហិរញ្ញប្បទាន (Financing Activities) ។

របាយការណ៍នេះ មានមុខងារដូចជា ៖

-វាយតម្លៃការប្រែប្រួលទ្រព្យសកម្មពិតរបស់សហគ្រាស (ប្រើទៅលើអ្វីខ្លះ? មានប្រភពមកពីណា?)

-រចនាសម្ព័ន្ធហិរញ្ញវត្ថុ រួមមាន Liquidity និង Solvency របស់សហគ្រាស។

.Liquidity គឺសំដៅដល់ភាពមានប្រាក់បម្រុងគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងការដកប្រាក់បញ្ញើ និងកិច្ចសន្យាហិរញ្ញវត្ថុផ្សេងទៀតដល់ពេលត្រូវសង។

.Solvency គឺសំដៅដល់ភាពមានប្រាក់សម្រាប់រយៈពេលវែង ដើម្បីឆ្លើយតបទៅនឹងកិច្ចសន្យាហិរញ្ញវត្ថុដល់ពេលត្រូវសងគេ។

-លទ្ធភាពរបស់សហគ្រាសក្នុងការបញ្ចេញឥទ្ធិពលរបស់ខ្លួនក្នុងការប្រើប្រាស់ចំនួនទឹកប្រាក់ និងពេលវេលានៃលំហូរសាច់ប្រាក់ ដើម្បីប្រើឱ្យស្របទៅតាមការប្រែប្រួលកាលៈទេសៈ និងឱកាស។

-ព័ត៌មានលំហូរសាច់ប្រាក់មានប្រយោជន៍ណាស់ ក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់សហគ្រាសក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល។

-ការផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ ដើម្បីបង្កើតរបៀបវាយតម្លៃ និងប្រៀបធៀបតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតទៅនឹងសហគ្រាសផ្សេងទៀត។

Company Name
Cash Flow Statement
Date: 31 December 20XX

Operating Activity	
Customers	xxx
Other operations	xxx
Cash paid for	xxx
Wage expenses	xxx
Interest	xxx
Income taxes	xxx
Net Profit from Operations	**xxx**
Additions to cash	xxx
Depreciation	xxx
Amortization	xxx
Subtractions from Cash	xxx
Increase in Accounts Receivable	xxx
Increase in Inventory	xxx
Total Cash from Operating Activities	**xxx**
Investing Activities	
Cash receipts from	xxx
Purchase of equipment	xxx
Bank loan	xxx
Total Cash from Investing Activities	**xxx**
Financing Activities	
Drawing/Distribution	xxx
Repayment of loans	xxx
Total Cash from Financing Activities	**xxx**
Beginning Cash	xxx
Total Change in Cash	**xxx**
Ending Cash	**xxx**

-របាយការណ៍បម្រែបម្រួលមូលធន (Statement of Change in Equity)

របាយការណ៍បម្រែបម្រួលមូលធន គឺជារបាយការណ៍ដែលបង្ហាញឱ្យឃើញនូវបម្រែបម្រួលមូលធនរបស់ម្ចាស់ក្រុមហ៊ុនតាំងពីដើមគ្រារហូតដល់ចុងគ្រា។ របាយការណ៍នេះ មានមុខងារដើម្បីតាមដានមូលធនដើមគ្រា ប្រាក់ចំណេញ ប្រាក់ចំណេញរក្សាទុក ការចែកភាគលាភ និងខាតមូលធនផ្សេងៗទៀត ព្រមទាំងមូលធននៅសល់ចុងគ្រា។

Statement of Stockholders' Equity Change 31/12/XX

(Dollar in million except Per Share)	Common Stock		Paid in Capital in excess of PV	Retained Earning	Accumulated Other Comprehensive		Total Share holder's Equity
	Share	Amount			Foreign Currency	Minimum	
.Balance at December 31/01/XX	xxx	xxx	xxx	xxx	xxx	xxx	xxx
.Net income				xxx			
.Foreign Currency Transaction					xxx		
.Minimum pension liabilities (Net of tax)						xxx	
Total comprehensive income							xxx
.Cash dividend per share				xxx			xxx
.Common stock Reacquired	xxx	xxx	xxx				xxx
.Stock comprehensive plans	xxx	xxx	xxx				xxx
.Balance at December 31/12/XX	**XXX**	**XXX**	**XXX**	**XXX**	**XXX**	**XXX**	**XXX**

-កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (Note to Financial Statement)

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ គឺសំដៅដល់ការពន្យល់បង្ហាញលម្អិតស្តីពីធាតុទាំង៥ នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានធាតុតូចៗ(គណនី) នៃពួកទ្រព្យសកម្ម បំណុល មូលធន ចំណូល និងចំណាយ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ នៅក្នុងនោះក៏រួមមាន គោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការទទួលស្គាល់នូវធាតុតូចៗ និងការវាស់វែងចំនួនទឹកប្រាក់នៃធាតុតូចៗនោះ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផងដែរ។ កំណត់សម្គាល់នេះ មានមុខងារបង្ហាញ និងពន្យល់លម្អិតពីការទទួលស្គាល់ ការវាស់វែង និងការបង្ហាញពីធាតុទាំង៥នៃរបាយការណ៍ហរិញ្ញវត្ថុ។

Note to Financial Statement 31/12/20XX

Note 6. Inventory, including deferred inventory costs

December 31	20XX	20XX
Raw materials and work in process	xxx	xxx
Finished goods	xxx	xxx
Deferred inventory costs(a)	xxx	xxx
Inventory, including deferred inventory costs	XXX	XXX

(a) Represents cost deferred for shipped goods (such as comonents for wind turbine assemblies within our Renewable Energy segment) and labor and overhead costs on time and material service contracts (primarily originating in Power and Aviation) and other costs for which the criteria for revenue recognition has not yet been met. This was previously recorded in Contract and other deferred assets.

របាយការណ៍ហិរញ្ញវត្ថុ ឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ ដូចជា ចំណូល ចំណាយ ទ្រព្យសកម្ម ទ្រព្យអសកម្ម លំហូរសាច់ប្រាក់ចូល ឬចេញ។ ដូច្នេះ យើងអាចដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងសក្តានុពលរបស់ក្រុមហ៊ុនតាមរយៈរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនហើយជាទូទៅ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានគេរៀបចំឡើង១ឆ្នាំម្តង។ របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ចំពោះអ្នកពាក់ព័ន្ធ ដូចខាងក្រោម៖

- អ្នកគ្រប់គ្រងក្រុមហ៊ុនផ្ទាល់ (Management)៖ នៅក្នុងការរៀបចំនូវគម្រោងហិរញ្ញវត្ថុផ្សេងៗពឹងផ្អែកទាំងស្រុងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែង។
- បុគ្គល និងអង្គភាពខាងក្រៅក្រុមហ៊ុន (Individual and Other Entity)៖ វិនិយោគិន ម្ចាស់បំណុល និងភាគីពាក់ព័ន្ធ មុននឹងធ្វើការសម្រេចចិត្តផ្សេងៗជាមួយក្រុមហ៊ុន ពួកគេត្រូវតែស្វែងយល់ពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឱ្យបានច្បាស់ ដើម្បីដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ ក្រុមហ៊ុន។
- រដ្ឋាភិបាល (Government)៖ ភ្នាក់ងាររបស់រដ្ឋាភិបាលមានតួនាទីត្រួតពិនិត្យ និងតាមដានពីស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុន ថាតើក្រុមហ៊ុនបាន អនុវត្តតាមច្បាប់ដែរឬទេ ដូចជា ការកត់ត្រា ការបង់ពន្ធជាដើម។ ដូច្នេះ គេត្រូវពឹងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុទាំងស្រុង។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ក្រុមហ៊ុនត្រូវមានការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យរបាយការណ៍នោះអាចជឿទុកចិត្តបានពីអ្នកប្រើប្រាស់ ដោយគោរពតាមលក្ខខណ្ឌដូចជា៖

ភាពត្រឹមត្រូវ និងការពិត (Faithful Representation)៖ ក្រុមហ៊ុនត្រូវតែធានាថារបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ ប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ពួកគេ។ ហើយត្រូវរួមបញ្ចូលទាំងការប្រកាន់ខ្ជាប់នូវស្តង់ដាគណនេយ្យ និងគោលការណ៍ដែលណែនាំក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

តម្លាភាព (Transparency)៖ របាយការណ៍ហិរញ្ញវត្ថុគួរតែមានតម្លាភាព ដោយផ្តល់នូវព័ត៌មានលម្អិត និងច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឱ្យភាគីពាក់ព័ន្ធអាចយល់ពីស្ថានភាពហិរញ្ញវត្ថុដែលបានបង្ហាញឡើង និងលទ្ធផលពាក់ព័ន្ធដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

ការអនុលោមភាព (Compliancy)៖ ក្រុមហ៊ុនត្រូវគោរពតាមស្តង់ដាគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលកំណត់ដោយស្ថាប័នគ្រប់គ្រង ដូចជា ក្រុមប្រឹក្សាស្តង់ដាគណនេយ្យហិរញ្ញវត្ថុ(FASB) នៅសហរដ្ឋអាមេរិក ឬស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) នៅទូទាំងពិភពលោក។

គណនេយ្យភាព (Accountability)៖ ក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះភាគីពាក់ព័ន្ធរបស់ពួកគេចំពោះភាពត្រឹមត្រូវ និងភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេ។ ភាគីពាក់ព័ន្ធពឹងផ្អែកលើសេចក្តីថ្លែងការណ៍ទាំងនេះ ដើម្បីធ្វើការសម្រេចចិត្តក្នុងការវិនិយោគ វាយតម្លៃហានិភ័យ និងវាយតម្លៃការអនុវត្ត និងអភិបាលកិច្ចទូទៅរបស់ក្រុមហ៊ុន។

ការពិចារណាអំពីក្រមសីលធម៌ (Consideration of ethics)៖ លើសពីកាតព្វកិច្ចផ្លូវច្បាប់ ក្រុមហ៊ុនគួរតែរក្សាស្តង់ដាសីលធម៌ក្នុងការរៀបចំ និងការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ។ នេះរួមបញ្ចូលទាំងការជៀសវាងជម្លោះផលប្រយោជន៍ ការធានាឱ្យមានការបង្ហាញដោយយុត្តិធម៌នៃទិន្នន័យហិរញ្ញវត្ថុ និងការបង្ហាញព័ត៌មានពាក់ព័ន្ធដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកពាក់ព័ន្ធ។

ផលប៉ះពាល់ចំពោះអ្នកប្រើប្រាស់ (Impact on users)៖ របាយការណ៍ហិរញ្ញវត្ថុក៏អាចឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះទំនួលខុសចំពោះអ្នកប្រើប្រាស់ផងដែរ។ នេះអាចរួមបញ្ចូលការរាយការណ៍អំពីគំនិតផ្តួចផ្តើមប្រកបដោយនិរន្តរភាព ផលប៉ះពាល់បរិស្ថាន ឬការវិនិយោគក្នុងសហគមន៍ ដោយផ្តល់ឱ្យភាគីពាក់ព័ន្ធនូវទិដ្ឋភាពទូលំទូលាយនៃការរួមចំណែករបស់ក្រុមហ៊ុនលើសពីការអនុវត្តផ្នែកហិរញ្ញវត្ថុ។

សរុបមក ទំនួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុជាមួយអ្នកប្រើប្រាស់រួមបញ្ចូលនូវផលប៉ះពាល់យ៉ាងទូលំទូលាយនៃរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ និងតម្លាភាព លើទំនុកចិត្ត និងទំនុកចិត្តរបស់អ្នកពាក់ព័ន្ធ ស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុ និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុននៅក្នុងសហគមន៍ដែលខ្លួនបម្រើ។

៣. សន្និដ្ឋាន

ក្រុមហ៊ុនដែលកំពុងដំណើរការអាជីវកម្មដែលបានចុះបញ្ជីក្នុងការបោះលក់មូលបត្រ និងក្រុមហ៊ុនធំៗភាគច្រើន គឺត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីដឹងពីដំណើរការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយបោះពុម្ពផ្សាយជាសាធារណៈដល់អ្នកប្រើប្រាស់។ ម្យ៉ាងវិញទៀត វាក៏ជាតម្រូវការ របស់និយ័តករ និងសវនកម្មដែលជាស្ថាប័នរបស់រដ្ឋផងដែរ ដើម្បីធ្វើការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវពាក់ព័ន្ធនឹងពន្ធដារ។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក ខ្ញុំយល់ឃើញថា របាយការណ៍ហិរញ្ញវត្ថុពិតមានផលប្រយោជន៍ណាស់ចំពោះអ្នកប្រើប្រាស់ ព្រោះថា អ្នកប្រើប្រាស់ទាំងអស់ត្រូវការរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីយកទៅអាន វិភាគ និងធ្វើការសម្រេចចិត្តមុននឹងដាក់ការវិនិយោគចូលក្រុមហ៊ុនណាមួយ។

ឯកសារយោង

១. វិទ្យាស្ថាន វ៉ាន់ដា. (2019). *Intermediate Accounting Part 3* បោះពុម្ពលើកទី១១ សរុប២៩៣ទំព័រ

២. KHEMSARITH . (2016, October 05). និយមន័យរបាយការណ៍ហិរញ្ញវត្ថុ https://khemsarith.wordpress.com/2016/10/05/

៣. វិទ្យាស្ថាន វ៉ាន់ដា. (2012). *ធម្មនុញ្ញភាពគណនេយ្យសម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* សរុប៥៣ទំព័រ

ប្រសិទ្ធភាពការងារជាក្រុម

Efficiency of Teamwork

កែវ ស៊ីថា
បេក្ខបណ្ឌិត សេដ្ឋកិច្ច
ប្រធានផ្នែក គណនេយ្យកុំព្យូទ័រ

មូលន័យសង្ខេប

ប្រសិទ្ធភាពការងារជាក្រុមពិតជាមានសារៈសំខាន់ណាស់ក្នុងការសហការគ្នា ធ្វើការងាររួមគ្នា និងសម្រេចបានលទ្ធផលចង់បានក្នុងលក្ខណៈទាន់ពេលវេលា។ ចូលរួមបង្កើនការពេញចិត្តការងារ ការលើកទឹកចិត្ត ស្មារតីសហការគ្នា បង្កើតបរិយាកាសជួយសម្រួលដល់ភាពជោគជ័យ។ ការងារជាក្រុម និងប្រកបដោយប្រសិទ្ធភាព ការងារជាក្រុមដ៏អស្ចារ្យអាចនាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់បុគ្គល នេះហើយហេតុផលដែលគ្រប់អាជីវកម្មព្យាយាមបង្កើនជំនាញការងារជាក្រុមនៅក្នុងក្រុម នៃក្រុមហ៊ុនរបស់ខ្លួន។

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដែលប្រមូលទិន្នន័យតាមរយៈគេហទំព័រ Team Asana. (2024 February 1st) ទាក់ទងទៅនឹងកត្តាការងារ ប្រសិទ្ធភាពការងារជាក្រុម និងគេហទំព័រ Astrid Tran. (2024 March 21) *New Understanding of the Importance of Teamwork* | 2024 Updated ទាក់ទងទៅនឹងសារៈសំខាន់នៃការងារជាក្រុម។

ប្រធានបទនេះពិតជាមានសារៈសំខាន់ ដោយបានជួយដល់ការងារជាច្រើនក្នុងការអនុវត្តការងារជាក្រុម និងមានការយល់ដឹង ចេះសហការគ្នា ជួយគ្នាទៅវិញទៅមក ដឹងច្បាស់ពីសមាជិកម្នាក់ៗ ចេះបែងចែកការងារ និងចេះទទួលខុសត្រូវ។ ការងារជាក្រុមសំដៅលើសមត្ថភាពរបស់បុគ្គលមួយក្រុមក្នុងការធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព និងសម្រេចបាននូវគោលដៅ។ កត្តាសំខាន់ៗមួយចំនួនក្នុងការរួមចំណែកដល់ប្រសិទ្ធភាពការងារជាក្រុម រួមមាន គោលដៅ និងគោលបំណងច្បាស់លាស់ ចក្ខុវិស័យរួម។ ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព ទំនុកចិត្ត និងការគោរពគ្នាទៅវិញទៅមកក្នុងចំណោមសមាជិកក្រុម។ បណ្តាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងការផ្ទេរភារកិច្ចឱ្យបានត្រឹមត្រូវ។

សរុបសេចក្តីមក ប្រសិទ្ធភាពការងារជាក្រុមពិតជាមានសារៈសំខាន់ណាស់ព្រោះបានជួយសម្រួលដល់ការងារជាច្រើនក្នុងការអនុវត្តការងារជាក្រុម ដើម្បីសម្រេចឱ្យបាននូវ គោលដៅ ចក្ខុវិស័យ និងបេសកកម្មរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

១. សេចក្តីផ្តើម

គ្រប់អង្គភាពទាំងអស់តែងតែចង់សម្រេចឱ្យបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួនតាមរយៈការទទួលបានប្រាក់ចំណេញជាអតិបរមា ដូច្នេះការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងអង្គភាពជាចំណុចចាប់ផ្តើមនៃការធ្វើដំណើរឱ្យស្របតាមផែនការ និងគោលដៅដែលបានកំណត់។ ដើម្បីឱ្យការដឹកនាំមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ បុគ្គលិកម្នាក់ៗត្រូវចូលរួមសហការធ្វើការងារជាក្រុមលើគ្រប់សកម្មភាពរបស់អង្គភាព។

ការងារជាក្រុម គឺជាការងារដែលតម្រូវឱ្យបុគ្គលិកធ្វើការរួមគ្នាប្រកបដោយភាពស្និទ្ធស្នាល ដើម្បីផ្តល់មតិយោបល់ ផ្លាស់ប្តូរគំនិត និងចែករំលែកបទពិសោធន៍ថ្មីៗ ក្នុងគោលបំណងទទួលយកធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានក្នុងការសម្រេចចិត្តប្រកបដោយភាពត្រឹមត្រូវ។

ការងារជាក្រុមប្រៀបដូចជាខ្សែសង្វាក់ផលិតកម្មមួយដែលមិនអាចខ្វះបាន ដោយមើលឃើញពីភាពចាំបាច់នៃការងារជាក្រុម ទើបខ្ញុំបាទលើកប្រធានបទ ***ប្រសិទ្ធភាពការងារជាក្រុម*** មកធ្វើការសិក្សាស្រាវជ្រាវ ដោយលើកយកសំណួរចំនួនពីរមកចោទសួរ ដូចខាងក្រោម៖

១. តើមានកត្តាអ្វីខ្លះដែលជំរុញឱ្យការងារជាក្រុមមានប្រសិទ្ធភាព?

២. តើការសហការគ្នាធ្វើការងារជាក្រុមមានសារៈសំខាន់ដូចម្តេចខ្លះ?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី **ប្រសិទ្ធភាពការងារជាក្រុម**។ ការប្រមូលទិន្នន័យតាមរយៈគេហទំព័រ Team Asana. (2024 February 1st) និងAstrid Tran. (2024 March 21)។

ឧបករណ៍ប្រមូលទិន្នន័យសម្រាប់សំណួរស្រាវជ្រាវទី១៖ ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់តាមបែបគុណវិស័យ ដើម្បីប្រមូលទិន្នន័យដោយធ្វើឡើងតាមរយៈគេហទំព័រ Team Asana. (2024 February 1st) ដើម្បីឆ្លើយតបអំពី **ប្រសិទ្ធភាពការងារជាក្រុម។** ការស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការរៀបចំ និងចងក្រងជាអត្ថបទខ្លីៗឡើងវិញ។

ឧបករណ៍ប្រមូលទិន្នន័យសម្រាប់សំណួរស្រាវជ្រាវទី២៖ ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់តាមបែបគុណវិស័យ ដើម្បីប្រមូលទិន្នន័យដោយធ្វើឡើងតាមរយៈគេហទំព័រ Astrid Tran. (2024 March 21) ដើម្បីឆ្លើយតបអំពី សារៈសំខាន់នៃការសហការគ្នាធ្វើការងារជាក្រុម។ ការស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការរៀបចំ និងចងក្រងជាអត្ថបទខ្លីៗឡើងវិញ។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

ប្រសិទ្ធភាព (Efficiency) គឺជាសមត្ថភាពនៃការប្រើប្រាស់ធនធាននានារបស់អង្គភាពដែលមាន ដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[1]។

[1] វិទ្យាស្ថាន វ៉ាន់ដា (២០១៥) *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង Principle of Management* បោះពុម្ពលើកទី៥ ទំព័រ១

ការងារជាក្រុម: គឺជាដំណើរការនៃការធ្វើការសហការជាក្រុមដែលធ្វើការរួមគ្នាឆ្ពោះទៅរកការសម្រេចបាននូវគោលដៅជាក់លាក់[2]។

ក្រុម (Group) គឺជាក្រុមមនុស្សត្រូវបានចាត់តាំងឡើង ដើម្បីធ្វើការរួមគ្នាឬក្រុមមនុស្សធ្វើការស្រដៀងៗគ្នា ឬក្រុមមនុស្សស្ថិតនៅក្រោមអ្នកបង្គាប់បញ្ជាតែម្នាក់[3]។

ការសហការ គឺជាភាពជាដៃគូ សហជីពមួយនៃការផលិតឬបង្កើតអ្វីមួយជាមួយគ្នា ការសហការអាចកើតឡើងរវាងមនុស្សពីរនាក់ឬមនុស្សជាច្រើន[4]។

២. ប្រសិទ្ធភាពការងារជាក្រុម

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១:

ប្រសិទ្ធភាពការងារជាក្រុមសំដៅលើសមត្ថភាពរបស់ក្រុមក្នុងការធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាពនិងសម្រេចបានលទ្ធផលចង់បានក្នុងលក្ខណៈទាន់ពេលវេលា។ វាពាក់ព័ន្ធនឹងការសម្របសម្រួល និងការសហការគ្នារបស់សមាជិកក្រុម ដើម្បីបង្កើនផលិតភាព កាត់បន្ថយពេលវេលា និងធនធានដែលខ្ជះខ្ជាយ។ ដើម្បីឱ្យការងារជាក្រុមមានប្រសិទ្ធភាពត្រូវមានកត្តាដូចខាងក្រោម:

១. បង្កើនការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

ការងារជាក្រុមប្រកបដោយប្រសិទ្ធភាព ចាប់ផ្តើមជាមួយនឹងការទំនាក់ទំនងដ៏រឹងមាំ ដើម្បីធ្វើការជាមួយគ្នា មិនថានៅពេលធ្វើការលើគម្រោងថ្មី អ្នកត្រូវមានទំនាក់ទំនងបង្កើតភាពស្និទ្ធស្នាល និងគោលដៅច្បាស់លាស់ដើម្បីសម្រេចបានជោគជ័យ។

២. ធ្វើឱ្យប្រសើរឡើងនូវការបំផុសគំនិត

ការបំផុសគំនិត គឺជាវិធីសាស្ត្រដ៏មានឥទ្ធិពលមួយដែលជួយក្រុមគិតនូវគំនិតថ្មីៗ ទាំងនេះអាចរួមបញ្ចូលទាំងគម្រោង ដំណើរការ ផលិតផល និងសេវាកម្ម។ ការងារជាក្រុមល្អមានន័យថា ក្រុមរបស់អ្នកមានទំនាក់ទំនងក្នុងការចែករំលែកបទពិសោធន៍ការងារ។ ភាពជោគជ័យនៃការបំផុសគំនិតពឹងផ្អែកលើការងារជាក្រុមដ៏រឹងមាំ តាមរយៈការវិនិយោគ ពេលវេលា ដើម្បីជំរុញទំនុកចិត្ត និងការទំនាក់ទំនងបើកចំហ។

៣. លើកទឹកចិត្តគោលដៅរួម

ការងារមានគោលដៅរួម គឺចាំបាច់ណាស់នៅពេលនិយាយអំពីអាទិភាពគម្រោង និងគំនិតផ្តួចផ្តើមថ្មីៗ ជាមួយនឹងសមាជិកក្រុមជាច្រើនដែលធ្វើការលើកិច្ចការនីមួយៗ គោលដៅគម្រោងឱ្យស្របគ្នា និងធានាថាគោលបំណងត្រូវបានបំពេញឱ្យបានជោគជ័យ។

មានវិធីមួយចំនួនដែលអ្នកអាចទំនាក់ទំនង គោលដៅតាមវិធីលើកទឹកចិត្តការងារជាក្រុម និងលើកកម្ពស់ការសហការទាំងនេះរួមមាន:

-ករណីអាជីវកម្ម គឺជាឯកសារដែលលម្អិតអំពីតម្លៃនៃគម្រោងឬគំនិតផ្តួចផ្តើម។ នេះធានាថាសមាជិកក្រុមនីមួយៗមានចំណុចចាប់ផ្តើមដូចគ្នាមុនពេលធ្វើគម្រោង។

---

[2]Team Asana. (2024 February 1st) *11 Benefits of teamwork in the workplace (with examples) (https_asana.com)*

[3] គង់ ឆាយឡេង. (2024 ខែមេសា5) *http://thehrdaily.com.dream.website/ideas/page=123/whatisteam/*

[4] Caitlin Ultimo. (2024 January 12) What is Collaboration? | Definition & Types of Collaboration (webex.com)

-ការប្រជុំ គឺជាវិធីដ៏ល្អមួយដើម្បីឱ្យក្រុមរបស់អ្នកធ្វើការជាមួយគ្នា។ មានកិច្ចប្រជុំដំបូង ក៏ដូចជាកិច្ចប្រជុំក្រោយពេលដែលគម្រោងបញ្ចប់ អាចជួយកំណត់លទ្ធផល និងធានាថាគោលបំណងត្រូវបានសម្រេច។

៤. ធ្វើឱ្យប្រសើរឡើងនូវជំនាញដោះស្រាយបញ្ហា

បញ្ហាអាចពិបាកដោះស្រាយដោយខ្លួនឯង នោះហើយជាមូលហេតុដែលធ្វើការរួមគ្នាជាក្រុមអាចផ្តល់នូវដំណោះស្រាយលឿនជាងមុន និងជាញឹកញាប់មានប្រសិទ្ធភាពជាងមុន។ មិនត្រឹមតែជួយបង្កើតដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការដោះស្រាយបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែការប្រើប្រាស់ការងារជាក្រុមបង្កើតគោលដៅរួមគ្នា។

៥. ជួយបង្កើតទំនុកចិត្ត

ជួយបង្កើតទំនុកចិត្ត គឺជាអ្វីដែលត្រូវបានសាងសង់តាមពេលវេលា វាត្រូវការការទំនាក់ទំនង តម្លាភាព និងការគាំទ្រ ដើម្បីកសាងទំនុកចិត្តជាមួយសមាជិកក្រុម។

ក្រុមដែលជឿទុកចិត្តគ្នាទៅវិញទៅមក ធ្វើឱ្យការទំនាក់ទំនងគំនិត សហការ និងបង្កើនកម្លាំងសាមគ្គី។ អវត្តមាននៃការងារជាក្រុមអាចនាំឱ្យមានការបែកបាក់ទំនុកចិត្ត។

៦. ធ្វើឱ្យប្រសើរឡើងនូវវប្បធម៌ក្រុមហ៊ុន

ក្រុមហ៊ុនភាគច្រើនខិតខំប្រឹងប្រែងសម្រាប់វប្បធម៌ក្រុមហ៊ុនល្អ ប៉ុន្តែវាមិនងាយស្រួលដូចជាការជជែកវប្បធម៌ក្រុមហ៊ុនពាក់ព័ន្ធនឹងការធ្វើឱ្យសមាជិកក្រុមរបស់អ្នកមានអារម្មណ៍ស្តាប់ និងផ្តល់អំណាច ដើម្បីធ្វើការងារល្អបំផុតរបស់ពួកគេ ខណៈពេលដែលផ្តល់ឱ្យពួកគេនូវតុល្យភាពការងារនិងជីវិត និងបរិយាកាសការងាររីករាយជារួម។

៧. បង្កើតប្រសិទ្ធភាព

ពីការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរហូតដល់ការកែលម្អវប្បធម៌ក្រុមហ៊ុន ការងារជាក្រុមជំរុញអត្ថប្រយោជន៍ជាច្រើន រួមទាំងការបង្កើតប្រសិទ្ធភាពក្រុម។ ក្រុមប្រកបដោយប្រសិទ្ធភាពធ្វើការរួមគ្នាដើម្បីគ្រប់គ្រងបញ្ហា និងកិច្ចការប្រចាំថ្ងៃបានយ៉ាងឆាប់រហ័ស។ ជាលទ្ធផល ក្រុមដែលមានប្រសិទ្ធភាពប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងឈានដល់ការអនុវត្តរបស់ពួកគេកាន់តែលឿន។ ការស្ថិតរមួតបែបនេះគឺជាឧបករណ៍ក្នុងការជំរុញដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ខណៈពេលដែលរក្សាគុណភាពស្របគ្នា។

៨. បង្កើនការចូលរួមរបស់បុគ្គលិក

ដើម្បីបង្កើនការចូលរួមរបស់បុគ្គលិក សូមលើកទឹកចិត្តការងារជាក្រុមទាំងក្នុង និងក្រៅការងារ។ កំណត់ពេលវេលាសម្រាប់ក្រុមរបស់អ្នក ដើម្បីចូលរួមធ្វើកិច្ចការកាន់តែមានប្រសិទ្ធភាពខ្ពស់។

៩. ជំរុញក្រុមដែលមានប្រសិទ្ធភាពខ្ពស់

ការជំរុញសមាជិកក្រុមមិនត្រឹមតែដើម្បីបំពេញតាមការរំពឹងទុកប៉ុណ្ណោះទេ ប៉ុន្តែដើម្បីឱ្យពួកគេមានឆន្ទៈរួមចំណែកគំនិតល្អបំផុតរបស់ពួកគេដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុម។ សមាជិកក្រុមនីមួយៗមានប្រសិទ្ធភាពខ្ពស់ ក្រុមទាំងមូលរបស់អ្នកនឹងមានប្រសិទ្ធភាពខ្ពស់ មានន័យថា អ្នកអាចបង្កើតការងារដែលមានគុណភាពខ្ពស់កាន់តែមានប្រសិទ្ធភាព។ មិនត្រឹមតែក្រុមមានប្រសិទ្ធភាពខ្ពស់ល្អសម្រាប់ក្រុមហ៊ុនរបស់

អ្នកប៉ុណ្ណោះទេ ប៉ុន្តែវាក็ជួយដល់ការពេញចិត្តការងារផងដែរ ព្រោះការធ្វើបានល្អនឹងជំរុញបុគ្គលឱ្យបន្តពង្រីកជំនាញរបស់ពួកគេ។

១០. អភិវឌ្ឍន៍ចំណុចខ្លាំងបុគ្គល

ការងារជាក្រុម មិនត្រឹមតែនិយាយអំពីភាពជោគជ័យរបស់ក្រុមប៉ុណ្ណោះទេ វាក็គាំទ្រដល់ការអភិវឌ្ឍបុគ្គលផងដែរ។ សមាជិកក្រុមដែលពង្រីកចំណេះដឹងបុគ្គលរបស់ពួកគេអាចចែករំលែកវាជាមួយអ្នកដទៃក្នុងអំឡុងពេលគម្រោងនាពេលអនាគត។

លទ្ធផល៖ សមាជិកក្រុមនីមួយៗរីកចម្រើនចំណុចខ្លាំងរបស់ពួកគេ ក็ដូចជាចំណុចខ្លាំងរបស់ក្រុម។ ទាំងនេះអាចរួមបញ្ចូលទាំងសមត្ថភាពរបស់អ្នកក្នុងការដោះស្រាយបញ្ហា ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងការប្រយុទ្ធប្រឆាំងនឹងការពន្យារពេលទាំងអស់នេះគឺជាជំនាញសំខាន់ក្នុងការអភិវឌ្ឍ។

១១. ធ្វើឱ្យប្រសើរឡើងនូវជំនាញក្នុងការសម្រេចចិត្ត

ដើម្បីពូកែក្នុងការសម្រេចចិត្ត អ្នកត្រូវការទំនុកចិត្តក្នុងការធ្វើការសម្រេចចិត្តរហ័សដោយផ្អែកលើចំណេះដឹងដែលអ្នកបានប្រមូលផ្តុំក្នុងតួនាទីរបស់អ្នក។ ការងារជាក្រុម គឺមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ការកែលម្អសមត្ថភាពសម្រេចចិត្ត។ វាបង្កើតបរិយាកាសមួយដែលសមាជិកក្រុមត្រូវបានលើកទឹកចិត្តឱ្យដោះស្រាយសំណួរ និងធ្វើការសម្រេចចិត្តភ្លាមៗ សម្រាប់ការដោះស្រាយបញ្ហាចាំបាច់តាមពេលវេលាជាក់ស្តែង។

កែលម្អការងារជាក្រុម

ការកែលម្អការងារជាក្រុម គឺនិយាយអំពីការជំរុញបរិយាកាសផ្តល់តម្លៃដល់ការរួមចំណែករបស់សមាជិកក្រុមទាំងអស់ និងលើកទឹកចិត្តកិច្ចខិតខំប្រឹងប្រែងរួមគ្នាឆ្ពោះទៅរកគោលដៅរួម។ វាពាក់ព័ន្ធនឹងការបង្កើនជំនាញការងារជាក្រុម ដែលអ្នកអាចធ្វើបានដើម្បីជំរុញការងារជាក្រុមដ៏អស្ចារ្យ។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២៖

កិច្ចសហប្រតិបត្តិការរវាងបុគ្គលម្នាក់ៗក្នុងដំណើរការបំពេញការកិច្ចគឺជាអ្វីដែលការងារសម្រេចបានប្រកបដោយប្រសិទ្ធភាព។ នៅពេលការសហការជាក្រុមក្លាយជាមូលដ្ឋានគ្រឹះនៃគម្រោងណាមួយ វាពិតជាអស្ចារ្យដែលឃើញពីលទ្ធផលទទួលបាន។ កន្លែងធ្វើការលើកទឹកចិត្ត ស្មារតីសហការគ្នាបង្កើតបរិយាកាសជួយសម្រួលដល់ភាពជោគជ័យ។ ការចែកចាយបន្ទុកការងារក្នុងចំណោមធនធាន ឬការបង្កើតរបៀបលំហូរការងារនឹងលាតត្រដាងនៅពេលដែលសមូហភាពអាចធ្វើឱ្យប្រសើរឡើងនូវការងារជាក្រុម ដើម្បីធ្វើឱ្យអ្វីៗដំណើរការទៅដោយរលូន នេះគឺជាមូលហេតុការងារជាក្រុម និងកិច្ចសហការបង្កើតផលវិជ្ជមានវិជ្ជជីវៈ។ នៅក្នុងបរិបទអាជីវកម្ម ការងារជាក្រុមត្រូវបានគេមើលឃើញថា ជាខ្សែជីវិតនៃប្រតិបត្តិការ ដែលទាមទារសម្រាប់ការគាំទ្រលំហូរការងារ និងការសម្រេចបាននូវគោលដៅ។ លើសពីការរក្សាដំណើរការអាជីវកម្ម ការធ្វើការងារជាក្រុមប្រកបដោយប្រសិទ្ធភាពនាំមកនូវអត្ថប្រយោជន៍ជាច្រើន ដែលជួយមនុស្សឱ្យរីកចម្រើនផ្ទាល់ខ្លួន និងបង្កើនជំនាញរបស់ពួកគេ។ នេះ គឺជាអត្ថប្រយោជន៍សំខាន់ៗនៃការងារជាក្រុម៖

ដើម្បីទទួលបានជោគជ័យក្នុងការងារ ជំនាញយល់ដឹងមិនគ្រប់គ្រាន់ទេ ជំនាញទាំងនេះបន្តិចម្តងក្លាយជាការវាស់វែងថ្មីនៃការអនុវត្តការងារ។ អាចំកំបាំងនៃក្រុមមានសមត្ថភាពខ្ពស់គឺការងារជាក្រុម។

អ្នកអាចអភិវឌ្ឍជំនាញការងារជាក្រុមតាំងពីនៅរៀនដំបូង នៅពេលអ្នកធ្វើការជាមួយមិត្តរួមថ្នាក់ ដើម្បីបំពេញកិច្ចការ។ ដូច្នេះ ការយល់ដឹងអំពីខ្លឹមសារនៃការងារជាក្រុម សារៈសំខាន់របស់វា និងទាំងឧទាហរណ៍វិជ្ជមាន និងអវិជ្ជមាន អាចជួយអាជីវកម្មដោះស្រាយជាមួយបុគ្គលិកដែលធ្វើការងារជាក្រុមមិនល្អ និងធ្វើឱ្យកិច្ចសហការក្នុងអាជីវកម្មរបស់ពួកគេប្រសើរឡើង។

ការសហការគ្នាធ្វើការងារជាក្រុមមានសារសំខាន់៥យ៉ាង ដូចខាងក្រោម៖

១. កាត់បន្ថយជម្លោះ

ជម្លោះជារឿយៗកើតឡើងនៅកន្លែងធ្វើការដែលមានការប្រកួតប្រជែងមិនល្អ ដោយសារមិត្តរួមក្រុមទទួលបានការព្យាបាល និងការចាប់អារម្មណ៍មិនស្មើគ្នា។ នៅកន្លែងធ្វើការតែងតែឃើញជម្លោះការងារ ជម្លោះទំនាក់ទំនង និងជម្លោះតម្លៃ។ ជាពិសេសជម្លោះការងារ សំដៅទៅលើការខ្វែងគំនិតគ្នាក្នុងគំនិត និងសកម្មភាពនៅពេលដែលសមាជិកក្រុមផ្សេងគ្នាមានទស្សនៈខុសៗគ្នា។ នៅពេលធ្វើការងារជាក្រុមបានល្អ ពួកគេអាចនៅជាមួយគ្នាដើម្បីដោះស្រាយបញ្ហា ស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព សម្រាប់ជម្លោះ និងភ្ជាប់ទំនាក់ទំនងជាមួយសមាជិកក្រុមឡើងវិញ។

២. លើកទឹកចិត្តដល់ការច្នៃប្រឌិត

នៅពេលធ្វើការងារជាក្រុម និងសកម្មភាពផ្សារភ្ជាប់គ្នាជាក្រុម បុគ្គលិកមានភាពងាយស្រួលក្នុងការទទួលបានការបំផុសគំនិត។ ខណៈដែលមិត្តរួមក្រុមផ្សេងទៀតមានឆន្ទៈក្នុងការស្តាប់ និងគាំទ្រគំនិត និងគំនិតរបស់អ្នកដទៃ ពួកគេអាចមានសេរីភាពក្នុងការបញ្ចេញគំនិត។ នៅពេលបុគ្គលម្នាក់បង្កើតគំនិតមួយ សមាជិកក្រុមផ្សេងទៀតអាចបង្ហាញការរិះគន់ និងដំបូន្មានដោយត្រង់ និងសមហេតុសមផល ខណៈពេលពួកគេធ្វើការរួមគ្នា ដើម្បីនាំយកគំនិតទាំងនេះទៅអនុវត្ត ដែលជំរុញឱ្យមានការបង្កើតថ្មី និងរបកគំហើញ។

៣. រក្សាកន្លែងធ្វើការជាវិជ្ជមាន

ការងារជាក្រុមមានសារៈសំខាន់ ព្រោះការធ្វើការងារជាក្រុមល្អ ធ្វើឱ្យបុគ្គលិកកាន់តែរីករាយ និងនៅតែជាបរិយាកាសការងារវិជ្ជមានគ្រប់ពេលវេលា។ ការធ្វើការងារជាក្រុមអាចការពារអ្នកពីការយល់ច្រឡំ និងការប្រកែកគ្នាដែលមិនចាំបាច់។ ទោះបីជាបន្ទាប់ពីឈ្លោះគ្នាយ៉ាងខ្លាំងក៏សមាជិកអាចយល់ចិត្តគ្នាបានកាន់តែប្រសើរ។ សមាជិកក្រុមដ៏ល្អម្នាក់អាចចែករំលែកនូវឆន្ទៈរបស់ពួកគេក្នុងការជួយរ៉ាប់រងការងារ ឬផ្តល់ការណែនាំដល់មិត្តរួមក្រុមផ្សេងទៀត នៅពេលពួកគេមិនមានបទពិសោធន៍ក្នុងស្ថានភាពថ្មី។

៤. ជំរុញកំណើនផ្ទាល់ខ្លួន

នៅក្នុងក្រុមមានសមត្ថភាពខ្ពស់ អ្នកនឹងបង្កើនឱកាសដើម្បីរៀនពីអ្នកជំនាញឬមនុស្សចាស់ដែលមានបទពិសោធន៍។ នៅពេលមានមនុស្សម្នាក់នៅក្នុងក្រុមរបស់អ្នកមានវិន័យលើខ្លួនឯង ការគ្រប់គ្រងពេលវេលាល្អ និងយកចិត្តទុកដាក់ចំពោះព័ត៌មានលម្អិត អ្នកនឹងអាចរៀនទាំងនេះបាន។ ភាពស្ទាត់ជំនាញពួកគេ និងជួយអ្នកឱ្យប្រសើរឡើងនូវចំណេះដឹងរបស់អ្នក ដំណើរការការងារកាន់តែខ្ពស់ ការសម្រេចចិត្តកាន់តែប្រសើរ និងនាំឱ្យមានការផ្សព្វផ្សាយកាន់តែទូលំទូលាយ។ ក្រុមហ៊ុនមានក្រុមការងារខ្ពស់ជាច្រើនគឺជាក្រុមហ៊ុន

ដែលរីកចម្រើន ពួកគេគឺជាកត្តាចម្បងក្នុងការរួមចំណែកដល់ភាពជោគជ័យរបស់ក្រុមហ៊ុននៅក្នុងទីផ្សារ ទទួលបានកេរ្តិ៍ឈ្មោះកាន់តែប្រសើរ និងទាក់ទាញអ្នកមានទេពកោសល្យកាន់តែច្រើន។

៥. កាត់បន្ថយការថប់បារម្ភ និងអស់កម្លាំង

អត្ថប្រយោជន៍នៃការធ្វើការងារជាក្រុមក៏ត្រូវបានបង្ហាញផងដែរក្នុងការកាត់បន្ថយការថប់បារម្ភ និងការអស់កម្លាំងក្នុងចំណោមបុគ្គលិក។ ប្រសិទ្ធភាពនៃការងារជាក្រុមមានន័យថា ជាធម្មតាពួកគេបំពេញតាមកាលកំណត់ បង្កើតលទ្ធផលល្អបំផុត និងជៀសវាងកំហុស។ ក្រុមទាំងអស់មានទំនួលខុសត្រូវ និងទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ពួកគេ និងមិនសូវខកចិត្តនៅពេលពួកគេដឹងថាពួកគេអាចទទួលបានការបម្រុងទុកពេញលេញពីក្រុមដែលអាចទុកចិត្តបានរបស់ក្រុមការងារ នៅពេលពួកគេស្ថិតក្នុងស្ថានភាពលំបាក។

-បញ្ហាប្រឈម និងដំណោះស្រាយក្នុងការងារជាក្រុម

ខណៈពេលការធ្វើការងារជាក្រុមមានសារៈសំខាន់សម្រាប់ការសម្រេចបាននូវគោលដៅរួម វាមិនមែនសុទ្ធតែគ្មានបញ្ហាប្រឈមកើតឡើងនោះទេ។ យើងនឹងស្វែងយល់ពីបញ្ហានៃក្រុមឧបសគ្គទូទៅដែលប្រឈមមុខ ហើយផ្ដួផ្ដងគ្នាជាមួយនឹងដំណោះស្រាយជាក់ស្ដែង។ ការស្វែងយល់ពីបញ្ហាប្រឈមទាំងនេះ និងការដឹងពីរបៀបដោះស្រាយបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះក្នុងការរក្សាបរិយាកាសក្រុមប្រកបដោយផលិតភាព និងសុខដុមរមនា។ គោលបំណងរបស់យើងគឺផ្ដល់ការណែនាំដែលជួយក្រុមឱ្យយកឈ្នះលើបញ្ហាប្រឈមទាំងនេះ ហើយកាន់តែរឹងមាំជាងមុន និងរួបរួមគ្នាកាន់តែខ្លាំងឡើងថែមទៀត៖

-ឧបសគ្គទំនាក់ទំនង កំណត់បណ្ដាញទំនាក់ទំនង និងពិធីការច្បាស់លាស់។ លើកទឹកចិត្តឱ្យមានការសន្ទនាដោយបើកចំហ ស្មោះត្រង់ និងប្រើប្រាស់ឧបករណ៍ ដូចជា ការប្រជុំក្រុមទៀងទាត់ វេទិកាទំនាក់ទំនងឌីជីថល ដើម្បីធានាថាអ្នកគ្រប់គ្នាស្ថិតនៅលើវេទិកាតែមួយ។

-ជម្លោះរវាងសមាជិកក្រុម លើកកម្ពស់វប្ប‌ធម៌នៃការគោរព និងការបើកចំហ ដែលជម្លោះអាចត្រូវបានពិភាក្សាក្នុងន័យស្ថាបនា។ អនុវត្តន៍យុទ្ធសាស្ត្រដោះស្រាយជម្លោះ ដូចជា ការសម្រុះសម្រួលឬការពិភាក្សាណែនាំ ដើម្បីដោះស្រាយបញ្ហាមុនពេលវាកាន់តែអាក្រក់ទៅៗ។

-រចនាបថការងារចម្រុះ និងបុគ្គលិកលក្ខណៈ អបអរសាទរ និងទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីភាពចម្រុះរបស់ក្រុម។ លើកទឹកចិត្តសមាជិកក្រុមឱ្យចែករំលែករចនាបថការងាររបស់ពួកគេ និងស្វែងរកមូលដ្ឋានរួម ឬវិធីដែលត្រូវគ្នា ដើម្បីធ្វើការជាមួយគ្នាប្រកបដោយប្រសិទ្ធភាព។

-ខ្វះគោលដៅ ឬទិសដៅច្បាស់លាស់ កំណត់គោលដៅច្បាស់លាស់ និងអាចសម្រេចបានសម្រាប់ក្រុម។ ត្រូវប្រាកដថា សមាជិកគ្រប់រូបយល់ពីតួនាទីរបស់ពួកគេ និងរបៀបរួមចំណែកដល់គោលបំណងធំជាងនេះ។ ត្រូវពិនិត្យ និងកែសម្រួលគោលដៅទាំងនេះឱ្យបានទៀងទាត់តាមតម្រូវការ។

-កម្រិតវិភាគទានអតុល្យភាព ដោះស្រាយបញ្ហាចែកចាយបន្ទុកដោយយុត្តិធម៌។ ទទួលស្គាល់ផ្ដល់រង្វាន់ដល់ការខិតខំប្រឹងប្រែង និងជំរុញបរិយាកាសមួយដែលវាមិនអីក្នុងការនិយាយ ប្រសិនបើនរណាម្នាក់មានអារម្មណ៍ថា ការងាររាប្រៃនពេក ឬមិនបានប្រើប្រាស់គ្រប់គ្រាន់។

-បរិយាកាសការងារពីចម្ងាយឬកូនកាត់ ប្រើបច្ចេកវិទ្យា ការប្រជុំនិម្មិតជាទៀងទាត់ ចែករំលែកកន្លែងធ្វើការឌីជីថល និងការប្រាស្រ័យទាក់ទងច្បាស់លាស់អាចជួយរក្សាការរួបរួមក្រុម និងធានាថា អ្នកគ្រប់គ្នាស្ថិតនៅលើក្រុមតែមួយ។

-រក្សាសីលធម៌ និងលើកទឹកចិត្តក្រុម បង្កើតវប្បធម៌ក្រុមវិជ្ជមាន អបអរភាពជោគជ័យ ផ្តល់មតិស្ថាបនា និងគាំទ្រដល់កំណើនអាជីព។ ការដោះស្រាយយ៉ាងសកម្មនូវបញ្ហាប្រឈមទូទៅទាំងនេះ អនុញ្ញាតឱ្យក្រុមមួយមិនត្រឹមតែយកឈ្នះលើឧបសគ្គដែលអាចកើតមានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យកាន់តែរឹងមាំ រួបរួមកាន់តែច្រើន និងរៀបចំបានកាន់តែប្រសើរឡើង ដើម្បីសម្រេចបាននូវគោលដៅក្រុមរបស់ខ្លួន។ ការធ្វើការងារជាក្រុមប្រកបដោយជោគជ័យ ពឹងផ្អែកលើការយល់ដឹង សកម្មភាព ការទទួលស្គាល់បញ្ហាប្រឈម និងការស្វែងរកដំណោះស្រាយយ៉ាងសកម្ម។

៣. សន្និដ្ឋាន

ការងារជាក្រុមប្រកបដោយប្រសិទ្ធភាពពិតជាមានសារៈសំខាន់ណាស់ ព្រោះបានជួយសម្រួលដល់ការងារជាច្រើនក្នុងការអនុវត្តការងារជាក្រុម និងមានការយល់ដឹង ចេះសហការគ្នា ជួយគ្នាទៅវិញទៅមក ដឹងច្បាស់ពីសមាជិកម្នាក់ៗចេះបែងចែកការងារ និងចេះទទួលខុសត្រូវ។ កត្តាសំខាន់ៗ មួយចំនួនដែលរួមចំណែកដល់ប្រសិទ្ធភាពការងារជាក្រុម រួមមាន ចក្ខុវិស័យរួម គោលដៅ គោលបំណងច្បាស់លាស់ ការច្នៃប្រឌិត និងការអនុវត្តជារួម។ ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព ទំនុកចិត្ត និងការគោរពគ្នាទៅវិញទៅមកក្នុងចំណោមសមាជិកក្រុម។ បណ្តាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងការផ្ទេរការកិច្ចឱ្យបានត្រឹមត្រូវតាមរយៈការបង្កើនប្រសិទ្ធភាពការងារជាក្រុម។ "ចង្កឹះមួយបាច់កាច់មិនបាក់ ប្រៀបបានទៅនឹងក្រុមការងារមួយដែលមិនអាចខ្វះសមាជិកក្រុមណាម្នាក់យ៉ាងដូច្នោះដែរ"។

ឯកសារយោង

១. Indeed Editorial Team. (2024 June 27) *How to Write Work Procedures in 11 Steps (With Examples) | Indeed.com Canada*

២. វិទ្យាស្ថាន វ៉ាន់ដា. (២០១៥) *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង Principle of Management* បោះពុម្ព លើកទី៥ សរុប៦៤ទំព័រ

៣. គង់ ឆាយឡេង. (២០២៤ ខែមេសា ៥) *http://thehrdaily.com.dream.website/ideas/page=123/whatisteam/*

៤. Caitlin Ultimo. (2024 January 12) What is Collaboration? | Definition & Types of Collaboration (webex.com)

៥. Ukuhlaziywa kwezinhlobo ezingaphezulu. (2023 December 27) *https://blog.plag.ai/km/teamwork-essentials-challenges-and-growth*

៦. Team Asana. (2024 February 1st) https://asana.com/resources/teamwork-in-the-workplace

៧. Astrid Tran. (2024 March 21) *New Understanding of the Importance of Teamwork* | 2024 Updated (https_ahaslides.com)

វិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា

Microfinance sector contributes to the development of Cambodian economy

កែវ ពៅរិទ្ធី
បេក្ខបណ្ឌិត សេដ្ឋកិច្ច
មុខងារប្រធានអនុគណៈកម្មការជំនាញទីផ្សារ និងធនាគារ

មូលន័យសង្ខេប

គោលបំណងសំខាន់នៃការស្រាវជ្រាវនេះ គឺដើម្បីសិក្សាឈ្វេងយល់ និងស្រាវជ្រាវបន្ថែមទាក់ទងនឹងសកម្មភាព ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាឱ្យមានការរីកចម្រើន តាមរយៈការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ ដោយផ្តល់កម្ចីដល់ក្រុមហ៊ុន សហគ្រាស អាជីវកម្មខ្នាតតូច និងខ្នាតមធ្យម ប្រជាពលរដ្ឋក្រីក្រ និងអ្នកដែលខ្វះដើមទុន ឬអ្នកមានមុខរបរថ្មី ដើម្បីឱ្យពួកគេមានជីវភាពល្អប្រសើរឡើង។

ការស្រាវជ្រាវធ្វើឡើងតាមវិធីសាស្ត្របែបគុណវិស័យ ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានយកមកវិភាគ ដោយសំយោគនូវចំណុចសំខាន់ៗទាក់ទងនឹងសកម្មភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យកមកបង្ហាញតាមរយៈគេហទំព័រដែលពាក់ព័ន្ធនឹងប្រធានបទនៃការស្រាវជ្រាវដូចជា៖ Khemsarith, AMS, Thmeythmey, Khsearch.com, Faster Capital, NBC.org.kh, កម្រងច្បាប់ និងបញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងសៀវភៅគោលនៃមុខវិជ្ជារូបិយវត្ថុ និងធនាគារនៅក្នុងវិទ្យាស្ថាន វ៉ាន់ដា ដែលបានបង្ហាញពីការចូលរួម និងអភិវឌ្ឍន៍សង្គមជាតិ ជាពិសេសនៅតាមជនបទឱ្យប្រជាពលរដ្ឋមានមុខរបរ និងជីវភាពធូរធារ។

តាមរយៈការស្រាវជ្រាវកន្លងមកបានបង្ហាញឱ្យឃើញថា វិស័យមីក្រូហិរញ្ញវត្ថុពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិពិតប្រាកដមែន ដោយមើលឃើញពីការរីកចម្រើន និងបានចូលរួមសកម្មភាពជាច្រើននៅក្នុងសង្គម ជាពិសេសនៅតាមទីជនបទ ដោយជួយដល់ប្រជាពលរដ្ឋក្រីក្រ តាមរយៈការផ្តល់កម្ចីក្នុងអត្រាការប្រាក់មួយសមរម្យ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់កសិករក្រីក្រ និងប្រឹក្សាយោបល់ទាក់ទងនឹងជំនួញខ្នាតតូចជាដើម ទើបអាចសន្និដ្ឋានបានថា វិស័យមីក្រូហិរញ្ញវត្ថុពិតជាបានចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនពិតប្រាកដមែន។

១. សេចក្តីផ្តើម

នាសតវត្សទី២១នេះ ជាយុគសម័យសកលភាវូបនីយកម្ម ដែលពិភពលោកទាំងមូលបានបើកចំហ ក្នុងការធ្វើពាណិជ្ជកម្មលើទីផ្សារសេរីបានយ៉ាងល្អ។ ក្នុងនោះដែរ កម្ពុជាក៏ជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ ដែលនាំឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនគួរកត់សម្គាល់ ជាពិសេសវិស័យហិរញ្ញវត្ថុ ដែលបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាបានមួយកម្រិត។

វិស័យហិរញ្ញវត្ថុ គឺសំដៅទៅលើស្ថាប័នធនាគារ ស្ថាប័នធានារ៉ាប់រង និងស្ថាប័នមូលបត្រ ដែលមានគោលដៅជួយជំរុញកំណើនសេដ្ឋកិច្ច ជាក់ស្តែងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាស្ថាប័នមួយប្រភេទ ដែលធ្វើប្រតិបត្តិការទៅលើសេវាមីក្រូហិរញ្ញវត្ថុ មានដូចជា ទទួលប្រាក់បញ្ញើ ផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត ដែលផ្តោតទៅលើអតិថិជនរស់នៅជនបទមានចំណូលទាប។

ហេតុដូចនេះ ដើម្បីបញ្ជាក់ថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិតជាបានចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទពិតមែននោះ ទើបមានប្រធានបទមួយបានលើកឡើងថា «**វិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា**» យកមកធ្វើការបកស្រាយនឹងដោយចោទជាពីរសំណួរដូចខាងក្រោម៖

១. តើវិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជាយ៉ាងដូចម្តេច?

២. តើធនាគារជាតិនៃកម្ពុជាមានគោលការណ៍ដូចម្តេចទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានយកមកវិភាគដែលពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី វិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា ដែលបានដកស្រង់ចេញពីគេហទំព័រ ដូចជា Khemsarith, NBC.org.kh, កម្រងច្បាប់ និងបញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សៀវភៅគោលនៃមុខវិជ្ជារូបិយវត្ថុ និងធនាគារ នៅវិទ្យាស្ថាន វ៉ាន់ដា។

សម្រាប់សំណួរស្រាវជ្រាវទី១ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ឯកសារពីគេហទំព័រ Khemsarith និងទិន្នន័យដែលមានស្រាប់នៅក្នុងសៀវភៅរូបិយវត្ថុ និងធនាគារ ភាគ១ របស់វិទ្យាស្ថាន វ៉ាន់ដា ដែលបានបង្ហាញពីការចូលរួមយ៉ាងសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

សម្រាប់សំណួរស្រាវជ្រាវទី២ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា (NBC.org.kh), កម្រងច្បាប់ និងបញ្ញត្តិផ្សេងៗ និងសៀវភៅរូបិយវត្ថុ និងធនាគារ ភាគ១ និងភាគ២ របស់វិទ្យាស្ថាន វ៉ាន់ដា ដែលទាក់ទងនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជា ការកំណត់ច្បាប់ទាក់ទងដើមទុន ការកំណត់អត្រាការប្រាក់លើឥណទាន និងប្រកាសស្តីពីប្រាក់តម្កល់ធានាលើដើមទុនជាដើម ដែលបានបង្ហាញពីការអនុវត្តរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមគោលការណ៍ ដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាពីភាពរឹងមាំនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាអង្គការមួយប្រភេទដែលផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋក្រីក្រទាំងឡាយ។ ភាគច្រើននៃអង្គការទាំងនេះ គឺផ្តល់ឥណទានខ្នាតតូចបំផុត និងទទួលប្រាក់បញ្ញើសន្សំតិចតួចពីអ្នកខ្ចីផ្ទាល់របស់ខ្លួន មិនមែនពីសាធារណជនទេ[1]។

អភិវឌ្ឍន៍ មានន័យថា ការចម្រើនក្រៃលែង ការលូតលាស់ចម្រើនជាដើម[2]។

សេដ្ឋកិច្ច គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការទិញដូរ ការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គម[3]។

១.៣.២ ប្រវត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានចាប់ដំណើរការអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ហើយត្រូវបានបែងចែកជាបីដំណាក់កាល។ ដំណាក់កាលទាំងបី មានដំណាក់កាលចាប់ផ្តើម(១៩៩០-១៩៩៥) ដំណាក់កាលស្ថាប័នអង្គការ (១៩៩៥-១៩៩៩) និងដំណាក់កាលពាណិជ្ជកម្ម(១៩៩៩-បច្ចុប្បន្ន)។

❖ ក្នុងដំណាក់កាលចាប់ផ្តើម នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាទទួលបានជំនួយពីអង្គការអន្តរជាតិសម្រាប់ផ្តល់ឥណទានដល់ប្រជាជន និងអ្នករកស៊ីនៅតំបន់ជនបទក្រីក្រ។ ស្ថាប័នអន្តរជាតិដែលផ្តល់ជំនួយនៅពេលនោះមាន ដូចជា Groupe de Recherche et d'Échanges Technologiques (GRET), Catholic Relief Service (CRS), World Vision រួមជាមួយនឹង United Nations Children's Fund (UNICEF), the International Labor Organization (ILO), the United Nations Development Program (UNDP), Agence Française de Développement (AFD), និង the US Agency for International Development(USAID)។ ជំនួយហិរញ្ញប្បទាននៅពេលនោះភាគច្រើនជាសមាសធាតុឥណទាននៅក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទរួមបញ្ចូលគ្នា។

❖ ក្រោយមកជំនួយហិរញ្ញប្បទានរួមគ្នាខាងលើចាប់ផ្តើមផ្តាច់ចេញពីគ្នា ហើយមានគម្រោងមួយចំនួនបង្កើតជាស្ថាប័នអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក សម្រាប់ធ្វើសកម្មភាពទាក់ទងនឹងការបម្រើសេវាមីក្រូហិរញ្ញវត្ថុ ដែលនេះជាដំណាក់កាលស្ថាប័នអង្គការ(១៩៩៥-១៩៩៩)។

❖ ចំណែកឯដំណាក់កាលពាណិជ្ជកម្ម(១៩៩៩-បច្ចុប្បន្ន) ចាប់ផ្តើមនៅពេលរដ្ឋសភាកម្ពុជាអនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅចុងឆ្នាំ១៩៩៩ ដែលអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលមួយចំនួនអាចបន្តនិរន្តរភាព ដោយចាប់ផ្តើមប្រែខ្លួនទៅជាធនាគារពាណិជ្ជ ឬជាក្រុមហ៊ុនឯកជនស្វែងរកប្រាក់ចំណេញ។

នៅឆ្នាំ២០០១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងគេ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ហើយមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនទៀតទទួលបានអាជ្ញាប័ណ្ណ

[1] khemsarith. (2016, Octobor 12). *KHEMSARITH*. Retrieved 07 30, 2024, from https://khemsarith.wordpress.com/author/khemsarith/page/4/
[2] *thmeythmey.com*. (2024, 07 24). Retrieved 07 30, 2024, from https://thmeythmey.com/?page=detail&id=44828
[3] (2021, 05 04). Retrieved from Chanheng_Menh: https://www.khsearch.com/qna/13654

ដំណើរការជាបន្តបន្ទាប់។ មួយឆ្នាំក្រោយមក ពេលគឺនៅឆ្នាំ២០០២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកឈានមុខគេចំនួន៧ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា អម្រឹត ហត្ថាកសិករ ម៉ាក់ស៊ីម៉ា សីលានិធិ CREDO និងប្រាសាក់ បានសម្រេចបង្កើតសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ (NGO) និងសមាគមវិជ្ជាជីវៈដែលមានគោលបំណង ដើម្បីធានានូវភាពរុងរឿង និងនិរន្តរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

នៅឆ្នាំ២០១២ ការិយាល័យឥណទានកម្ពុជាត្រូវបានបង្កើតឡើង ដែលក្លាយជាក្រុមហ៊ុនឈានមុខគេក្នុងការផ្តល់នូវសេវាព័ត៌មានហិរញ្ញវត្ថុ ឧបករណ៍វិភាគទិន្នន័យ និងរបាយការណ៍ឥណទានទៅដល់ស្ថាប័នហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា[4]។

-ទ្រឹស្តីនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

មីក្រូហិរញ្ញវត្ថុ គឺជាពាក្យរួមបញ្ចូលនូវសេវាកម្ម និងផលិតផលហិរញ្ញវត្ថុជាច្រើន ដែលមានគោលបំណងផ្តល់លទ្ធភាពទទួលបានឥណទាន ការសន្សំ ការធានារ៉ាប់រង និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដល់បុគ្គល និងក្រុមគ្រួសារមានចំណូលទាប ជាពិសេសអ្នកដែលត្រូវបានដកចេញពីវិស័យធនាគារផ្លូវការ។ មីក្រូហិរញ្ញវត្ថុអាចត្រូវបានគេមើលឃើញថា ជាមធ្យោបាយនៃការផ្តល់អំណាចដល់ជនក្រីក្រ ការលើកកម្ពស់ភាពជាសហគ្រិន ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ការរួមបញ្ចូលក្នុងសង្គម។ ទោះជាយ៉ាងណាក៏ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ប្រឈមមុខចំពោះបញ្ហា និងការរិះគន់ជាច្រើនផងដែរដូចជា អត្រាការប្រាក់ខ្ពស់ពេកការជំពាក់បំណុលហួសកម្រិត កង្វះបទបញ្ញត្តិ ផលប៉ះពាល់សង្គម និងបរិស្ថាន[5]។

-ទ្រឹស្តីនៃពាក្យសេដ្ឋកិច្ច

តាមទ្រឹស្តីសេដ្ឋវិទូបានឱ្យនិយមន័យសេដ្ឋកិច្ចខុសៗគ្នាជាច្រើន ប៉ុន្តែន័យសុក្រឹតមួយ គឺសេដ្ឋកិច្ចសិក្សាអំពីការប្រើប្រាស់បណ្តាធនធានដ៏កម្រ ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។ មានទ្រឹស្តីមួយទៀតបាននិយាយថា សេដ្ឋកិច្ចជាការសិក្សាអំពីយុទ្ធសាស្ត្រ របៀបប្រើប្រាស់ធនធាន ដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្ស ដែលមានប្រព័ន្ធទាក់ទិននឹងប្រព័ន្ធផលិតកម្ម (ផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម) ប្រព័ន្ធបែងចែក (ផ្នែកពាណិជ្ជកម្ម) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច (ផ្នែកអតិថិជន ផ្នែកគមនាគមន៍ និងដឹកជញ្ជូន)[6]។

សេដ្ឋកិច្ចមានពីរប្រភេទធំៗ គឺមីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ចចែកចេញជាបី គឺសេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចចម្រុះ។

---

[4] *AMS*. (2021, 29 09). (លោកហេងសុវណ្ណ, Producer) Retrieved 07 30, 2024, from https://economy.ams.com.kh/42867

[5] *FasterCapital*. (2024, June 16). Retrieved 08 10, 2024, from https://fastercapital.com/content/Microfinance-Theory--The-Concepts-and-Frameworks-that-Underpin-Microfinance.html

[6] *KHsearch.com*. (2019, 01 09). Retrieved from https://www.khsearch.com/qna/13654

២. វិស័យមីក្រូហិរញ្ញវត្ថុចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជា

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាផ្នែកមួយដ៏សំខាន់នៃវិស័យហិរញ្ញវត្ថុដែលបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា វិស័យនេះ មានការរីកចម្រើនយ៉ាងខ្លាំង និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ។ ម្យ៉ាងវិញទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាស្ថានប័នហិរញ្ញវត្ថុមួយដែលផ្តល់សេវាកម្មប្រាក់សន្សំ ប្រាក់បញ្ញើ និងផ្តល់សេវាប្រាក់កម្ចីខ្នាតតូច និងខ្នាតមធ្យមទៅឱ្យប្រជាជនក្រីក្រ និងអ្នកដែលខ្វះដើមទុន ឬអ្នកបង្កើតមុខរបរថ្មី ដើម្បីឱ្យពួកគេមានជីវភាពល្អប្រសើរឡើង។ សកម្មភាពមួយចំនួនដែលបញ្ជាក់ថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈ៖

- បានផ្តល់កម្ចីដល់កសិករទាំងឡាយសម្រាប់ទិញឧបករណ៍ សម្ភារ និងមធ្យោបាយកសិកម្ម។
- បានផ្តល់កម្ចីដល់ប្រជាពលរដ្ឋក្រីក្រ (កសិករ និងអ្នករកស៊ី)មានចំណូលទាប និងមធ្យម ដែលត្រូវការសាច់ប្រាក់ប្រើប្រាស់ក្នុងការបង្កើត ពង្រីក និងកែលម្អមុខរបរតាមតម្រូវការរបស់ពួកគេឱ្យកាន់តែប្រសើរឡើង។
- បានផ្តល់កម្ចីឱ្យកសិករអាចរក្សាទុក និងអាចលក់កសិផលរបស់ពួកគេនៅពេលណាដែលមានតម្លៃសមរម្យនៅលើទីផ្សារ។
- បានផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈ លើកម្មវិធីផលិតកម្ម កសិកម្ម ដើម្បីឱ្យកសិករចេះរៀបចំ និងអនុវត្តគម្រោងអាជីវកម្មបានត្រឹមត្រូវ តាមរយៈសកម្មភាពនេះអាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់កម្ចីតាមគ្រួសារបានយ៉ាងមានប្រសិទ្ធភាព។
- ចូលរួមកាត់បន្ថយការប្រើប្រាស់កម្ចីមានអត្រាការប្រាក់ខ្ពស់ហួសហេតុ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន តាមរយៈអត្រាការប្រាក់មួយដ៏សមរម្យ។
- ការជួយបង្កើតការងារសម្រាប់ប្រជាជនក្នុងសង្គមតាមរយៈ ការផ្តល់ប្រាក់កម្ចីដល់សហគ្រាសក្រុមហ៊ុនអាជីវកម្ម និងអាចជួយបង្កើតកន្លែងការងារថ្មី និងកែលម្អជីវភាពសង្គមកាន់តែប្រសើរ។
- ផ្តល់សេវាកម្មទូទាត់សាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជន ដើម្បីជួយសម្រួលក្នុងមធ្យោបាយផ្ទេរប្រាក់ ទូទាត់ថ្លៃទំនិញ និងសេវាកម្ម មានភាពរហ័ស សុវត្ថិភាព និងទំនុកចិត្តខ្ពស់ដើម្បីធានាបាននូវនិរន្តរភាពនៃសេដ្ឋកិច្ច។
- ចូលរួមលើកតម្កើងប្រាក់រៀល ស្របតាមគោលការណ៍ធនាគារជាតិ ដើម្បីជួយជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។
- បានចូលរួមបង្កើនផលិតផលក្នុងស្រុក តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុជាច្រើន ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចជនបទ ដែលសេវាកម្មទាំងនោះរួមមាន ឥណទានក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺនកសាងសមត្ថភាពដល់អតិថិជនក្នុងការបង្កើតមុខរបរ ការចុះតាមដាន និងផ្តល់យោបល់ជូនអ្នកខ្វីប្រាក់ ដើម្បីឱ្យការប្រើប្រាស់មីក្រូឥណទានបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ដោយសារបច្ចុប្បន្ននេះ សេវាកម្មធនាគារ និងហិរញ្ញវត្ថុប្រមូលផ្តុំតែតាមទីក្រុងធំៗ ដូច្នេះ ការជំរុញសកម្មភាពមីក្រូហិរញ្ញវត្ថុនៅកម្ពុជា គឺជាកត្តាចាំបាច់មួយក្នុងការបង្កើត និងពង្រឹងមុខរបរនៅជនបទ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជនបទ។

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ដើម្បីដឹកនាំ គ្រប់គ្រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យបានល្អ ដែលធានាបាននូវភាពរឹងមាំព្រមទាំងសុវត្ថិភាពដល់ការផ្តល់សេវាហិរញ្ញវត្ថុជូនសាធារណជននោះ ធនាគារជាតិនៃកម្ពុជាបានកំណត់គោលការណ៍ច្បាប់ និងបទបញ្ញត្តិផ្សេងៗដូចខាងក្រោម៖

១-ការកំណត់ដើមទុនចុះបញ្ជីសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI License) ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ១២០.០០០.០០០.០០០រៀល (មួយរយម្ភៃប៉ីលានរៀល) ស្មើ៣០លានដុល្លារអាមេរិក និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI Listed) ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង៦.០០០.០០០.០០០រៀល (ប្រាំមួយប៉ីលានរៀល) ស្មើ១.៥លានដុល្លារអាមេរិក យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ដែលបានចុះផ្សាយថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ ។

២-ការកំណត់អត្រាការប្រាក់លើឥណទានចំពោះធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ គឺមិនឱ្យលើសពី១៨% ក្នុងមួយឆ្នាំ(១.៥%ក្នុងមួយខែ)សម្រាប់គ្រប់ឥណប្រតិទានៃឥណទាន(១៣-មីនា-២០១៧)។

៣-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន៥ភាគរយ(៥%) នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនី ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា (២៥-កុម្ភៈ-២០០២)។

៤-នៅពេលដែលគ្រឹះស្ថានមានវិនភាពប្រាក់បម្រុងកាតព្វកិច្ចត្រូវបំពេញជាបន្ទាន់នៅពេលណាដែលគ្រឹះស្ថានទាំងនោះទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

៥-រាល់ដំណាច់ខែនីមួយៗគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីអត្រាការប្រាក់ជាមធ្យម ដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា (ប្រកាសធនាគារជាតិនៃកម្ពុជា ០៩-០៩-២០០៩)។

៦-ការកំណត់ប្រាក់តម្កល់ធានាលើដើមទុន ដែលត្រូវដាក់ផ្ញើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន១០ភាគរយ(១០%)នៃដើមទុន (ប្រកាសស្តីពីប្រាក់តម្កល់ធានាលើដើមទុន)។

៧-គ្រឹះស្ថានទាំងអស់ត្រូវមានឥណទានជារូបិយវត្ថុជាតិយ៉ាងតិច១០% នៃសំពៀតឥណទានសរុបដោយត្រូវអនុវត្តចាប់ពីថ្ងៃប្រកាសនេះចូលជាធរមាន និងឱ្យបានពេញលេញយ៉ាងយូរត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៩។

៨-គ្រឹះស្ថានណាដែលគ្មានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុផ្សេងទៀតមិនអាចទទួលប្រាក់បញ្ញើពីសាធារណជនបានទេ។

៩-ការដាក់ចេញប្លង់គណនី និងកាតព្វកិច្ចព័ត៌មានសម្រាប់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។

១០-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ត្រូវអនុវត្តផងដែរនូវស្តង់ដាគណនេយ្យកម្ពុជា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១១-ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់ ស្តីពី លទ្ធផលហិរញ្ញវត្ថុ សំពៀតឥណទាន ប្រាក់បញ្ញើដែលប្រមូលបានព្រមទាំងបណ្តាសាខា (ធនាគារជាតិនៃកម្ពុជា, n.d.)។

១២-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំទៅធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ក-ទីស្នាក់ការកណ្តាលត្រូវបង់ ៧០,០០០,០០០រៀល

ខ-សាខារាជធានា-ខេត្ត-ក្រុង(ពី១-៧សាខា)ត្រូវបង់ក្នុង១សាខា ៤០,០០០,០០០រៀល

-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

ក-ទីស្នាក់ការកណ្តាលត្រូវបង់ ២០,០០០,០០០រៀល

ខ-សាខារាជធានា-ខេត្ត-ក្រុង(ពី១-៧សាខា)ត្រូវបង់ក្នុង១សាខា ៥,០០០,០០០រៀល

គ្រឹះស្ថានត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំឱ្យបានមុនថ្ងៃ១៥ ខែមករារៀងរាល់ឆ្នាំ។ គោលនយោបាយសំខាន់ៗរបស់ធនាគារជាតិក្នុងការអភិវឌ្ឍគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន៖

ក-ជំរុញវឌ្ឍនភាព និងបង្កើនប្រសិទ្ធភាពឥណទានជនបទតាមរយៈ

-ការរៀបចំច្បាប់សម្រាប់គ្រប់គ្រងស្ថាប័នមីក្រូហិរញ្ញវត្ថុ

-ជំរុញឱ្យធនាគារឯកជនគាំទ្រវិស័យឥណទានជនបទ

-បន្តទាក់ទងធនធានហិរញ្ញវត្ថុ និងបច្ចេកទេសពីក្រៅប្រទេស

-បង្កើនសមត្ថភាពប្រតិបត្តិករមីក្រូហិរញ្ញវត្ថុតាមរយៈកម្មវិធីហ្វឹកហ្វឺន

ខ-ការធានាស្ថេរភាពនៃសកម្មភាពឥណទានជនបទតាមរយៈការបង្កើតការិយាល័យត្រួតពិនិត្យធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំណុះឱ្យធនាគារជាតិនៃកម្ពុជា ។

គ-ការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅឆ្នាំ១៩៩៨ ក្នុងគោលបំណងបំពេញនូវកង្វះខាតរវាងតម្រូវការ និងការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅតំបន់ជនបទ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ ធនាគារអភិវឌ្ឍន៍ជនបទមានភារកិច្ចចម្បងគឺ ៖

-ផ្តល់ហិរញ្ញប្បទាន និងបុនហិរញ្ញប្បទានដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ និងធនាគារពាណិជ្ជដែលមានសកម្មភាពទ្រទ្រង់សេដ្ឋកិច្ចជនបទ។

-ចរចាជាមួយម្ចាស់ជំនួយនានា ដើម្បីទាក់ទាញជំនួយ និងឥណទានអនុគ្រោះសម្រាប់ពង្រីកសកម្មភាព

-សហការជាមួយស្ថាប័នហិរញ្ញវត្ថុនានា ក្នុងការផ្តល់ឥណទានដល់កសិករ និងដល់គម្រោងក្នុងវិស័យ

កសិកម្ម និងសេដ្ឋកិច្ចជនបទ។ មូលនិធិរបស់ធនាគារអភិវឌ្ឍន៍ជនបទ គឺបើកចំហសម្រាប់ឱ្យខ្ចីដល់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងវិនិយោគិនទាំងឡាយដែលមានបំណងអភិវឌ្ឍន៍ជនបទ។ ធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់កម្ចីទៅឱ្យប្រតិបត្តិករមីក្រូហិរញ្ញវត្ថុនានាដោយយក ការប្រាក់ទាប។

ឃ-ពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖ តាមរយៈប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលជាប្រតិបត្តិករមីក្រូឥណទានអាចប្រែក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចធ្វើអាជីវកម្មមានលក្ខណៈជាប្រព័ន្ធធនាគារ ដោយបានការទទួលស្គាល់តាមនីតិវិធីនៃច្បាប់ពីសំណាក់ធនាគារជាតិនៃកម្ពុជា និងផ្តល់ភាពងាយស្រួលដល់បណ្តាប្រតិបត្តិករទាំងនោះ ក្នុងការសុំខ្ចីមូលនិធិពីបណ្តាស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីពង្រឹងសកម្មភាពរបស់ខ្លួនប្រកបដោយនិរន្តរភាពយូរអង្វែង។

៣. សន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សា និងការស្រាវជ្រាវដោយយកចិត្តទុកដាក់កន្លងមក យើងអាចវាយតម្លៃបានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងលើកតម្កើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមទីជនបទ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច តាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស និងជាពិសេសការផ្តល់សេវាកម្មឥណទានដល់ប្រជាពលរដ្ឋកំពុងខ្វះខាតនូវទុនហិរញ្ញវត្ថុសម្រាប់យកទៅប្រើប្រាស់ ឬដោះដូរក្នុងការប្រកបមុខរបរផ្សេងៗ ដែលជាតម្រូវការចាំបាច់របស់ពួកគេ ហើយមួយចំនួនទៀតសម្រាប់ការបម្រើឱ្យសេចក្តីត្រូវការនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងជួយផ្តល់ប្រភពទុនសម្រាប់ផ្គត់ផ្គង់ដល់អ្នកមានតម្រូវការលើផ្នែកមូលធន ដែលមានគំនិតក្នុងកិច្ចការជំនួញតូច ធំ ថ្មីផ្សេងៗទៀតផងដែរ។

ដោយមើលឃើញនូវសកម្មភាព ការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំចេះតែកើនឡើង និងសមិទ្ធផលជាច្រើនបែបនេះហើយ ទើបយើងអាចសន្និដ្ឋានបានថា វិស័យមីក្រូហិរញ្ញវត្ថុពិតជាបានចូលរួមអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចកម្ពុជាឱ្យមានការអភិវឌ្ឍរីកចម្រើន និងបានជួយជំរុញសកម្មភាពសេដ្ឋកិច្ចជាតិពិតប្រាកដមែន ។

ឯកសារយោង

១. Khemsarith. (2016, Octobor 12). KHEMSARITH. Retrieved 07 30, 2024, from https://khemsarith.wordpress.com/author/khemsarith/page/4/

២. Thmeythmey.com. (2024, 07 24). Retrieved 07 30, 2024, from https://thmeythmey.com/?page=detail&id=44828

៣. KHsearch.com. (2019, 01 09). Retrieved from https://www.khsearch.com/qna/13654

៤. (2021, 05 04). Retrieved from Chanheng_Menh: https://www.khsearch.com/qna/13654

៥. AMS. (2021, 29 09). (លោកហេងសុវណ្ណ, Producer) Retrieved 07 30, 2024, from https://economy.ams.com.kh/42867

៦. FasterCapital. (2024, June 16). Retrieved 08 10, 2024, from https://fastercapital.com/content/Microfinance-Theory--The-Concepts-and-Frameworks-that-Underpin-Microfinance.html

៧. KHsearch.com. (2019, 01 09). Retrieved from https://www.khsearch.com/qna/13654

៨. vandainstitute. (2017). money&banking-2. Retrieved 08 17, 2024

៩. vandainstitute. (2024). money&banking-1. Retrieved 08 20, 2024

១០. ធនាគារជាតិនៃកម្ពុជា. (n.d.). nbc.org.kh. Retrieved 10 20, 2024, from https://www.nbc.gov.kh/english/index.php

ការរៀបចំយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង

Develop Strategies to Win Competitors

ចូ ធារី
បរិញ្ញាបត្រជាន់ខ្ពស់
គ្រូ មុខវិជ្ជាគ្រប់គ្រង

មូលន័យសង្ខេប

ក្នុងការប្រកបអាជីវកម្ម មានការប្រកួតប្រជែងខ្លាំង អង្គភាពត្រូវការយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីធ្វើឱ្យអាជីវកម្មកាន់តែរឹងមាំ និងអាចទទួលបានជោគជ័យ។ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់យកឈ្នះគូប្រកួតប្រជែងត្រូវបានគេបង្ហាញថាជាជំហានសំខាន់សម្រាប់ការពង្រីកទីផ្សារ និងបង្កើតអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម។

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង។ ការប្រមូលទិន្នន័យតាមរយៈគេហទំព័រដូចជា Coca-Cola Marketing Strategy 2024 (ផ្តោតលើការរៀបចំយុទ្ធសាស្ត្រទីផ្សារ), សៀវភៅគោលមុខវិជ្ជា ការគ្រប់គ្រងយុទ្ធសាស្ត្រ (ផ្តោតសំខាន់ពីការរៀបចំផែនការយុទ្ធសាស្ត្រការវិភាគពីការប្រកួតប្រជែង) និងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង(ផ្តោតទៅលើការកំណត់គោលដៅអង្គភាពនិងស្ថានភាពអាជីវកម្ម)។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យដឹងថា ការរៀបចំផែនការយុទ្ធសាស្ត្រមិនត្រឹមតែជាការសម្រេចចិត្តក្នុងការអភិវឌ្ឍផលិតផល ឬសេវាកម្មប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានរៀបចំឡើង ដើម្បីទាញប្រជាប្រិយភាពពីទីផ្សារ ការទំនាក់ទំនងជាមួយអតិថិជន និងការវិភាគពីគូប្រកួតប្រជែង។ ក្នុងប្រធានបទនេះ នឹងផ្តល់ដល់អ្នកអាន និងអ្នកស្រាវជ្រាវធ្វើការពិចារណានូវធាតុសំខាន់ៗនៃការរៀបចំផែនការយុទ្ធសាស្ត្រដែលអាចជួយឱ្យអ្នកឈ្នះក្នុងការប្រកួតប្រជែងក្នុងអាជីវកម្ម។

១. សេចក្តីផ្តើម

បច្ចុប្បន្ន ប្រទេសកម្ពុជាជាប្រទេសមួយដែលប្រកាន់យកនូវទីផ្សារសេរី គ្រប់អាជីវកម្មទាំងអស់បានចុះក្នុងបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងធ្វើការកសាងប្រកួតប្រជែងលើទីផ្សារដោយសេរី។ ទោះបីអាជីវកម្មទាំងនោះជាអាជីវកម្មខ្នាតតូចក្តី ខ្នាតធំក្តី ត្រូវមានបច្ចេកទេសប្រកួតប្រជែង ក៏ប៉ុន្តែគេបានសង្កេតឃើញថា អាជីវកម្មទាំងអស់អាចឈរជើងនឹងបាន គឺអាស្រ័យទៅលើម្ចាស់អាជីវកម្មនីមួយៗ បានរៀបចំយុទ្ធសាស្ត្រអាជីវកម្ម ដោយបង្កើតបេសកកម្ម ទិសដៅ គោលដៅរបស់ខ្លួនបានច្បាស់លាស់ដើម្បីឆ្ពោះទៅរកការសម្រេចចក្ខុវិស័យរបស់ខ្លួន ។

ការបង្កើត និងរៀបចំយុទ្ធសាស្ត្របានល្អ គឺអាស្រ័យទៅលើម្ចាស់អាជីវកម្មផ្ទាល់ មិនថាជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី ត្រូវរៀបចំនូវគម្រោងផែនការយុទ្ធសាស្ត្ររបស់ខ្លួនបែបណាឱ្យបានល្អប្រសើរ ត្រូវប្រើប្រាស់នូវថាមពល និងធនធានរបស់អង្គភាព។ ជាពិសេស អង្គភាពត្រូវអនុវត្ត តាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្របែបណា ដើម្បីអាចគ្រប់គ្រងស្ថានការណ៍បាននៅពេលដែលអាជីវកម្ម ឬក្រុមហ៊ុនជួបនូវរិបត្តិឬបញ្ហាផ្សេងៗ។

ការធ្វើអាជីវកម្មប្រកបដោយភាពជោគជ័យ យើងត្រូវរៀបចំផែនការយុទ្ធសាស្ត្រទុកជាមុន ហេតុនេះហើយទើបមានប្រធានបទមួយបានលើកឡើងអំពី «**ការរៀបចំយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង**» យកមកសិក្សាស្រាវជ្រាវ។ ដោយមើលឃើញពីសារសំខាន់នៃការរៀបចំយុទ្ធសាស្ត្រសម្រាប់អាជីវកម្ម ទើបមានសំណួរពីរលើកឡើងថា៖

១.តើការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាពមានសារសំខាន់អ្វីខ្លះ?

២.តើដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រត្រូវធ្វើឡើងយ៉ាងដូចម្តេច?

១.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី«**ការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង**»។ ការប្រមូលទិន្នន័យតាមរយៈគេហទំព័រដូចជា Coca-Cola Marketing Strategy 2024 សៀវភៅគោលមុខវិជ្ជាការគ្រប់គ្រងយុទ្ធសាស្ត្រ និងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងរបស់វិទ្យាស្ថាន វ៉ាន់ដា។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យធ្វើឡើងតាមរយៈការដកស្រង់ចេញពីសៀវភៅគោលមុខវិជ្ជា ការគ្រប់គ្រងយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន វ៉ាន់ដា ទៅលើសារសំខាន់នៃការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាពអាជីវកម្ម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យធ្វើឡើងតាមរយៈគេហទំព័រ Coca-Cola Marketing Strategy 2024 សៀវភៅគោលមុខវិជ្ជាការគ្រប់គ្រងយុទ្ធសាស្ត្រ និងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង របស់វិទ្យាស្ថាន វ៉ាន់ដា ទៅលើការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង។

១.៣ ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

១.៣.១ និយមន័យ

ការគ្រប់គ្រង (Management) គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រ ដែលសិក្សាលម្អិតអំពី៖ ១-ការធ្វើផែនការ(Planning), ២-ការចាត់ចែង (Organizing), ៣-ការដឹកនាំ(Leading), ៤-ការត្រួតពិនិត្យឡើងវិញ (Controlling) និង ៥-ការធ្វើសេចក្តីសម្រេចចិត្ត (Decision making)[1] ។

យុទ្ធសាស្ត្រ (Strategic) សំដៅដល់វិធីសាស្ត្រ ល្បិច មធ្យោបាយ ឬជាផែនការសកម្មភាពដែលត្រូវអនុវត្តដើម្បីសម្រេចបាននូវគោលដៅ និងទិសដៅអ្វីមួយ[2]។

ផែនការយុទ្ធសាស្ត្រ (Strategic Planning) ជាផែនការរយៈពេលវែងចាប់ពី៥ឆ្នាំឡើងទៅ ដែលធ្វើការវិភាគពីស្ថានភាពនៃបរិយាកាសនៃអាជីវកម្ម ដើម្បីកំណត់នូវទិសដៅអង្គភាពដើម្បីបំពេញបាននូវបេសកកម្ម និងទស្សនៈវិស័យ [3]។

ការគ្រប់គ្រងយុទ្ធសាស្ត្រ (Strategic Management) គឺជាដំណើរការនៃការរៀបចំលើការបង្កើតយុទ្ធសាស្ត្រ (Strategy Formulation) ការអនុវត្តយុទ្ធសាស្ត្រ (Strategy Implementation) និងការវាយតម្លៃពីយុទ្ធសាស្ត្រ (Strategy Evaluation) សម្រាប់ការសម្រេចចិត្ត លើចំណុចជាយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីអភិវឌ្ឍក្រុមហ៊ុនក្នុងរយៈពេលវែង [4]។

ការប្រកួតប្រជែង គឺជាប្រភេទនៃការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចដែលប្រឈមមុខរបស់ក្រុមហ៊ុនមួយ អាចអនុញ្ញាតឱ្យក្រុមហ៊ុននោះមានភាពទូលំទូលាយក្នុងការធ្វើសេចក្តីសម្រេចចិត្ត កំណត់ថ្លៃ ដោយផ្អែកលើសមត្ថភាពនៃផលិតផលរបស់ក្រុមហ៊ុននោះ[5]។

២. ការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែង

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី១

ការមិនយកចិត្តទុកដាក់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ អាជីវកម្មអាចប្រឈមនឹងការប្រកួតប្រជែងខ្លាំងនៅក្នុងទីផ្សារសេរី ជាពិសេសសព្វថ្ងៃនេះកំពុងមានការប្រកួតប្រជែងកាន់តែខ្លាំងទាំងបច្ចេកវិទ្យា នវានុវត្តន៍ និងបច្ចេកទេសទីផ្សារ។ ដូច្នេះដើម្បីឱ្យអាជីវកម្មរក្សាបាននូវនិរន្តរភាពយូរអង្វែង ម្ចាស់អាជីវកម្មត្រូវរៀបចំផែនការយុទ្ធសាស្ត្រអាជីវកម្មជាមុនសិន មុននឹងចាប់ផ្តើមដំណើរការអាជីវកម្ម។

ផែនការយុទ្ធសាស្ត្រមានសារសំខាន់ចំពោះអង្គភាពដូចជា៖

- អាចបញ្ជាក់ពីទិសដៅ គោលដៅនៃយុទ្ធសាស្ត្រ ដែលជួយក្នុងការប្រតិបត្តិ និងឈានដល់ការសម្រេចឱ្យបាននូវបេសកកម្ម និងចក្ខុវិស័យរបស់អង្គភាព

---

[1] វិទ្យាស្ថានវ៉ាន់ដា: *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង* ឆ្នាំទី១ ធមាសទី២ បោះពុម្ពលើកទី៧(២០២៤) ទំព័រ ២

[2] វិទ្យាស្ថានវ៉ាន់ដា: *ការគ្រប់គ្រងយុទ្ធសាស្ត្រ* ឆ្នាំទី៤ ធមាសទី២ បោះពុម្ពលើកទី៧(២០២៤) ទំព័រ ២

[3] វិទ្យាស្ថានវ៉ាន់ដា: *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង* ឆ្នាំទី១ ធមាសទី២ បោះពុម្ពលើកទី៧(២០២៤) ទំព័រ ១៥

[4] វិទ្យាស្ថានវ៉ាន់ដា: *ការគ្រប់គ្រងយុទ្ធសាស្ត្រ* ឆ្នាំទី៤ ធមាសទី២ បោះពុម្ពលើកទី៧(២០២៤) ទំព័រ ៣

[5] វិទ្យាស្ថានវ៉ាន់ដា: *មូលដ្ឋានគ្រឹះនៃម៉ាយ៉ីតធីង* ឆ្នាំទី១ ធមាសទី២ បោះពុម្ពលើកទី៧(២០១៧) ទំព័រ ៦

- អាចយល់ដឹងអំពីភាពខ្លាំង និងភាពខ្សោយរបស់អង្គភាព ទាក់ទងដល់ការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង និងបុគ្គលិកដែលពាក់ព័ន្ធ
- យល់ដឹងពីការគំរាមកំហែង និងឱកាសល្អៗដែលជះឥទ្ធិពលដល់អង្គភាព
- ជំរុញឱ្យមានលក្ខណៈត្រៀមទុកជាមុន(Proactive) ដោយមិនរង់ចាំមានបញ្ហាហើយ ទើបដោះស្រាយជាក្រោយនោះទេ
- ជួយឱ្យអង្គភាពប្រើប្រាស់ធនធានបានចំគោលដៅ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

លទ្ធផលសម្រាប់សំណួរស្រាវជ្រាវទី២

ដើម្បីឱ្យអាជីវកម្មរក្សាបាននូវនិរន្តរភាពយូរអង្វែង ម្ចាស់អាជីវកម្មត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ការបង្កើតយុទ្ធសាស្ត្រ ការអនុវត្តយុទ្ធសាស្ត្រ ការតាមដានវាយតម្លៃ និងការវិភាគពីបរិស្ថានជុំវិញអង្គភាព ដើម្បីកំណត់យុទ្ធសាស្ត្ររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

២.១ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

អង្គភាពត្រូវរៀបចំចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅ វិភាគពីភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ដើម្បីកំណត់នូវយុទ្ធសាស្ត្រដែលខ្លួនចង់បាន។

ក. ចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅ

- **ចក្ខុវិស័យ** (Vision) ជាការកំណត់នូវអ្វីដែលអង្គភាពចង់ក្លាយជាអ្វីនាអនាគត ឬមានសភាពបែបណានាពេលអនាគត។
- **បេសកកម្ម** (Mission) ជាហេតុផលដែលអង្គភាពចង់ធ្វើ ឬត្រូវតែធ្វើនាពេលអនាគត។
- **គោលដៅ** (Goal) ជាលទ្ធផលនៃការសម្រេចបានពីទិសដៅ ប៉ុន្តែទស្សនខ្លះយល់ថា អត្ថន័យពាក្យទាំងពីរនេះប្រហែលគ្នា។
- **ទិសដៅ** (Objective) សកម្មភាពដែលត្រូវធ្វើ ដើម្បីសម្រេចគោលដៅអង្គភាព។ ទិសដៅអាជីវកម្ម វាបង្ហាញពីទិសដៅដែលត្រូវអនុវត្ត ដើម្បីបំពេញនូវគោលដៅធំមួយ នៅក្នុងគោលដៅអាជីវកម្ម មួយអាចមាន ទិសដៅ២-៣ សម្រាប់គាំទ្រ។

ខ. គោលដៅ និងទិសដៅគួរមានលក្ខណៈឆ្លាត (Goals/Objectives should be SMART)

SMART = ជាពាក្យកាត់នៃពាក្យពេញនីមួយៗ ដូចខាងក្រោម៖

- **Specific: (ជាក់លាក់)** ជាការកំណត់ក្នុងគោលដៅឱ្យជាក់លាក់ ឬពិតប្រាកដ។
- **Measurable: (អាចវាស់បាន ឬអាចថ្លឹងថ្លែងបាន)** គោលដៅគួរតែអាចវាស់វែងបាន ដូចជាអាចដឹងពីលក្ខខណ្ឌនានា និងបរិមាណ (ចំនួនឯកតា ដុល្លារ ភាគរយជាដើម)។
- **Attainable: (ភាពដែលអាចសម្រេចបាន)** គោលដៅដែលបានកំណត់ វាគួរតែអាចសម្រេចទៅកើតដោយបង្ហាញពីភាពប្រាកដនិយម ថានឹងសម្រេចបាន។

- **Results-oriented:** (**និន្នាការឆ្ពោះទៅរកលទ្ធផល**) គោលដៅដែលបានរៀបចំហើយ អង្គភាពតែងផ្តោតការយកចិត្តទុកដាក់ដល់លទ្ធផលដែលនឹងសម្រេចចុងក្រោយថា តើសម្រេចដោយរបៀបណា?
- **Time-limited:** (**ពេលវេលាត្រូវមានដែនកំណត់**) គោលដៅត្រូវមានដែនកំណត់ពីពេលវេលាអនុវត្តន៍ឱ្យសម្រេចបានដូចជា ប៉ុន្មានថ្ងៃ ប៉ុន្មានសប្តាហ៍ ប៉ុន្មានខែ ឬប៉ុន្មានឆ្នាំ ជាដើម។

គ. ការវិភាគបរិស្ថានអាជីវកម្ម

ការវិភាគ SWOT ជាការវិភាគពីភាពខ្លាំង ភាពខ្សោយនៅក្នុងអង្គភាព និងឱកាស ការគំរាមកំហែងទាំងបរិស្ថានខាងក្នុង និងបរិស្ថានខាងក្រៅ ដើម្បីបំពេញនូវយុទ្ធសាស្ត្រប្រតិបត្តិការអង្គភាព។

សមាសធាតុនៃការវិភាគ SWOT

រាល់ការវិភាគ SWOT នឹងរួមបញ្ចូលកត្តាសំខាន់ៗបួនដូចខាងក្រោម៖ SWOT នឹងប្រែប្រួលពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយតាមប្រភេទអាជីវកម្ម និងវិស័យនៃឧស្សាហកម្ម។ ការវិភាគ SWOT គឺមិនពេញលេញទេ បើគ្មានធាតុនីមួយៗទាំងបួននេះចូលរួម៖

- **ភាពខ្លាំង (Strength)** គឺជាការពិពណ៌នាអំពីអ្វីដែលអង្គភាពពូកែ និងអ្វីដែលអង្គភាពមានដោយជួយគាំទ្រសកម្មភាពឱ្យទទួលបានជោគជ័យដូចជា៖ កេរ្តិ៍ឈ្មោះល្បីល្បាញ ទីតាំងអំណោយផល អ្នកដឹកនាំមានសមត្ថភាព មូលដ្ឋានអតិថិជនដ៏ស្មោះត្រង់ តារាងតុល្យការដ៏រឹងមាំ បច្ចេកវិទ្យាពិសេស និងអ្វីៗផ្សេងទៀត។
- **ភាពទន់ខ្សោយ (Weakness)** គឺជាការរារាំងអង្គភាពមិនឱ្យដំណើរការនៅកម្រិតល្អបំផុត គឺជាផ្នែកដែលអាជីវកម្មត្រូវកែលម្អដើម្បីរក្សាការប្រកួតប្រជែង៖ ភាពល្បីល្បាញនៅមានកម្រិត ចំណូលទាបបំណុលកម្រិតខ្ពស់ ការផ្គត់ផ្គង់មិនគ្រប់គ្រាន់ ឬកង្វះដើមទុន។ល។
- **ឱកាស (Opportunity)** សំដៅទៅលើកត្តាខាងក្រៅអំណោយផលដែលអាចផ្តល់ឱ្យអង្គភាពនូវអត្ថប្រយោជន៍ នៃការប្រកួតប្រជែងដូចជា៖ សេដ្ឋកិច្ចខ្លាំង គូប្រកួតប្រជែងចុះទន់ខ្សោយ ធនធានសម្បូរបែប រដ្ឋាភិបាលផ្តល់គោលនយោបាយលើកទឹកចិត្ត។
- **ការគំរាមកំហែង (Threats)** សំដៅទៅលើកត្តាដែលមានសក្តានុពលក្នុងការបង្ករគ្រោះថ្នាក់ដល់អង្គភាពដូចជា៖ គូប្រកួតប្រជែងថ្មី ផលិតផលជំនួស ខ្វះធនធាន ការផ្លាស់ប្តូរទីផ្សារ ច្បាប់ថ្មី។

ឃ. ការបង្កើតយុទ្ធសាស្ត្រ

ការបង្កើតបានជាយុទ្ធសាស្ត្ររួមមួយរបស់អង្គភាព ទាក់ទងនឹងកត្តានានាដែលយុទ្ធសាស្ត្រត្រូវធ្វើរយៈពេលវែង ដោយផ្អែកតាមការគ្រប់គ្រងបានតាមរយៈការវិភាគ (SWOT Analysis)។ ការបង្កើតយុទ្ធសាស្ត្រមានដូចជា៖

- ការកំណត់ពីបេសកកម្ម (Mission)
- ការកំណត់ទិសដៅរយៈពេលវែង (Long term objective)
- ការព្រៀងយុទ្ធសាស្ត្រប្លែកៗពីគ្នា (Alternative strategy)

- ការជ្រើសរើសយកយុទ្ធសាស្ត្រ (Strategy selection)

ង. ការអនុវត្តយុទ្ធសាស្ត្រ

ជាដំណើរការនៃការអនុវត្តទៅលើយុទ្ធសាស្ត្រនានាដែលគេបានជ្រើសរើសយក និងគោលនយោបាយអង្គភាពតាមកម្មវិធីផ្សេងៗ តាមគម្រោងថវិកា និងតាមទម្រង់ការផ្សេងៗ។ ដំណើរការអនុវត្តយុទ្ធសាស្ត្រនេះអាចទាក់ទងទៅនឹងការផ្លាស់ប្តូរវប្បធម៌នៃការគ្រប់គ្រងអង្គភាព រចនាសម្ព័ន្ធអង្គភាព និងរចនាបថគ្រប់គ្រងអង្គភាព។

Strategy Implementation

- Annual objectives (short term milestone that organization must achieve to reach long term objective)
- Policies (Procedure, Standard, Guideline)
- Employees motivation
- Resources allocation

ច. ការតាមដានការអនុវត្តយុទ្ធសាស្ត្រ

គឺជាដំណើរការតាមដានលទ្ធផលពីលើការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពរបស់អង្គភាព ដើម្បីអាចធ្វើការប្រៀបធៀបពីការអនុវត្តយុទ្ធសាស្ត្រជាក់ស្តែងទៅនឹងយុទ្ធសាស្ត្រដែលអង្គភាពចង់បាន។ អ្នកគ្រប់គ្រងគ្រប់កម្រិតត្រូវប្រើប្រាស់ព័ត៌មាន ឬតួលេខពីលទ្ធផលនៃការអនុវត្ត ដើម្បីចាត់វិធានការកែតម្រូវរាល់សកម្មភាព និងដោះស្រាយបញ្ហានានា។

២.២ យុទ្ធសាស្ត្រអាជីវកម្ម

យុទ្ធសាស្ត្រអាជីវកម្មសំដៅលើការសម្រេចចិត្តទាំងអស់ដែលបានធ្វើឡើង និងសកម្មភាពដែលធ្វើឡើងដោយអាជីវកម្មសម្រាប់ការសម្រេចបាននូវចក្ខុវិស័យ។ ការដឹងពីយុទ្ធសាស្ត្រអាជីវកម្ម និងរបៀបអនុវត្តយុទ្ធស្តាស្ត្រឱ្យបានត្រឹមត្រូវ អាចជួយឱ្យអាជីវកម្មក្លាយជាអ្នកដឹកនាំទីផ្សារនៅក្នុងដែនរបស់ពួកគេ។ ជាក់ស្តែងយុទ្ធសាស្ត្រអាជីវកម្ម គឺជាឆ្អឹងខ្នងនៃអាជីវកម្មទាំងអស់ ហើយការខ្វះខាតណាមួយអាចមានន័យថា គោលដៅអាជីវកម្មត្រូវបាត់បង់ពាក់កណ្តាល។

1- Geographic expansion, Diversification
2- Acquisition (Buying full or part of other company)
3- Product development, Market penetration
4- Retrenchment, Divestiture
5- Liquidation, Joint-venture

យុទ្ធសាស្ត្រទាំងអស់នេះ នៅក្នុងអាជីវកម្មភាគច្រើនយកមកអនុវត្តទទួលបានជោគជ័យទាំងនៅក្នុងអាជីវកម្ម ជាពិសេសទទួលការគាំទ្រពីអតិថិជនផងដែរ។ សម្រាប់តែក្រុមហ៊ុន កូកា-កូឡា ក៏ធ្វើការលើកយកយុទ្ធសាស្ត្រមួយចំនួនមកអនុវត្តដូចជា៖

- **បណ្តាញទីផ្សារកូកា-កូឡា**

ដំបូងឡើយ កូកា-កូឡា ប្រើយុទ្ធសាស្ត្រកំណត់គោលដៅដែលមិនខុសគ្នា។ ក្នុងរយៈពេលថ្មីៗនេះ វាបានចាប់ផ្តើមធ្វើមូលដ្ឋានីយកម្មផលិតផលរបស់ខ្លួនសម្រាប់ការទទួលយកបានប្រសើរជាងមុន។ វារួមបញ្ចូលបណ្តាញទីផ្សារមូលដ្ឋានចំនួនពីរ៖ ផ្ទាល់ខ្លួន និងមិនមែនផ្ទាល់ខ្លួន។

បណ្តាញផ្ទាល់ខ្លួន រួមមានការទំនាក់ទំនងដោយផ្ទាល់ជាមួយទស្សនិកជន។ បណ្តាញទីផ្សារមិនមែនផ្ទាល់ខ្លួនរួមមានទាំងប្រព័ន្ធផ្សព្វផ្សាយអនឡាញ និងក្រៅបណ្តាញ ដូចជា៖

- យុទ្ធនាការផ្សព្វផ្សាយ
- ព្រឹត្តិការណ៍
- ទូរទស្សន៍
- ផ្ទាំងរូបភាព
- អ៊ីមែល
- គេហទំព័រ
- ខិត្តប័ណ្ណ
- ផ្ទាំងប៉ាណូ
- ប្រព័ន្ធផ្សព្វផ្សាយសង្គម

Coca-Cola's Gripping Advertisements

- **យុទ្ធសាស្ត្រទីផ្សារកូកា-កូឡា**

យុទ្ធសាស្ត្រទីផ្សារកូកា-កូឡាដែលបានបង្កើតតែមួយគត់ គឺនៅពីក្រោយការឈានទៅដល់អន្តរជាតិរបស់ក្រុមហ៊ុន និងប្រជាប្រិយភាពរីករាលដាល។ យុទ្ធសាស្ត្រអាចត្រូវបានបែងចែកជា: យុទ្ធសាស្ត្រផលិតផលកូកា-កូឡា មានផលិតផលប្រមាណ៥០០។ ភេសជ្ជៈរបស់វាត្រូវបានផ្តល់ជូនជាសកលហើយ យុទ្ធសាស្ត្រផលិតផលរបស់វារួមបញ្ចូលទាំងការលាយទីផ្សារ។ ភេសជ្ជៈមានដូចជា Coca-Cola, Minute Maid, Diet Coke, Light, Coca-Cola Life, Coca-Cola Zero, Sprite Fanta និងជាច្រើនទៀតត្រូវបានលក់ក្នុងទំហំ និងការវេចខ្ចប់ផ្សេងៗ។ ពួកគេរួមចំណែកដ៏សំខាន់ និងបង្កើតប្រាក់ចំណេញដ៏ធំសម្បើម។

- **យុទ្ធសាស្ត្រកំណត់តម្លៃ**

តម្លៃរបស់កូកា-កូឡានៅតែថេរក្នុងរយៈពេលប្រហែល៧៣ឆ្នាំនៅត្រឹមប្រាំសេន។ ក្រុមហ៊ុនត្រូវតែធ្វើឱ្យយុទ្ធសាស្ត្រកំណត់តម្លៃរបស់ខ្លួនមានភាពបត់បែនជាមួយនឹងការកើនឡើងនៃការប្រកួតប្រជែង ជាមួយដៃគូប្រកួតប្រជែងដូចជា Pepsi ។ វាមិនធ្លាក់ថ្លៃខ្លាំងពេកទេ ហើយក៏មិនដំឡើងថ្លៃដោយមិនសមហេតុផលដែរ ព្រោះវានឹងនាំឱ្យអ្នកប្រើសង្ស័យលើគុណភាពផលិតផល ហើយប្តូរទៅជម្រើសផ្សេង។

- **ទីតាំងយុទ្ធសាស្ត្រកូកា-កូឡា**

មានបណ្តាញចែកចាយយ៉ាងទូលំទូលាយ។ វាមានតំបន់ប្រតិបត្តិការចំនួនប្រាំមួយ៖ អាមេរិកខាងជើង អាមេរិកឡាទីន អាហ្វ្រិក អឺរ៉ុប ប៉ាស៊ីហ្វិក និងអ៊ីរ៉ាស៊ី។ ដៃគូដបរបស់ក្រុមហ៊ុនផលិត វេចខ្ចប់ និងដឹកជញ្ជូនទៅភ្នាក់ងារ។ បន្ទាប់មកភ្នាក់ងារដឹកជញ្ជូនផលិតផលតាមផ្លូវទៅកាន់អ្នកស្តុកទុក បន្ទាប់មកទៅកាន់អ្នកចែកចាយ ទៅកាន់អ្នកលក់រាយ និងចុងក្រោយទៅកាន់អតិថិជន។ កូកា-កូឡា ក៏មានបណ្តាញខ្សែសង្វាក់ផ្គត់ផ្គង់បញ្ជ្រាសយ៉ាងទូលំទូលាយ ដើម្បីប្រមូលដបកែវដែលនៅសល់សម្រាប់ប្រើឡើងវិញ។

- **យុទ្ធសាស្ត្រផ្សព្វផ្សាយ**

កូកា-កូឡា ប្រើប្រាស់យុទ្ធសាស្ត្រផ្សព្វផ្សាយ និងទីផ្សារផ្សេងៗគ្នា ដើម្បីរស់រៀនមានជីវិតពីការប្រកួតប្រជែងខ្លាំងនៅក្នុងទីផ្សារ។ វាចំណាយរហូតដល់៤លានដុល្លារជារៀងរាល់ឆ្នាំ ដើម្បីផ្សព្វផ្សាយម៉ាកយីហោរបស់ខ្លួន ដោយប្រើប្រាស់ទាំងមជ្ឈដ្ឋានប្រពៃណី និងអន្តរជាតិសម្រាប់ការផ្សាយពាណិជ្ជកម្ម។

២.៣ ការវិភាគពីគូប្រកួតប្រជែង

Michael Porter បានវិភាគឃើញថាមានកម្លាំងទាំង៥ ដែលមានឥទ្ធិពលដល់ការប្រកួតប្រជែងនៃវិស័យឧស្សាហកម្ម។ កម្លាំងទាំង៥ ត្រូវបានគេវាយតម្លៃ និងពិនិត្យមើលពីលទ្ធភាពនៃ Probability ពីការប្រកួតប្រជែងជោគជ័យនៃអាទិភាពឧស្សាហកម្ម។ ម្យ៉ាងទៀតការវិភាគបានបា្ចស់ពីកម្លាំងទាំង៥នេះ ធ្វើឱ្យក្រុមហ៊ុនអាចកំណត់បានពីតម្លៃនៃការទាក់ទាញចូលទៅកាន់ឧស្សាហកម្ម វិភាគបានពីនិន្នាការប្រកួតប្រជែង និងធ្វើគម្រោងយុទ្ធសាស្ត្រអនាគត។

Port's 5 Forces Model



- **ដៃគូប្រកួតប្រជែងថ្មីមានសក្តានុពល (New Entrants) ៖** ក្រុមហ៊ុនត្រូវពិនិត្យមើលពីដៃគូប្រជែងថ្មីៗទាំងឡាយណាដែលមានសក្តានុពលកំពុងជ្រៀតចូលក្នុងទីផ្សារមានស្រាប់ ឬក៏កំពុងជ្រៀតចូលក្នុងផ្នែកឧស្សាហកម្ម។ ក្រុមហ៊ុនត្រូវតែពិនិត្យមើលឧបសគ្គទាំងឡាយដែលកើតចេញពីរបាំងនៃការធ្វើពាណិជ្ជកម្ម ឬឧស្សាហកម្មមុននឹងសម្រេចចិត្តឈានចូលក្នុងមុខរបរទាំងនេះ។
  - High barrier : ធ្វើឱ្យក្រុមហ៊ុនថ្មីៗពិបាកនឹងឈានចូលបង្កើតមុខរបរ
  - Low barrier : ធ្វើឱ្យក្រុមហ៊ុនថ្មីៗងាយនឹងឈានចូលបង្កើតមុខរបរ។

- **អ្នកផ្គត់ផ្គង់ (Suppliers) ៖** ក្រុមហ៊ុនត្រូវយកចិត្តទុកដាក់ក្នុងការជ្រើសរើសអ្នកផ្គត់ផ្គង់បានល្អ ដើម្បីឆ្លើយតបនឹងការប្រកួតប្រជែង។ ពេលខ្លះមាន Bargaining Power ពីអ្នកផ្គត់ផ្គង់ដោយសារតែក្នុងឧស្សាហកម្មនោះមានអ្នកផ្គត់ផ្គង់តិច។
- **អតិថិជន (Customers) ៖** ក្រុមហ៊ុនត្រូវពិនិត្យមើលពី Bargaining power របស់អតិថិជនដើម្បីសម្របសម្រួលក្នុងបរិស្ថានប្រកួតប្រជែង។ Bargaining power របស់អតិថិជនទាក់ទងនឹងកម្រិតតម្លៃ និងលក្ខខណ្ឌផ្សេងៗនៃការទិញរបស់អតិថិជន។
- **ផលិតផលជំនួស (Substitute Product) ៖** ផលិតផលជំនួស ជាការគំរាមកំហែងដល់ការប្រកួតប្រជែង ប្រសិនបើក្រុមហ៊ុនមិនមានការយកចិត្តទុកដាក់ជាពិសេសទេនោះ។ មានក្រុមហ៊ុនប្រកួតប្រជែងមួយចំនួននឹងប្រើប្រាស់ផលិតផល ឬសេវាកម្មដទៃទៀតមានចរិត និងលក្ខណៈរូបរាងស្រដៀងនឹងផលិតផលដែលក្រុមហ៊ុនកំពុងប្រកួតប្រជែងដែលផលិតផលទាំងនោះ អាចបំពេញសេចក្តីត្រូវការអតិថិជនបាន។
- **ដៃគូប្រជែង (Industry Competition) ៖** មានការគំរាមកំហែងដល់ក្រុមហ៊ុនផងដែរ ទាក់ទងនឹងដៃគូប្រជែងក្នុងវិស័យឧស្សាហកម្ម ដែលតម្រូវឱ្យក្រុមហ៊ុនពិចារណាពីការធ្វើអាជីវកម្ម ដោយពិនិត្យមើលឧស្សាហកម្មណាដែលមានគូប្រកួតច្រើនមិនគួរចូលទេ។ ក្នុងវិស័យឧស្សាហកម្មខ្លះមានការប្រកួតខ្លាំងដោយក្តាប់យកចំណែកទីផ្សារតាមការកាត់បន្ថយថ្លៃដើម។ ប៉ុន្តែមានឧស្សាហកម្មដទៃទៀត គូប្រកួតមិនរំខានក្រុមហ៊ុនដទៃផងដែរ។

៤. សន្និដ្ឋាន

យោងតាមការស្រាវជ្រាវខាងលើ យើងអាចវាយតម្លៃបានថាការរៀបផែនការចំយុទ្ធសាស្ត្រដើម្បីយកឈ្នះគូប្រកួតប្រជែងមិនមានជាការងាយស្រួលនោះទេ អង្គភាពនីមួយៗត្រូវកំណត់ឱ្យបានច្បាស់នូវសេចក្តីថ្លែងចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅ និងផែនការយុទ្ធសាស្ត្រដែលសមស្របតាមស្ថានភាពរបស់អង្គភាព ជាពិសេសអង្គភាពត្រូវការការប្តេជ្ញាចិត្តខ្ពស់របស់ម្ចាស់អាជីវកម្ម ដោយបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ មានធនធានគាំទ្រគ្រប់គ្រាន់ ទាំងធនធានមនុស្ស ធនធានសម្ភារ ធនធានបច្ចេកវិទ្យា ធនធានហិរញ្ញវត្ថុ បង្កើតវប្បធម៌ល្អសម្រាប់អង្គភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផល និងសេវាថ្មីៗដែលស្របតាមតម្រូវការបច្ចុប្បន្ន និងស្ថានភាពទីផ្សារ និងសង្គមខាងក្រៅផងដែរ ។

មិនតែប៉ុណ្ណោះអង្គភាពត្រូវវិភាគ និងសិក្សាពីស្ថានភាពនៃបរិយាកាសខាងក្រៅផងដែរ ដូចជាការវិភាពពីគូប្រកួតប្រជែង កត្តាសេដ្ឋកិច្ច សង្គម និងវប្បធម៌ កត្តាច្បាប់នយោបាយ ទីផ្សារ បច្ចេកវិទ្យា កត្តាប្រជាសាស្ត្រ និងកត្តាផ្សេងៗដែលបង្ក ឱ្យមានកាលានុវត្តភាព និងការគំរាមកំហែងដល់ភាពជោគជ័យនៃការអនុវត្តផែនការ ដើម្បីយកឈ្នះគូប្រកួតប្រជែងផងដែរ។

ឯកសារយោង

១. វិទ្យាស្ថាន រ៉ាន់ដា. (២០២៤) . មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង បោះពុម្ពលើកទី៧ ទំព័រទី២ សរុប៦២ទំព័រ

២. វិទ្យាស្ថាន រ៉ាន់ដា .(២០២៤). ការគ្រប់គ្រងយុទ្ធសាស្ត្រ បោះពុម្ពលើកទី៧ ទំព័រទី២ សរុប៦៨ទំព័រ

៣. វិទ្យាស្ថាន រ៉ាន់ដា. (២០២៤) . មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង បោះពុម្ពលើកទី៧ ទំព័រទី១៥ សរុប៦២ទំព័រ

៤. វិទ្យាស្ថាន រ៉ាន់ដា.(២០២៤). ការគ្រប់គ្រងយុទ្ធសាស្ត្រ បោះពុម្ពលើកទី៧ ទំព័រ៣ សរុប៦៨ទំព័រ

៥. វិទ្យាស្ថាន រ៉ាន់ដា .(២០១៧). មូលដ្ឋានគ្រឹះនៃម៉ាយ៉ីតធីង បោះពុម្ពលើកទី៧ ទំព័រទី៦ សរុប៥០ទំព័រ

៦. វិទ្យាស្ថាន រ៉ាន់ដា.(២០២៤). ការគ្រប់គ្រងយុទ្ធសាស្ត្រ បោះពុម្ពលើកទី៧ ទំព័រ៥ សរុប៦៨ទំព័រ

៧. វិទ្យាស្ថាន រ៉ាន់ដា.(២០២៤). មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង បោះពុម្ពលើកទី៧ ទំព័រ១៦. ១៧. ១៨ សរុប ៦២ទំព័រ

៨. វិទ្យាស្ថាន រ៉ាន់ដា.(២០២៤). ការគ្រប់គ្រងយុទ្ធសាស្ត្រ បោះពុម្ពលើកទី៧ ទំព័រទី២៨. ២៩. ៣០. ៣១ សរុប ៦៨ទំព័រ

៩. By Rahul Arun (23. Jul.2024) Coca-Cola Marketing Strategy 2024: A Case Study
https://www.simplilearn.com/tutorials/marketing-case-studies-tutorial/coca-cola-marketing-strategy